01200897

E350/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 02 / 2016
ម៉ោង (Time/Heure): 16:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

# មាតិកា

១. សេចក្តីផ្តើម ...... 4

២. សារណា ...... 5

២.១ សារណារបស់សហព្រះរាជអាជ្ញា ...... 5

២.២ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ...... 7

២.៣ សារណារបស់មេធាវីការពារក្តី នួន ជា ...... 9

២.៤ សារណារបស់មេធាវីការពារក្តី ខៀវ សំផន ...... 11

៣. សារតារ ...... 12

៣.១ សេចក្តីសម្រេចរបស់ ក.ស.ច.ស និង អ.ប.ជ លើការប្រើប្រាស់ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ...... 12

៣.២ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក លើការធ្វើទារុណកម្មក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២/០១ ...... 14

៤. ច្បាប់ជាធរមាន ...... 16

៥. សំអាងហេតុ ...... 21

៥.១ បញ្ហាបឋម ...... 21

៥.២ បទដ្ឋាន និង បន្ទុកក្នុងការបង្ហាញភស្តុតាង ...... 23

៥.២.១ បទដ្ឋានក្នុងការបង្ហាញភស្តុតាង ...... 23

៥.២.២ បន្ទុកក្នុងការបង្ហាញភស្តុតាង ...... 24

៥.២.៣ បទដ្ឋាន និងបន្ទុកក្នុងការបដិសេធ ...... 25

៥.២.៤ ការវាយតម្លៃចុងក្រោយទៅលើភស្តុតាងដោយអំពើទារុណកម្ម ...... 26

៥.៣ ការពិចារណាលើការជំនុំជម្រះដោយយុត្តិធម៌ ...... 27

៥.៣.១ សច្ចធារណ៍និរទោស ...... 27

៥.៣.២ សិទ្ធិបង្ហាញភស្តុតាងដោះបន្ទុក ...... 28

៥.៤ ការអនុវត្ត និងវិសាលភាពនៃវិធានបដិសេធភស្តុតាង ...... 32

៥.៤.១ ភស្តុតាងដែលបានមកដោយការបង្ខិតបង្ខំ ឬ ការធ្វើបាប ...... 33

៥.៤.២ ភស្តុតាងក្លាយ ...... 41

៥.៥ អញ្ញត្រកម្មចំពោះវិធានបដិសេធភស្តុតាងដែលមាននៅក្នុងមាត្រា ១៥ ...... 44

៥.៥.១ ភស្តុតាងក្នុងសំណុំរឿង ០០២/០២ ដែលមានហានិភ័យពិតប្រាកដដែលថាភស្តុតាងនេះបានមកដោយការធ្វើទារុណកម្ម ...... 50

៥.៥.២ ការប្រើភស្តុតាងដែលបានមកដោយអំពើទារុណកម្មក្នុងសំណុំរឿង ០០២/០២ ...... 51

៥.៥.៣ ការអនុវត្តគោលការណ៍ទាំងនេះនៅពេលអនាគត........................................................ 54

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់ភាគី ដែលបានធ្វើឡើងដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ សុំការបញ្ជាក់អំពីការអនុញ្ញាតឲ្យប្រើប្រាស់ភស្តុតាង ដែលអាចទទួលបានពីការប្រើប្រាស់ទារុណកម្ម។ ទោះបីភាគីទទួលស្គាល់ការអាចប្រើប្រាស់ភស្តុតាងបែបនេះនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្តី ក៏ភាគីបានជំទាស់ទៅនឹងការបកស្រាយអត្ថន័យនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោក ("អនុសញ្ញាប្រឆាំងទារុណកម្ម") ឆ្នាំ ១៩៨៤ ដែលគេក៏ស្គាល់ថាជា "វិធានស្តីពីអញ្ញត្រកម្ម" ដែលចែងថា "រដ្ឋភាគីត្រូវធានាថា ឯកសាររាយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ លើកលែងតែឯកសាររាយការណ៍នោះ ត្រូវបានធ្វើសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម"។

២. នៅក្នុងដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចលើសេចក្តីជំទាស់ផ្សេងៗចំពោះការប្រើប្រាស់ឯកសារមួយចំនួនពីមន្ទីរសន្តិសុខ ស-២១ ដែលភាគីបានស្នើឡើងដើម្បីធ្វើការសាកសួរសាក្សី។ កាលពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទៅលើសេចក្តីជំទាស់ទាំងនេះដោយបានចេញសេចក្តីសម្រេចមួយ ហើយសំអាងហេតុនៃសេចក្តីសម្រេចនេះនឹងត្រូវចេញនាពេលក្រោយ។ កាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសំអាងហេតុពេញលេញចំពោះសេចក្តីសម្រេចរបស់ខ្លួននោះ[1]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យទៅលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងផ្តល់ការណែនាំទៅលើបញ្ហាជាច្រើនដែលភាគីបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការអនុញ្ញាតឲ្យប្រើប្រាស់នូវភស្តុតាងដែលត្រូវបានចោទប្រកាន់ថាបានមកដោយការធ្វើទារុណកម្ម។

៣. អង្គជំនុំជម្រះកត់សម្គាល់ថា សំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលភាគច្រើនសំដៅទៅលើភស្តុតាង ដែលត្រូវបានស្នើដើម្បីប្រើប្រាស់ក្នុងសវនាការរបស់អង្គជំនុំជម្រះ

---

[1] សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ ឯកសារ F26/12 ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក") កថាខណ្ឌ ៣០, ៦៧។

តុលាការកំពូល នៅខែ កក្កដា ឆ្នាំ ២០១៥ ដែលហៅថា ឯកសារ ស-២១[2]។ លើសពីនេះទៀត ដោយសារតែវិសាលភាពនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលមិនបានបកស្រាយអញ្ញត្រកម្មដែលមាននៅក្នុងមាត្រា១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ពាក់ព័ន្ធនឹងចម្លើយ "ប្រឆាំងជនជាប់ចោទនៃអំពើទារុណកម្ម" ហើយអង្គជំនុំជម្រះក៏មិនបានពិនិត្យទៅលើការអនុវត្តគោលការណ៍ទាំងនេះចំពោះឯកសារពីមន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខផ្សេងៗទៀតឡើយ ក្រៅពីឯក-សារពីមន្ទីរសន្តិសុខ ស-២១ នោះ[3]។ ដូច្នេះ សេចក្តីសម្រេចនេះពិនិត្យទៅលើបញ្ហាភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មឱ្យបានគ្រប់ជ្រុងជ្រោយ ដោយដោះស្រាយបញ្ហានីមួយៗដែលបានលើកឡើងនៅក្នុងសំណុំរឿងដែលកំពុងជំនុំជម្រះនាពេលបច្ចុប្បន្ន។

## ២. សារណា

### ២.១ សារណារបស់សហព្រះរាជអាជ្ញា

៤. សហព្រះរាជអាជ្ញាលើកឡើងថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ត្រូវតែបកស្រាយឱ្យស្របតាមគោលបំណងរបស់វា ពោលគឺការលុបបំបាត់ការប្រើប្រាស់អំពើទារុណកម្ម និង កាតព្វ-កិច្ចដែលតម្រូវដោយអនុសញ្ញាក្នុងការចោទប្រកាន់ជនដែលប្រព្រឹត្តអំពើទារុណកម្ម[4]។ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ចែងច្បាស់អំពីការទទួលយកចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្មដើម្បីប្រឆាំងនឹងអ្នកដែលធ្វើទារុណកម្មក្នុងគោលបំណងបង្ហាញថា ចម្លើយសារភាពនោះត្រូវបានរៀបចំបង្កើតឡើង[5]។ ប៉ុន្តែ អនុសញ្ញានេះហាមឃាត់មិនឱ្យប្រើប្រាស់ខ្លឹមសារចម្លើយ

---

[2] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ផ្នែកសម្រេចសេចក្តី កថាខណ្ឌ ៥ ("ភាគីពុំអាចប្រើប្រាស់នូវឯកសារ D312.2.25-D366/7.1.1.8, E3/1682, E3/1855, E3/2792, E3/3857, E3/3989, E3/4202 ពីព្រោះឯកសារទាំងនេះទំនងជាចម្លើយសារភាពដែលទទួលបានមកពីការធ្វើទារុណកម្ម"), សូមមើលផងដែរ សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៣០, កថាខណ្ឌ ៦៥ (បញ្ហានៅទីនេះ គឺថាតើ ចម្លើយនៅមន្ទីរ ស-២១ អាចត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលសវនាការក្នុងខែ កក្កដា ឆ្នាំ ២០១៥ សម្រាប់តែគោលបំណងដែលត្រូវបានកម្រិត ក្នុងការសួរសំណួរសាក្សីទាំងបីរូបលើបណ្តឹងសាទុក្ខដែរ ឬយ៉ាងណា")។

[3] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ២៧, ៣០, ៦៧ ជើងទំព័រ ៥៤។

[4] សារណារបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងការអនុវត្តអនុសញ្ញាប្រឆាំងទារុណកម្ម ចំពោះចម្លើយសារភាពរបស់មន្ទីរសន្តិសុខ ស-២១ និង ឯកសារផ្សេងៗទៀតពាក់ព័ន្ធនឹងការសួរចម្លើយអ្នកជាប់ឃុំ ឯកសារ E350/1 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ("សារណារបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ ២-៣។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ កថាខណ្ឌ ៤-៥, ១៦។

[5] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣,៧។

សារភាពដែលបានពីការធ្វើទារុណកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីទេ ដោយសារខ្លឹមសារចម្លើយសារភាពដែលបានពីអំពើទារុណកម្មនោះមិនគួរឱ្យជឿទុកចិត្តបាន[6]។ ទោះជាយ៉ាងនេះក្តី មូលហេតុដូច្នេះមិនអាចយកមកអនុវត្តបានទេ កាលណាចម្លើយសារភាពនោះត្រូវបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងក្រៅពីដើម្បីបង្ហាញសច្ចភាពនៃចម្លើយសារភាពនោះ[7]។ វិធានបដិសេធភ័ស្តុតាងនេះ មានបំណងរារាំងកុំឱ្យអ្នកធ្វើទារុណកម្មទទួលបានអត្ថប្រយោជន៍ពីចម្លើយសារភាពដែលពួកគេទទួលបានដោយខុសច្បាប់[8]។

៥. សហព្រះរាជអាជ្ញាអះអាងថា កំណត់ហេតុនៃការសួរចម្លើយពីមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អាចទទួលយកបាន លើសពីគោលបំណងនៃការបង្ហាញសច្ចភាពនៃចម្លើយទាំងនោះ[9]។ ការប្រើប្រាស់កំណត់ហេតុសួរចម្លើយដើម្បីបញ្ជាក់ទិន្នន័យអំពីអត្តសញ្ញាណ និងប្រវត្តិរូបរបស់ជនរងគ្រោះ និងកាលបរិច្ឆេទនៃការចាប់ខ្លួនពួកគេ រួមទាំងការសួរចម្លើយ គឺស្ថិតនៅក្នុងវិសាលភាពនៃករណីលើកលែងរបស់មាត្រា ១៥ នេះ ឬ ឆ្លុះបញ្ចាំងអំពីព័ត៌មានដែលមិនមែនបានមកដោយការធ្វើទារុណកម្ម[10]។ ចំណារដែលចារដោយអ្នកសួរចម្លើយ ឬ ថ្នាក់លើរបស់ពួកគេមានលក្ខណៈខុសគ្នាពីចម្លើយសារភាពរបស់ជនរងគ្រោះ។ ហេតុដូចនេះ ចំណារទាំងនោះមិនមែនជាព័ត៌មានដែលបានមកពីការធ្វើទារុណកម្មទេ[11]។ ព័ត៌មានទាំងនោះបញ្ជាក់អំពីការប្រព្រឹត្តិអំពើទារុណកម្ម និងបទឧក្រិដ្ឋដទៃទៀត ព្រមទាំងគោលបំណង និងការដឹងរបស់មេដឹកនាំ ប.ក.ក[12]។ ការប្រើប្រាស់នាពេលក្រោយនូវឈ្មោះបុគ្គលណាមួយ ដែលមាននៅក្នុងចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ ឬ សៀវភៅកំណត់ហេតុនៃមន្ទីរសន្តិសុខក្រាំងតាចាន់ មិនបានពឹងផ្អែកលើខ្លឹមសារនៃចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្មនោះទេ[13]។ របាយការណ៍ និង

[6] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤-៥។ ប្រតិចារិក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៤។

[7] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣, ៥,៧។ ប្រតិចារិក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៧-៨ និង ១៥-១៦។

[8] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤-៦។ ប្រតិចារិក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៥-៦។

[9] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧-១៨។ ប្រតិចារិក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៧-៨។

[10] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥, ៩,១០។ ប្រតិចារិក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ១១-១២។

[11] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥, ១១,១៥។

[12] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥, ១៤,១៥។

[13] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥។

កំណត់ហេតុ អាចត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់អំពីដំណើរការនៃការសម្រេចចាប់ខ្លួន[14]។ លិខិត និង ចម្លើយសារភាពដែលទទួលបាននៅមុនពេលសួរចម្លើយ និង ចម្លើយដែលមិនទំនងជាទទួលបានតាមរយៈការធ្វើទារុណកម្ម បើសិនជាមើលទៅលើខ្លឹមសារនៃចម្លើយនោះ មិនត្រូវចាត់ទុកថាជាភ័ស្តុតាងបានមកពីការធ្វើទារុណកម្មនោះឡើយ[15]។

៦. សហព្រះរាជអាជ្ញាលើកឡើងថា គួរតែមានបទដ្ឋាននៃការបង្ហាញភ័ស្តុតាងច្បាស់លាស់ និង គួរឱ្យជឿទុកចិត្តមួយ ដើម្បីបង្ហាញថា ចម្លើយណាមួយមិនមែនបានមកដោយសារការធ្វើទារុណកម្ម[16]។ ពួកគាត់លើកឡើងបន្ថែមទៀតថា អំពើទារុណកម្មមិនមែនកម្រិតត្រឹមតែការធ្វើបាបផ្នែករាងកាយប៉ុណ្ណោះទេ តែអាចរាប់បញ្ចូលទាំងការធ្វើបាបផ្នែកស្មារតីផងដែរ[17]។

៧. ជាចុងក្រោយ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះមិនគួរដោះស្រាយបញ្ហានេះតាមដំណាក់កាលដូច្នេះទេ។ អង្គជំនុំជម្រះគួររង់ចាំរហូតដល់ការបញ្ចប់ការដេញដោលលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ នេះសិន ចាំសម្រេចលើភាពអាចទទួលយកបាន និង ទម្ងន់នៃភ័ស្តុតាងដែលបានមកពីការធ្វើការទារុណកម្ម[18]។ សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះបានធ្វើដូច្នេះដែរកាលនៅក្នុងសំណុំរឿង ០០១[19]។ ពួកគាត់លើកសម្អាងហេតុថា ចៅក្រមអាជីពមិនត្រូវអនុវត្តវិធានភ័ស្តុតាងតឹងរឹង នៅក្នុងអំឡុងពេលនៃការជំនុំជម្រះឡើយ[20]។

## ២.២ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

៨. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ខ្លឹមសារនៃចម្លើយសារភាពដែលទទួលបានតាមរយៈការប្រើប្រាស់ទារុណកម្ម មិនអាចទទួលយកធ្វើជាភ័ស្តុតាងនោះទេ លើកលែងតែប្រើប្រាស់វាក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ពីការធ្វើទារុណ-

---

[14] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥, ១៥។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ១១-១២។

[15] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦-១៨។

[16] ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ១៣។

[17] ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ១៤។

[18] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១-២២។

[19] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២។

[20] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ១៨-១៩។

កម្មនោះ[21]។ ពួកគាត់ស្នើឱ្យអង្គជំនុំជម្រះសម្រេចថា ភាគីមិនអាចតាំងសំណួរណាមួយដែលផ្តោតលើខ្លឹមសារនៃភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មនោះទេ[22]។ ប៉ុន្តែ ពួកគេលើកឡើងថា ចំណារ ឬ កំណត់សម្គាល់ណាមួយដែលបានបង្កើតឡើងចំពោះភ័ស្តុតាងនោះ នាពេលក្រោយមក អាចទទួលយកធ្វើជាភ័ស្តុតាងបាន[23]។ ដោយសារតែជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ហេតុដូចនេះ ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មអាចប្រើប្រាស់បានដើម្បីប្រឆាំងនឹងជនជាប់ចោទទាំងនោះដើម្បីបញ្ជាក់ថា ភ័ស្តុតាងនោះពិតជាបានមកដោយអំពើទារុណ-កម្មមែន[24]។ ជាពិសេស អត្ថិភាពនៃចម្លើយសារភាព កាលៈទេសៈនៃការបង្កើតចម្លើយសារភាព អត្តសញ្ញាណរបស់ជនដែលបានសារភាព និង ព័ត៌មានអំពីជីវប្រវត្តិផ្សេងទៀត គឺស្ថិតក្នុងករណីលើកលែងនៃមាត្រា ១៥[25]។

៩. ដោយកត់សម្គាល់ឃើញថា ចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ត្រូវបានចាត់ទុកថាជាភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មនៅក្នុងសំណុំរឿង ០០១ រួចទៅហើយនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ឯកសារទាំងនោះត្រូវបានសន្មតថា ទទួលបានមកដោយការធ្វើទារុណកម្ម ហើយមិនអាចយកមកសំអាងសម្រាប់បញ្ជាក់ការពិតនៃខ្លឹមសាររបស់វាទេ លើកលែងតែភាគីណាមួយដែលមានបំណងចង់ពឹងផ្អែកទៅលើឯកសារនេះ បានតវ៉ា ដោយស្នើសុំឱ្យអង្គជំនុំជម្រះស៊ើបអង្កេត អនុលោមតាម ៩៣(១) នៃវិធានផ្ទៃក្នុង ទៅលើកាលៈទេសៈនៃការផ្តល់ចម្លើយសារភាពនោះ[26]។ ចំពោះបទដ្ឋាននៃការបង្ហាញភ័ស្តុតាង សហមេធាវីនាំមុខតំណាង

---

[21] សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងភាពអាចទទួលយកបាន និង ការអនុញ្ញាតដោយច្បាប់ឲ្យប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្ម E350/3 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ("សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខ") កថាខណ្ឌ ១៦, ១៨-១៩។ ប្រតិចារិក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ២១។

[22] សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៨, ប្រតិចារិក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ២១។

[23] សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៧។

[24] សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ១៦, ១៧។

[25] សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ១៦។

[26] សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២០។ ប្រតិចារិក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ២១-២៣, ២៥។

ដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យអង្គជំនុំជម្រះពិចារណានូវនិយាមនៃ "ហានិភ័យពិតប្រាកដ" ដែលថាអំពើទារុណកម្មត្រូវបានប្រើប្រាស់[27]។

## ២.៣ សារណារបស់មេធាវីការពារក្ដី នួន ជា

១០. មេធាវីការពារក្ដី នួន ជា លើកឡើងថា ដោយសារអង្គជំនុំជម្រះតុលាការកំពូលកំពុងដោះស្រាយបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងការប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ហេតុនេះ វាមិនមែនជាការសមស្របទេដែលអង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេចលើការប្រើប្រាស់ទូទៅនៃភ័ស្តុតាងបែបនេះ នាពេលនេះ[28]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងគប្បីសម្រេចត្រឹមតែបញ្ហាជាក់លាក់ដែលបានលើកឡើងចំពោះសាក្សីផ្អែកលើចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ បានហើយ[29]។ ជាពិសេស មេធាវីការពារក្ដី នួន ជា ស្នើសុំការអនុញ្ញាតតាំងសំណួរទៅសាក្សីក្នុងទម្រង់ស្រដៀងគ្នាទៅនឹងការតាំងសំណួរទៅ ពេជ្រ ជឹម[30] ក្នុងអំឡុងនៃសវនាការ កាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥[31] និង ខឹម បឿន ហៅ យាយបឿន នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥[32]។

១១. មេធាវីការពារក្ដី នួន ជា សន្និដ្ឋានថា ទោះបីភាគីគួរត្រូវបានអនុញ្ញាតឱ្យបង្ហាញភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មក្ដី ក៏មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មមិនអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាប្រើប្រាស់ភ័ស្តុតាងបែបនេះដែរ[33]។ ជាពិសេស មេធាវីអះអាងថា ខ្លឹមសារនៃមាត្រា

---

[27] ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ២៤-២៦។

[28] សារណារបស់ នួន ជា ទាក់ទងនឹងការប្រើប្រាស់ "ភ័ស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម" នៅក្នុងសំណុំរឿង ០០២/០២ ឯកសារ E350 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ("សារណារបស់ នួន ជា") កថាខណ្ឌ ៩, ១១។

[29] សារណារបស់ នួន ជា កថាខណ្ឌ ១១។ ដូចគ្នានឹង ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥ ទំព័រទី ២៥ ("ខ្ញុំសូមឱ្យអង្គជំនុំជម្រះ [...] បញ្ចូលក្នុងសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់ខ្លួន អំពីវិធីដោះស្រាយចំពោះការអានហេតុពីក្រាំងគាត់")។

[30] ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥ ទំព័រទី ៣០ ("តើអ្នកមានដែលធ្លាប់ដឹងឬទេថា សែ ឆ្លើយដាក់អ្នក និង បងប្អូនរបស់អ្នក ថាជាអ្នកចូលក្នុងខ្សែគាត់?")។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ទំព័រទី ៣១-៣៣។

[31] សារណារបស់ នួន ជា កថាខណ្ឌ ៤, ៩។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ២៧, ៣៧, ៣៩។

[32] សារណារបស់ នួន ជា កថាខណ្ឌ ៧។ ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ២៩-៣៤។

[33] សារណារបស់ នួន ជា កថាខណ្ឌ ១៥-២៣។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៣០។

នេះលើកលែងចំពោះការអនុវត្តនូវការប្រើប្រាស់ចម្លើយដែលបានមកដោយការធ្វើទារុណកម្មដោយអាជ្ញាធររដ្ឋ (ក្នុងករណីនេះគឺសហព្រះរាជអាជ្ញា) ប្រឆាំងនឹងបុគ្គលមួយចំនួន[34]។ មេធាវីការពារក្តីអះអាងថា ការវិវត្តន៍នាពេលកន្លងមកនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការអនុវត្តរបស់រដ្ឋគាំទ្រការបកស្រាយបែបនេះ[35]។

១២. មេធាវីការពារក្តីកត់សម្គាល់ថា ភាពអាចទទួលយកបាននៃភ័ស្តុតាង គឺស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៨៧(៣)[36]។ មេធាវីការពារក្តីលើកឡើងថា ចម្លើយដែលបានមកដោយការធ្វើទារុណកម្ម ដែលអាចបញ្ជាក់ពីនត្ថិភាពនៃពិរុទ្ធរបស់ជនជាប់ចោទ គួរតែអាចទទួលយកបាន[37] និងគប្បីវាយតម្លៃទៅលើទម្ងន់ជាភ័ស្តុតាងរបស់វានៅពេលក្រោយ[38]។ មេធាវីការពារក្តីអះអាងថា ការធ្វើដូច្នេះគឺជាផ្នែកមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[39]។ មេធាវីការពារក្តីលើកឡើងបន្ថែមទៀតថា ច្បាប់ក្នុងប្រទេសកាណាដា ដាណឺម៉ាក ក្រិច និងអូទ្រីស ទទួលស្គាល់ភាពអាចទទួលយកបានជាទូទៅនៃភ័ស្តុតាងដោះបន្ទុក[40]។ ភ័ស្តុតាងដែលទទួលបានតាមរយៈការប្រើប្រាស់ទារុណកម្ម ជាអាទិ៍ ដែលជាភ័ស្តុតាងបានមកដោយខុសច្បាប់ក៏ដោយ ក៏មិនគួរត្រូវបានបដិសេធដាច់ខាតគ្រប់ពេលនោះដែរ[41]។

១៣. ចុងក្រោយ មេធាវីការពាក្តីសន្និដ្ឋានថា សហព្រះរាជអាជ្ញាបានប្រើភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មជាច្រើនលើក ប៉ុន្តែ បែរជាជំទាស់មិនឱ្យមេធាវីការពារក្តីប្រើប្រាស់វាទៅវិញ[42]។ មេធាវីការពារក្តីលើកឡើងថា ការធ្វើបែបនេះគឺជាការអនុវត្តនិយាមពីរខុសគ្នា[43]។

---

[34] សារណារបស់ នួន ជា កថាខណ្ឌ ១៧។

[35] សារណារបស់ នួន ជា កថាខណ្ឌ ១៨-២៣។

[36] សារណារបស់ នួន ជា កថាខណ្ឌ ២៤។

[37] សារណារបស់ នួន ជា កថាខណ្ឌ ២៨, ៣០។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៣០។

[38] សារណារបស់ នួន ជា កថាខណ្ឌ ២៨។

[39] សារណារបស់ នួន ជា កថាខណ្ឌ ២៥-២៦។

[40] សារណារបស់ នួន ជា កថាខណ្ឌ ២៧។

[41] ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ២៩។

[42] សារណារបស់ នួន ជា កថាខណ្ឌ ២៩-៣០។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៣១-៣២។

## ២.៤ សារណារបស់មេធាវីការពារក្តី ខៀវ សំផន

១៤. មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មអាចប្រើប្រាស់បានសម្រាប់តែបង្ហាញថាពិតជាមានចម្លើយសារភាពតែប៉ុណ្ណោះ ហើយភាគីទាំងអស់ដែលមានបំណងប្រើប្រាស់ភ័ស្តុតាងបែបនេះ ត្រូវបង្ហាញភ័ស្តុតាងដើម្បីបញ្ជាក់ថា ពួកគេប្រើភ័ស្តុតាងនេះតែក្នុងគោលបំណងនេះប៉ុណ្ណោះ[44]។ មេធាវីការពារក្តីអះអាងថា វិធានបដិសេធភ័ស្តុតាងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម អាចអនុវត្តបានសម្រាប់តែចម្លើយណាដែលត្រូវបានបង្ហាញឱ្យឃើញថា បានមកដោយការធ្វើទារុណកម្ម[45]។ មេធាវីការពារក្តី ខៀវ សំផន លើកឡើងថា មិនមែនអ្នកជាប់ឃុំទាំងអស់ ដែលត្រូវបានសួរចម្លើយនៅមន្ទីរសន្តិសុខក្រាំងតាចាន់ សុទ្ធតែរងការធ្វើទារុណកម្មផ្នែករាងកាយគ្រប់គ្នានោះទេ[46] ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថារាល់ចម្លើយសារភាពទាំងអស់ សុទ្ធតែបានមកដោយការធ្វើទារុណកម្មនោះដែរ[47]។ មេធាវីការពារក្តីលើកឡើងបន្តទៀតថា ក្នុងករណីមានវិមតិសង្ស័យអំពីវិធីនៃការទទួលបានចម្លើយសារភាពណាមួយ អង្គជំនុំជម្រះមិនអាចយកចម្លើយនោះមកប្រើបានទេ[48]។

១៥. មេធាវីការពារក្តី ខៀវ សំផន សន្និដ្ឋានផងដែរថា ច្បាប់កម្ពុជាមិនអនុញ្ញាតឱ្យទទួលយកចម្លើយសារភាពដែលបានមកដោយការបង្ខិតបង្ខំលើរូបរាងកាយ ឬ ផ្លូវចិត្តឡើយ[49]។ បទដ្ឋានដូចគ្នានេះគប្បីយកមកអនុវត្ត ដោយសារតែច្បាប់កម្ពុជា និង អនុសញ្ញាប្រឆាំងទារុណកម្មមានគោលបំណងដូចគ្នា[50]។

---

[43] សារណារបស់ នួន ជា កថាខណ្ឌ ៣០។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ២៨។

[44] សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងការប្រើប្រាស់ព័ត៌មានបានមកពីការធ្វើទារុណកម្ម ឯកសារ E350/4 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ ("សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន") កថាខណ្ឌ ១៤។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៤០-៤១, ៤៥-៤៦។

[45] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន កថាខណ្ឌ ៦។

[46] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន កថាខណ្ឌ ៧។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៤៣, ៤៦។

[47] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន កថាខណ្ឌ ៨។

[48] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន កថាខណ្ឌ ៩។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៤៥-៤៦។

[49] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន កថាខណ្ឌ ១០។ ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៤៣, ៤៧។

[50] សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន កថាខណ្ឌ ១១-១៣។

## ៣. សាធារ

### ៣.១ សេចក្ដីសម្រេចរបស់ ក.ស.ច.ស និង អ.ប.ជ លើការប្រើប្រាស់ភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម

១៦. ក្នុងឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចមួយលើការប្រើប្រាស់ត្រឹមត្រូវនូវភ័ស្តុតាងដែលអាចបានមកដោយការធ្វើទារុណកម្ម[51]។ នៅក្នុងការបកស្រាយអនុសញ្ញាប្រឆាំងទារុណកម្មនេះ ដំបូងសហចៅក្រមស៊ើបអង្កេតបានសម្រេចថា មានប្រភេទព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ដែលមិនមែនបានមកដោយការធ្វើទារុណកម្ម ដូច្នេះហើយមិនជាប់ពាក់ព័ន្ធនឹងមាត្រា ១៥ នោះទេ។ ឯកសារប្រភេទនេះ រួមមាន ចំណារដោយដៃដែលសរសេរដោយនរណាម្នាក់ដែលមិនត្រូវរងទារុណកម្ម ឯកសារប្រវត្តិរូបបឋម (ប្រសិនបើរកឃើញថា ឯកសារនេះទទួលបាននៅមុនពេលជននោះចូលដល់មន្ទីរសន្តិសុខ ស-២១) "ព័ត៌មានជាសត្យានុម័តណាមួយ [...] ដែលកើតមានដោយមិនជាប់ពាក់ព័ន្ធនឹងការសួរចម្លើយ ដូចជាកាលបរិច្ឆេទនៃការចាប់ខ្លួនជននោះ" និង ព័ត៌មានពាក់ព័ន្ធទៅនឹងប្រវត្តិរូប ដូចជា ឈ្មោះ អាយុ តួនាទី និង អង្គភាពការងាររបស់ជនដែលរងអំពើទារុណកម្ម[52]។

១៧. សហចៅក្រមស៊ើបអង្កេតសម្រេចថា មាន "អញ្ញត្រកម្មខ្លះៗ" ចំពោះមាត្រា ១៥ ក្នុងការអនុញ្ញាតឲ្យប្រើប្រាស់ភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ដែលត្រូវប្រើ "ប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម ដើម្បីជាភ័ស្តុតាងបញ្ជាក់ថា ចម្លើយសារភាពនោះ ពិតជាត្រូវបានធ្វើឡើងមែន"។ សហចៅក្រមស៊ើបអង្កេតសម្រេចថា ការអនុវត្តនេះ មិនមែនប្រើបានតែក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងចារីផ្ទាល់នៃអំពើទារុណកម្មដែលរងការចោទប្រកាន់ប៉ុណ្ណោះទេ ប៉ុន្តែគេអាចប្រើវាបានក្នុងករណីដែលជនជាប់ចោទ ត្រូវបានចោទប្រកាន់លើការទទួលខុសត្រូវរបស់ថ្នាក់លើ ឬ សហឧក្រិដ្ឋកម្មរួមផងដែរ ដោយសារ "វាមានសារសំខាន់ស្មើគ្នា ទោះបីជាមិនមានសារសំខាន់ខ្លាំងជាងនោះក៏ដោយ ក្នុងការទប់ស្កាត់អំពើទារុណកម្មដែលប្រព្រឹត្តដោយជនដែលមានឋានៈខ្ពស់ក្នុងខ្សែសង្វាក់នៃការបញ្ជា" ដូចគ្នានឹងចារីផ្ទាល់ដែលអនុវត្តគោលនយោបាយនៃការប្រើ

---

[51] ដីកាសម្រេចលើការប្រើប្រាស់ភ័ស្តុតាងដែលបានមក ឬ ដែលអាចបានមកដោយការធ្វើទារុណកម្ម D130/8 ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ("ដីកាសម្រេចរបស់ ក.ស.ច.ស")។

[52] ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ១៩។

អំពើទារុណកម្មនោះ[53]។ សហចៅក្រមស៊ើបអង្កេតលើកឡើងនូវហេតុផលចំនួនពីរនៃមាត្រា ១៥ ៖ ទីមួយ ការលុបបំបាត់ការលើកទឹកចិត្តមិនឱ្យប្រើប្រាស់អំពើទារុណកម្ម និង ទីពីរ ការទប់ស្កាត់មិនឱ្យប្រើព័ត៌មានដែលមិនគួរឱ្យជឿជាក់បាន។សហចៅក្រមស៊ើបអង្កេតសម្រេចថា ហេតុផលទីមួយមិនអាចអនុវត្តបានទេ ដោយយល់ថា ការបដិសេធព័ត៌មាននៅក្នុងសំណុំរឿង ០០២ នេះ នឹងមិនអាចធ្វើឱ្យជនប្រព្រឹត្តិអំពើទារុណកម្មញញើតទេ ព្រោះថាភ័ស្តុតាងនោះមានអាយុកាល ៣០ ឆ្នាំមកហើយ ហើយភ័ស្តុតាងនោះមិនមែន អ.វ.ត.ក ឬ មន្ត្រី អ.វ.ត.ក ជាអ្នកប្រមូលបាននោះទេ[54]។

១៨. ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតយល់ថា បញ្ហានៃភាពគួរឱ្យជឿជាក់បាននៃភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ជាកត្តាដែលគួរធ្វើការពិចារណា។ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ភ័ស្តុតាងបែបនេះអាចត្រូវប្រើបានតាមពីររបៀប ដោយមិនពឹងផ្អែកលើភាពគួរឱ្យជឿជាក់បាននៃភ័ស្តុតាងក៏បាន៖ ១) ជាតម្រុយនៃការស៊ើបអង្កេត និង ២) សម្រាប់គោលបំណងផ្សេងក្រៅពីការបង្ហាញការពិតនៃខ្លឹមសារចម្លើយសារភាព។ ប្រភេទទីពីរនេះបូកបញ្ចូលទាំងបញ្ជីរបស់ជនដែលត្រូវចោទថាក្បត់ "ប្រសិនបើគេអាចបង្ហាញឱ្យឃើញថា ជនដែលមានឈ្មោះក្នុងបញ្ជីនោះត្រូវបានចាប់ខ្លួន ឬ សម្លាប់ចោលនៅពេលក្រោយ" នោះ វាគឺជាភ័ស្តុតាងបញ្ជាក់អំពីការដែលជនជាប់ចោទពឹងផ្អែកលើព័ត៌មាននេះ[55]។

១៩. ចុងក្រោយ សហចៅក្រមស៊ើបអង្កេតសម្រេចថា "តាមច្បាប់ ព័ត៌មានដែលបានមកដោយការធ្វើទារុណកម្ម មិនអាចយកជាការបានទេ"។ ប៉ុន្តែ ពួកគាត់សម្រេចថា វាអាចមានលទ្ធភាពដែលថាភ័ស្តុតាងបែបនេះអាចមានផ្នែកមួយចំនួនជាការពិត ហើយពួកគាត់នឹងពិចារណាលើការពឹងផ្អែកលើភ័ស្តុតាងប្រភេទនេះនៅចុងបញ្ចប់នៃកិច្ចស៊ើបសួរ ទៅតាមករណីជាក់ស្តែង[56]។ អង្គបុរេជំនុំជម្រះសម្រេចលើចំណុចចុងក្រោយមួយនេះ នៅពេលអង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍ដោយផ្អែកទៅលើភាពអាចទទួលយកបាននៃភ័ស្តុតាង។ អង្គបុរេជំនុំជម្រះបានលើកឡើងថា "ទោះបីជាសហចៅក្រមស៊ើបអង្កេតមានសេចក្តីសង្កេតផ្ទុយពីនេះក្នុងដីកាសម្រេចរបស់ខ្លួនក្តី ក៏មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មនឹងត្រូវយកមកអនុវត្តយ៉ាងម៉ឺងម៉ាត់។ គ្មានចន្លោះណា

[53] ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ២០, ២២។

[54] ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ២៣, ២៤។

[55] ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ២៥-២៧។

[56] ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ២៨-២៩។

មួយដែលបើកលទ្ធភាពឱ្យមានការកំណត់ការពិត ឬ ឱ្យប្រើសេចក្ដីថ្លែងការណ៍ដែលបានមកពីអំពើទារុណកម្មក្នុងវិធីផ្សេងពីនេះឡើយ”[57]។

## ៣.២ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក លើការធ្វើទារុណកម្មក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២/០១

២០. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដូចៗគ្នាថា ភ័ស្ដុតាងដែលបានមកដោយការធ្វើទារុណកម្មមិនអាចប្រើប្រាស់បានសម្រាប់បញ្ជាក់ការពិតនៃខ្លឹមសាររបស់ភ័ស្ដុតាងនោះបានទេ[58]។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកតារាងចំណាររបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលមានចម្លើយសារភាពចំនួន ៦០ ពីមន្ទីរសន្ដិសុខ ស-២១ ដោយអង្គជំនុំជម្រះគូសបញ្ជាក់ថា “ភាពពាក់ព័ន្ធនៃឯកសារទាំងនេះ មានកំណត់ត្រឹមតែអង្គហេតុដែលថាឯកសារទាំងនោះត្រូវបានបង្កើតឡើង និង ក្នុងករណីដែលសមស្របធ្វើជាភ័ស្ដុតាងបង្ហាញថាឯកសារទាំងនោះត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្ម។ ឯកសារទាំងអស់នោះ គឺមិនត្រូវបានអនុញ្ញាតឱ្យយកមកប្រើប្រាស់ ដើម្បីបញ្ជាក់ការពិតនៃខ្លឹមសាររបស់វានោះទេ”[59]។ នៅក្នុងការអនុវត្តបន្តទៀតនៃសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រមសំណុំរឿង

---

[57] សាលដីសម្រេចលើការទទួលយកបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ ក.ស.ច.ស លើសំណើរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភ័ស្ដុតាង និង ការសម្អាងទៅលើភ័ស្ដុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម D130/7/3/5 ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៣៨។

[58] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រទី ៩ (“អង្គសវនាការចង់បញ្ជាក់អំពីសារសំខាន់នៃអង្គហេតុដែលថាសវនាការនេះ គឺត្រូវគោរពមាត្រា១៥ នៃអនុសញ្ញាស្ដីពីការធ្វើទារុណកម្ម ដែលលោកប្រធានទើបតែអានអម្បាញ់មិញនេះ ។ បទប្បញ្ញត្តិនេះ គឺបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និង វិធាន២១.៣ នៃវិធានផ្ទៃក្នុង [...] ។ ក្នុងការអនុវត្តចំណុចនេះមានន័យថា ចម្លើយសារភាពដែលបានធ្វើឡើង ហើយបានធ្វើឡើងក្រោមការធ្វើទារុណកម្មនោះ គឺជាអង្គហេតុដែលមានអត្ថិភាពពិតប្រាកដមែន ។ ប៉ុន្តែខ្លឹមសារនៃការសារភាព ដែលធ្វើឡើងដោយអំពើទារុណកម្មនោះ គឺមិនអាចទទួលយកបានថា វាជាចម្លើយមួយដែលពិតប្រាកដនោះទេ ។ ប្រសិនបើភាគីណាមួយចង់លើកឡើងអំពីភាពពិតប្រាកដ ឬ ក៏ខ្លឹមសារនៃចម្លើយសារភាពទាំងអស់នោះ វាជាការចាំបាច់ក្នុងការបង្ហាញជាមុនឱ្យឃើញថា ចម្លើយសារភាពត្រូវបានធ្វើឡើងដោយមានទារុណកម្ម ឬ ក៏ដោយមានការគំរាមកំហែងនៃអំពើទារុណកម្ម ។ ដោយសារមូលហេតុនេះ ភាគីគួរតែពិចារណាថាតើការពិនិត្យទៅលើខ្លឹមសារនៃចម្លើយសារភាពទាំងអស់នោះ គឺវាគ្រប់គ្រាន់ ហើយមានសារសំខាន់ពេញលេញដែរ ឬទេ ក្នុងការពិចារណាទៅលើលក្ខខណ្ឌ ឬ ក៏ស្ថានភាពមួយចំនួនដែលចម្លើយសារភាពនោះត្រូវបានធ្វើឡើង ។”)។

[59] សេចក្ដីសម្រេចលើសំណើរបស់ភាគីទាំងនាសុំដាក់សម្ភារៈមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង ៨៧ (២) E176 (សំណុំរឿង ០០១) ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ៨។

០០១ បានយោងទៅឯកសារមួយដែលត្រូវបានបង្កើតឡើងដោយអ្នកសួរចម្លើយនៅមន្ទីរសន្តិសុខ ស-២១ ដែលជាមូលដ្ឋានសម្រាប់ការចាប់ខ្លួនអ្នកជាប់ឃុំ ដោយផ្អែកលើចម្លើយសារភាពរបស់អ្នកទាំងនោះ និង ព័ត៌មានដែលត្រូវបានចងក្រងដើម្បីស៊ើបអង្កេត និង ឈានទៅចាប់ខ្លួនអ្នកដទៃទៀត[60]។ លើសពីនេះទៀត នៅពេលវាយតម្លៃទៅលើតួនាទីរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ នៅក្នុងការចាប់ខ្លួន អង្គជំនុំជម្រះបានផ្អែកទៅលើលិខិតជាច្រើនពី ស៊ូ ម៉េត (មេបញ្ជាការកងពល ៥០២) ដែលបានផ្ញើទៅកាន់ជនជាប់ចោទរូបនេះ ពាក់ព័ន្ធនឹងការចាប់ខ្លួនជនទាំងឡាយដែលត្រូវបានកំណត់ថាស្ថិតនៅក្នុងខ្សែបណ្ដាញនៅក្នុងចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១[61]។ អង្គជំនុំជម្រះមិនបានផ្អែកលើខ្លឹមសារនៃចម្លើយសារភាពទាំងនេះនោះទេ។

២១. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចផ្ទាល់មាត់មួយ នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ដោយបានបញ្ជាក់សាជាថ្មីនូវសេចក្ដីសម្រេចរបស់ខ្លួនដែលថា ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ត្រូវបានយកមកប្រើដោយមានកម្រិត និងណែនាំឲ្យភាគីយោងទៅសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះកាលពីពេលមុន ពាក់ព័ន្ធនឹងបញ្ហានេះក្នុងសំណុំរឿង ០០១[62]។ អង្គជំនុំជម្រះពិចារណាលើបញ្ហានេះឡើងវិញជាច្រើនលើកក្នុងសំណុំរឿងនោះ ដោយបានបញ្ជាក់សាជាថ្មីថា អង្គជំនុំជម្រះមានកាតព្វកិច្ចអនុវត្តតាមអនុសញ្ញាប្រឆាំងទារុណកម្ម និង មិនអនុញ្ញាតឲ្យភាគីយោងទៅខ្លឹមសារនៃចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្មនោះទេ ទោះជា

---

[60] *កាំង ហ្គេកអ៊ាវ ហៅ ឌុច*, សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជសដ, សាលក្រម, E188, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រមសាលាដំបូងក្នុងសំណុំរឿង ០០១"), កថាខណ្ឌ ២៥៤ (ដកស្រង់បញ្ជីស្ថិតិរបស់សន្តិបាលស-២១, E3/426)។

[61] *កាំង ហ្គេកអ៊ាវ ហៅ ឌុច*, សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជសដ, សាលក្រម, E188, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រមសាលាដំបូងក្នុងសំណុំរឿង ០០១"), កថាខណ្ឌ ១៧០ (ដកស្រង់ឯកសារសំណុំរឿង ០០១៖ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើទៅ ឌុច– ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៧៧", E3/40។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើទៅ ឌុច– ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៧", E3/210។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើទៅ ឌុច– ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៧៧", E3/211។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើទៅ ឌុច– ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ១៩៧៧", E3/212។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើទៅ ឌុច– ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ១៩៧៧", E3/213។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើទៅ ឌុច– ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៧៧", E3/214។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើទៅ ឌុច– ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៧៧", E3/215។ "លិខិតរបស់ ស៊ូ ម៉េត ផ្ញើទៅ ឌុច– ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៧", E3/216)។

[62] ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ទំព័រទី ៨៨។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និង ចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ E185 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២១(៩)។

អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីយោងទៅលើចំណារ ឬ កាលបរិច្ឆេទនៅក្នុងចម្លើយសារភាពក្តី[63]។ អង្គជំនុំជម្រះបានបញ្ជាក់បន្ថែមទៀតថា "ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ដែលផ្ទុយទៅនឹងបទប្បញ្ញត្តិនៃអនុសញ្ញាប្រឆាំងទារុណកម្ម មិនអាចត្រូវបានអនុញ្ញាតឲ្យយកមកប្រើជាភស្តុតាង ឬ ជាមូលដ្ឋានក្នុងការតាំងសំណួរបានទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមរម្លឹកភាគីថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យសួរសំណួរពាក់ព័ន្ធនឹងខ្លឹមសារនៃចម្លើយសារភាព ហើយអង្គជំនុំជម្រះក៏នឹងមិនប្រើប្រាស់ព័ត៌មានប្រភេទនេះនៅក្នុងសាលក្រមរបស់ខ្លួនឡើយ"[64]។ ក្នុងពេលសួរសំណួរ ឌុច ដែលចូលខ្លួនមកផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីនៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសួរសំណួរពាក់ព័ន្ធនឹងថាតើ ប៉ង់ ដែលជាកម្មាភិបាលមួយរូប និង ក្រោយមកបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពផ្សេងទៀតដែរ ឬ យ៉ាងណានោះទេ ដោយសារតែសំណួរនោះ ផ្អែកលើចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម[65]។ ចុងក្រោយ នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានបញ្ជាក់សាជាថ្មីថា "អង្គជំនុំជម្រះអាចពឹងផ្អែកលើភស្តុតាងជាក់លាក់មួយចំនួន តែសម្រាប់គោលបំណងដែលមានដែនកំណត់ប៉ុណ្ណោះ ប៉ុន្តែមិនមែនដើម្បីបញ្ជាក់ការពិតលើខ្លឹមសារនៃចម្លើយសារភាពនោះឡើយ"[66]។

## ៤. ច្បាប់ជាធរមាន

២២. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា "ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ"[67]។ លើសពីនេះទៀត មាត្រា

---

[63] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រទី ១០៨។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥ (ចៅក្រម Lavergne ៖ "ប្រសិនបើគោលបំណងពាក់ព័ន្ធនឹងការប្រើប្រាស់កំណត់ត្រានៅក្នុងក្រាំងតាចាន់ បង្ហាញអំពីអត្តសញ្ញាណរបស់អ្នកដែលត្រូវបានឃុំនៅក្នុងមន្ទីរសន្តិសុខនោះ អង្គជំនុំជម្រះយល់ឃើញថាមិនមានការជំទាស់ក្នុងការប្រើប្រាស់ឯកសារបែបនេះទេ។")។

[64] ប្រតិចារឹក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ ទំព័រទី ៧៤ (មានគូសបញ្ជាក់បន្ថែម)។

[65] ប្រតិចារឹក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ ទំព័រទី ១២។

[66] សាលក្រមក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៣៥។

[67] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨។ អង្គជំនុំជម្រះកត់សម្គាល់ថា វិធានផ្ទៃក្នុងមិនដោះស្រាយឲ្យបានច្បាស់ចំពោះបញ្ហាស្តីពីភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ឬ ការបង្ខិតបង្ខំឡើយ។

៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា "ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបរាងកាយ ឬ ខាងផ្លូវចិត្ត គ្មានតម្លៃជាភស្តុតាងទេ"[68]។

២៣. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពាក្យខ្មែរ "ការបង្ខិតបង្ខំ" ដែលមាននៅក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបកប្រែក្រៅផ្លូវការខុសៗគ្នាជាភាសាអង់គ្លេស និង បារាំង ដោយប្រើពាក្យ *"force", "duress", "coercion" និង "pression", "coercition", "contrainte"*[69]។ ពាក្យពេចន៍នីមួយៗឆ្លុះបញ្ចាំងជាទូទៅអំពីភាពគ្មានឆន្ទៈប្រកបដោយសេរីភាពក្នុងការផ្តល់ចម្លើយ។ ទោះបីអង្គជំនុំជម្រះយល់ឃើញថាការបកប្រែពាក្យថា "ការបង្ខិតបង្ខំ" ត្រឹមត្រូវបំផុតដោយប្រើពាក្យ *"coercion"* ក៏ច្បាប់កម្ពុជាមិនបានកំណត់និយមន័យពាក្យនេះ ហើយក៏មិនបានចាត់ទុកថាវាជាបទល្មើសព្រហ្មទណ្ឌដែរ។ ទោះបីច្បាប់កម្ពុជាចែងថាអំពើទារុណកម្មជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ក៏ច្បាប់នេះមិនចែងអំពីនិយមន័យនៃពាក្យនេះដែរ។ ចំណែកឯក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានចែងយោងជាក់លាក់ណាមួយទៅពាក្យនេះទេ[70]។

២៤. អនុលោមតាមក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក នៅពេលដែលច្បាប់នីតិវិធីកម្ពុជាមិនបានចែងអំពីបញ្ហាជាក់លាក់ណាមួយ ឬមានបញ្ហាពាក់ព័ន្ធនឹងភាពស៊ីសង្វាក់ទៅនឹងវិធាននេះនៅក្នុងបទដ្ឋានអន្តរជាតិ អង្គជំនុំជម្រះអាចស្វែងរកការណែនាំពីវិធាននីតិវិធីដែលមាននៅកម្រិតអន្តរជាតិ[71]។ ហេតុដូច្នេះ

[68] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣២១។ មាត្រា ៣២១ ចែងជាលក្ខណៈទូទៅថា ភស្តុតាងទាំងអស់អាចដាក់ជូនបានដោយសេរី លើកលែងមានបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ។

[69] *សូមមើល* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បកប្រែក្រៅផ្លូវការដោយក្រុមប្រឹក្សាធម្មនុញ្ញ ខែ មីនា ឆ្នាំ ២០១០ មាត្រា ៣៨។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បកប្រែក្រៅផ្លូវការ មាននៅ http://faolex.fao.org/docs/pdf/cam117198.pdf។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ភាសាខ្មែរ-អង់គ្លេស បោះពុម្ពផ្សាយលើកទី ១ (ឆ្នាំ ២០០៨)។

[70] *សូមមើលក្រមព្រហ្មទណ្ឌកម្ពុជា* (២០០៩), មាត្រា ១៨៨ (កំណត់អំពើទារុណកម្មថាជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ), មាត្រា ១៩៣ (កំណត់អំពើទារុណកម្មថាជាបទឧក្រិដ្ឋសង្គ្រាម), មាត្រា ២១០ (កំណត់អំពើទារុណកម្មថាជាបទល្មើសព្រហ្មទណ្ឌ និង ជាស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋដទៃទៀត ដូចជា មនុស្សឃាត ការរំលោភសេពសន្ថវៈ)។

[71] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២(១)។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដែលមាន

អង្គជំនុំជម្រះយោងទៅនីតិវិធីដែលពាក់ព័ន្ធនៅកម្រិតអន្តរជាតិ ដើម្បីបញ្ជាក់ថាតើច្បាប់កម្ពុជាមានភាពស៊ីសង្វាក់ទៅនឹងបទដ្ឋានដែលពាក់ព័ន្ធនៅកម្រិតអន្តរជាតិ ជាពិសេសបទដ្ឋានដែលមានចែងក្នុងអនុសញ្ញាប្រឆាំងទារុណកម្មដែរ ឬ ទេ[72]។

២៥. ការហាមឃាត់អំពើទារុណកម្ម ដែលមានចែងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម[73] ដែលមានការទទួលស្គាល់យ៉ាងទូលំទូលាយដោយសហគមន៍អន្តរជាតិ ត្រូវបានទទួលស្គាល់ថា ជាបទដ្ឋានដាច់ខាតមួយក្នុងច្បាប់អន្តរជាតិ ដែលរដ្ឋទាំងឡាយមិនអាចបំពានបានឡើយ[74]។ តាមរយៈ

---

បញ្ចូលវិសោធនកម្ម ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ជាសាធារណៈនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ អ.វ.ត.ក") មាត្រា ២៣ថ្មី។

[72] អង្គជំនុំតុលាការកំពូលបានសម្រេចថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មអាចអនុវត្តដោយផ្ទាល់បាន ដោយមិនចាំបាច់អនុវត្តច្បាប់ឡើយ ដូច្នេះវាជាផ្នែកមួយនៃច្បាប់កម្ពុជា *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៣៤-៣៥។ ទោះជាមធ្យោបាយណាក៏ដោយ ទាំងសេចក្តីសម្រេចនេះ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា មាត្រា ១៥ គឺជាមូលដ្ឋាននៃការសម្រេចទាំងអស់នោះ*សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៣៨។

[73] សម្រាប់គោលបំណងក្នុងការកំណត់ ថាតើអង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មដែរ ឬ យ៉ាងណា នៅក្នុងពេលជំនុំជម្រះ អង្គជំនុំជម្រះអនុវត្តនិយមន័យនៃអំពើទារុណកម្ម ដូចមានចែងនៅក្នុងអនុសញ្ញាប្រឆាំងទារុណកម្មឆ្នាំ ១៩៨៤ នៅពេលអង្គជំនុំជម្រះខិតខំរក្សាឱ្យបាននូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និង មិនកំណត់ថាតើជនជាប់ចោទបានដឹងអំពីនិយមន័យនៃបទឧក្រិដ្ឋពាក់ព័ន្ធនឹងអំពើទារុណកម្ម នៅពេលប្រព្រឹត្តបទល្មើសដែលរងការចោទប្រកាន់ដែរ ឬ យ៉ាងណានោះទេ។ ដូចគ្នានឹង កាំង ហ្កេកអ៊ាវ ហៅឌុច សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជតក សាលដីកាលើបណ្តឹងសាទុក្ខ, F28, ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២០៥។ អនុលោមតាមមាត្រានៃអនុសញ្ញាប្រឆាំងទារុណកម្ម ទារុណកម្មមានន័យថា "អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬ រងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬ ផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជា ទាញយកព័ត៌មានពីជននោះ ឬ តតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយ ដែលជននោះ ឬ តតិយជនណាម្នាក់បានប្រព្រឹត្ត ឬ សង្ស័យថាបានប្រព្រឹត្ត ឬ បំភិតបំភ័យ ឬ បង្ខិតបង្ខំជននោះ ឬ តតិយជនណាម្នាក់ ឬ ដើម្បីមូលហេតុណាផ្សេងទៀត ដែលផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬ ការរងទុក្ខបង្កដោយមន្ត្រីសាធារណៈ ឬ ជនផ្សេងទៀត តាមការញុះញង់ ឬ ការព្រមព្រៀង ឬ ផ្តើមគំនិតរបស់មន្ត្រីសាធារណៈ ឬ ជនផ្សេងទៀតដែលបំពេញតួនាទីផ្លូវការ។ ពាក្យទារុណកម្មមិនរាប់បញ្ចូលនូវការឈឺចាប់ ឬ រងទុក្ខ ដែលកើតជាប់ ឬ ម្តងម្កាលពីទណ្ឌកម្មត្រឹមត្រូវតាមច្បាប់ឡើយ"។

[74] *បញ្ហាពាក់ព័ន្ធនឹងកាតព្វកិច្ចក្នុងការចោទប្រកាន់ ឬធ្វើបត្យាប័ន (ប្រទេសប៊ែលហ្ស៊ិក ទល់នឹង សេនេហ្គាល់)*, តុលាការយុត្តិធម៌អន្តរជាតិ, សាលក្រម, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២, (របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិឆ្នាំ ២០១២), កថាខណ្ឌ ៩៩។ *រដ្ឋអាជ្ញា* ទល់នឹង *Furundžija*, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, IT-95-17/1-T, សាលក្រម, ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ ("ករណីរបស់ *រដ្ឋអាជ្ញា ទល់នឹង Furundžija*") កថាខណ្ឌ ១៤៤-១៥៧ ("ដោយសារតែសារសំខាន់នៃតម្លៃដែលត្រូវការពារ គោលការណ៍នេះបានវិវត្តក្លាយជាបទដ្ឋានដាច់ខាតមួយ ឬ jus cogens ពោលគឺជាបទដ្ឋានដែលមានលំដាប់ខ្ពស់នៅក្នុង

ការទទួលយកអនុសញ្ញានោះ ប្រទេសកម្ពុជាបានបង្ហាញនូវចេតនារបស់ខ្លួនក្នុងការគោរពតាមបទប្បញ្ញត្តិនៃអនុសញ្ញាប្រឆាំងទារុណកម្ម រួមទាំងមាត្រា ១៥ ផងដែរ។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា មាត្រា ១៥ ដែលជាផ្នែកសំខាន់នៃអនុសញ្ញាប្រឆាំងទារុណកម្ម និង ជាអង្គនៃវិធានសន្ធិសញ្ញាដែលចែងអំពីអំពើទារុណកម្ម គឺជាបទដ្ឋានដាច់ខាតមួយក្នុងច្បាប់អន្តរជាតិ[75]។

---

ឋានៈនៃច្បាប់សន្ធិសញ្ញាអន្តរជាតិ និង វិធានទំនៀមទម្លាប់អន្តរជាតិ"ធម្មតា"ផងដែរ")។ *A និងអ្នកផ្សេងទៀត,* House of Lords, [2005] UKHL 71, Lord Bingham (ដកស្រង់ *Montgomery ទល់មេធាវីការពារក្តី* H M, *Coulter ទល់នឹងមេធាវីការពារក្តី* H M [2003] 1 AC 641), កថាខណ្ឌ ៣៣។ សាលក្រមសាលាដំបូងក្នុងសំណុំរឿង ០០១ កថាខណ្ឌ ៣៥២-៣៥៣។ *សូមមើលផងដែរ* អនុសញ្ញាក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា, ឯកសារអង្គការសហប្រជាជាតិលេខ 18232 ចូលជាធរមាននៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៨០ ("អនុសញ្ញាក្រុងវីយែន") មាត្រា ៥៣, ៦៤ (កំណត់និយមន័យ *jus cogens*) សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤០។ ។

[75] *ករណីរបស់* Othman (Abu Qatada) *ទល់នឹងចក្រភពអង់គ្លេស,* សាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (សំណើលេខ 8139/09), ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២ ("*ករណីរបស់ Othman (Abu Qatada) ទល់នឹងចក្រភពអង់គ្លេស*") កថាខណ្ឌ ២៦៦ ("បទដ្ឋានអន្តរជាតិ ដែលមានតិចតួចពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះ ជាមូលដ្ឋានគ្រឹះសំខាន់ជាងការបដិសេធភ័ស្តុតាងដែលបានដោយការធ្វើទារុណកម្ម។ [...] UNCAT ឆ្លុះបញ្ចាំងអំពីឆន្ទៈច្បាស់លាស់នៃសហគមន៍អន្តរជាតិ ដើម្បីបន្តការពារការហាមឃាត់ដាច់ខាតចំពោះអំពើទារុណកម្ម ដោយចាត់វិធានការមួយចំនួន ដើម្បីលុបបំបាត់ការលើកទឹកចិត្តឱ្យមានអំពើទារុណកម្ម។ សំខាន់ជាងនេះ បទប្បញ្ញត្តិ UNCAT ត្រង់មាត្រា ១៥ ដែលហាមឃាត់ ដែលបញ្ជាក់ន័យស្ទើរតែដាច់ខាត អំពីការទទួលយកភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម។ បទប្បញ្ញត្តិនេះបានកំណត់នូវកាតព្វកិច្ចច្បាស់លាស់មួយ ដើម្បីឱ្យរដ្ឋទាំងឡាយអនុវត្តតាម")។ *ករណីរបស់* Cabrera García *និង* Montiel Flores *ទល់នឹងម៉ិចស៊ិក្វ,* សាលក្រម, IACtHR, ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០ ("*ករណីរបស់ Cabrera García និង Montiel Flores ទល់នឹងម៉ិចស៊ិក្វ*") កថាខណ្ឌ ១៦៥ ("វិធានដែលមិនអនុញ្ញាតឱ្យប្រើភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ឬ ការប្រព្រឹត្តិឃោរឃៅ និង អមនុស្សធម៌ នៅគ្រប់កិច្ចដំណើរការនីតិវិធីតុលាការ (តទៅនេះហៅថា "វិធានបដិសេធភ័ស្តុតាង") ត្រូវបានទទួលស្គាល់ដោយសន្ធិសញ្ញាអន្តរជាតិជាច្រើន និង អង្គការអន្តរជាតិ ដើម្បីការពារសិទ្ធិមនុស្ស ដែលយល់ឃើញថា វិធានបដិសេធភ័ស្តុតាង គឺមានសារៈសំខាន់ក្នុងការហាមឃាត់អំពើបែបនេះ")។ UN Doc. A/HRC/25/60, របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើទារុណកម្ម និង ការប្រព្រឹត្តិឃោរឃៅ អមនុស្សធម៌ ឬ ការបន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម, ឯកសារអង្គការសហប្រជាជាតិ A/HRC/25/60, ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៤ (របាយការណ៍របស់អ្នករាយការណ៍សិទ្ធិមនុស្សអង្គការសហប្រជាជាតិ ឆ្នាំ ២០១៤) ("របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ឆ្នាំ ២០១៤") កថាខណ្ឌ ២២ ("ដោយសារតែការហាមឃាត់អំពើទារុណកម្ម និង ការធ្វើបាបដទៃទៀត មានលក្ខណៈដាច់ខាត និង មិនអាចបំពានបានទៅស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ច្បាប់បានចែងថា វិធានបដិសេធភ័ស្តុតាង ត្រូវតែអនុវត្តដោយគ្មានការលើកលែងទៅនៅក្នុងកាលៈទេសៈណាក៏ដោយ [...]")។ *ដូចគ្នានឹង* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៦៤-៦៥ ("អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា អាចមានរឿងក្តីមួយ

២៦. ក្នុងករណីដែលចម្លើយសារភាពត្រូវបានធ្វើឡើងដោយជនជាប់ចោទ ឬ ដោយតតិយជន តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ការប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាពមកធ្វើជាភ័ស្តុតាងដើម្បីគាំទ្រការចោទប្រកាន់ គឺជាការធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ជំនុំជម្រះក្តីដោយយុត្តិធម៌ ក៏ដូចជាប៉ះពាល់ដល់ប្រយោជន៍យុត្តិធម៌។ តុលាការសិទ្ធិមនុស្សអឺរ៉ុបយល់ឃើញថា ការប្រើប្រាស់ភ័ស្តុតាងបែបនេះនឹងធ្វើឱ្យកិច្ចដំណើរការនីតិវិធីមិនយុត្តិធម៌ លើកលែងតែក្នុងករណីដែលភ័ស្តុតាងនោះត្រូវបានប្រើប្រាស់ប្រឆាំងជនជាប់ចោទនៃអំពើទារុណកម្ម ដើម្បីបញ្ជាក់ថាចម្លើយសារភាពនោះពិតជាត្រូវបានធ្វើឡើងមែន[76]។ តុលាការនោះបានអនុញ្ញាតឱ្យបដិសេធភ័ស្តុតាងណាដែលជនរងគ្រោះនៃអំពើទារុណកម្មគឺជាជនជាប់ចោទ ហើយតតិយជនជាម្ចាស់ប្រភពនៃភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មនោះ[77]។

២៧. នៅក្នុងការបកស្រាយបទប្បញ្ញត្តិស្តីពីសន្ធិសញ្ញា ដូចជាមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម អនុសញ្ញាក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាចែងថា សេចក្តីយោងដំបូងត្រូវសំដៅលើអត្ថន័យធម្មតាចំពោះកម្មវត្ថុ និង គោលបំណងរបស់សន្ធិសញ្ញា។ ក្នុងករណីដែលការបកស្រាយនេះបន្សល់ទុកនូវភាពមិនច្បាស់លាស់ ឬ នាំឱ្យមានផលវិបាកមិនសមហេតុផលណាមួយ គេអាចពិគ្រោះរកចំណុចត្រៀម ឬ មធ្យោបាយបន្ថែមផ្សេងទៀតក្នុងការបកស្រាយនេះ[78]។

---

ចំនួនដែលមានលក្ខណៈកម្រ និងអាចមានករណីចាំបាច់នានា ដែលត្រូវងាកចេញពីវិធានបដិសេធភ័ស្តុតាង ប៉ុន្តែ រឿងក្តីនៅចំពោះមុខនេះពិតណាស់ពុំមែននៅក្នុងចំណោមរឿងក្តីទាំងនោះឡើយ")។

[76] *ករណី Othman (Abu Qatada) ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៦៤ ("រឹតតែសំខាន់ជាងនេះ គ្មានប្រព័ន្ធច្បាប់ណាមួយដែលអាចយកមកសំអាងដើម្បីគាំទ្រដល់ការទទួលយកភ័ស្តុតាងមិនថាគួរឱ្យជឿជាក់ ប្រសិនបើភ័ស្តុតាងនោះបានមកដោយការប្រព្រឹត្តិអំពើព្រៃផ្សៃ គួយ៉ាងដូចជាអំពើទារុណកម្ម។ ដំណើរការជំនុំជម្រះ ជាសរសរទ្រូងនៃនីតិរដ្ឋ។ ភ័ស្តុតាងដែលបានមកដោយអំពើទារុណកម្ម ធ្វើឱ្យខូចខាតដែលមិនអាចជួសជុលវិញបាន ទៅលើដំណើរការនោះ។ ការប្រើភ័ស្តុតាងបែបនេះនឹងប៉ះពាល់ដល់អានុភាពនៃនីតិរដ្ឋ និង ធ្វើឱ្យខូចឈ្មោះតុលាការណាដែលអនុញ្ញាតឱ្យប្រើវា។ ភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ត្រូវបានបដិសេធ ដើម្បីការពារសុចរិតភាពរបស់ដំណើរការជំនុំជម្រះ និង ការពារនីតិរដ្ឋនេះឯង")។

[77] *ករណីរបស់ El Haski ទល់នឹងប្រទេសប៊ែលហ្ស៊ិក សាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (សំណុំរឿងលេខ 649/08)*, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ ("*ករណីរបស់ El Haski ទល់នឹងប្រទេសប៊ែលហ្ស៊ិក*") កថាខណ្ឌ ៨៥។

[78] អនុសញ្ញាក្រុងវីយែន មាត្រា ៣១, ៣២។

## ៥. សំអាងហេតុ

២៨. មុននឹងកំណត់អំពីវិសាលភាពនៃអញ្ញត្រកម្មចំពោះវិធានបដិសេធភ័ស្តុតាងដែលមាននៅក្នុងឃ្លាចុងក្រោយនៃមាត្រា ១៥ ហើយថាតើចំណុចនេះរួមទាំងភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើបាបការបង្ខិតបង្ខំ ឬ ភ័ស្តុតាងក្លាយ ដែលបានមកពីភ័ស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្មនោះ អង្គជំនុំជម្រះជាដំបូងត្រូវពិចារណាទៅលើបញ្ហាពាក់ព័ន្ធមួយចំនួន រួមទាំងបន្ទុក និង បទដ្ឋានស្តីពីការបង្ហាញភ័ស្តុតាង ដើម្បីកំណត់ថា តើការធ្វើទារុណកម្មត្រូវបានប្រើប្រាស់ដើម្បីទទួលបានភ័ស្តុតាងដែរ ឬ យ៉ាងណា និង កំណត់អំពីការប៉ះពាល់ទៅលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ជាពិសេស សិទ្ធិទទួលបានសច្ចធារណ៍និរទោស និងសិទ្ធិក្នុងការបង្ហាញភ័ស្តុតាងដោះបន្ទុក។

### ៥.១ បញ្ហាបឋម

២៩. ជាបញ្ហាដំបូង អង្គជំនុំជម្រះសាលាដំបូងបដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តី នួន ជា ដែលលើកឡើងថា អង្គជំនុំជម្រះគប្បីកម្រិតការសម្រេចរបស់ខ្លួនត្រឹមតែការកំណត់អំពីភាពអាចទទួលយកបាននៃទម្រង់សំណួរដែលមេធាវីការពារក្តីសួរ ដោយផ្អែកលើភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម។ វាស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់អង្គជំនុំជម្រះក្នុងការសម្រេចលើបញ្ហាណាមួយដែលពាក់ព័ន្ធនឹងការជំនុំជម្រះនេះ ជាពិសេសនៅពេលដែលបញ្ហានោះត្រូវបានលើកឡើងជាច្រើនលើកច្រើនសា ហើយអង្គជំនុំជម្រះត្រូវជួបប្រទះនូវបញ្ហានេះនៅក្នុងកិច្ចដំណើរការនីតិវិធីទៅថ្ងៃអនាគត។ ចាប់តាំងពីដើមដំបូងនៃបញ្ហានេះ សហព្រះរាជអាជ្ញា និង មេធាវីការពារក្តី នួន ជា បានលើកឡើង ឬ ប៉ុនប៉ងលើកឡើងនូវភ័ស្តុតាង ដែលអាចបានមកដោយការធ្វើទារុណកម្មពីក្នុងកាលៈទេសៈខុសប្លែកគ្នា ដែលមិនកម្រិតត្រឹមតែកាលៈទេសៈដូចដែលបានលើកឡើងដោយមេធាវីការពារក្តី នួន ជា និង ដែលត្រូវបានសម្រេចក្នុងសេចក្តីសម្រេចនេះនោះទេ[79]។ ហេតុដូច្នេះ ការដោះស្រាយបញ្ហានេះឱ្យបានចប់សព្វគ្រប់រួមគ្នាតែម្តង ជាជាងដោះស្រាយមួយករណីម្តងៗ គឺបានផ្តល់ជាប្រយោជន៍ដល់តុលាការ។ បញ្ហានៅតែមាននៅឡើយ បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលមិនបានដោះស្រាយបញ្ហាភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ដែលទទួល

---

[79] *សូមមើលដូចខាងលើ ត្រង់ផ្នែក ៥.៥.២។*

បានពីទីតាំងផ្សេងៗ ក្រៅពី ស-២១ ហើយមិនដោះស្រាយបញ្ហាមួយចំនួនផ្សេងទៀត រួមទាំង ការវិភាគស៊ីជម្រៅទៅលើអញ្ញត្រកម្មដែលមាននៅក្នុងមាត្រា ១៥។

៣០. អង្គជំនុំជម្រះកត់សម្គាល់ឃើញដែរថា អង្គជំនុំជម្រះបានទទួលស្គាល់ចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ចំនួនជាងប្រាំរយ និង សៀវភៅកំណត់ហេតុរបស់មន្ទីរឃុំឃាំង និង ភ័ស្តុតាងដទៃទៀតដែលអាចមានភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មរួចមកហើយ។ អង្គជំនុំជម្រះបានពិចារណាលើការអនុញ្ញាតឱ្យប្រើប្រាស់ភ័ស្តុតាងទាំងនេះតាមផ្លូវច្បាប់ ដើម្បីវាយតម្លៃថាតើឯកសារទាំងនេះបានបំពេញ ឬ មិនបានបំពេញទៅតាមបទដ្ឋានអប្បបរមានៃភាពពាក់ព័ន្ធ និង ភាពជឿជាក់បាននៃភ័ស្តុតាង (រួមទាំងភាពត្រឹមត្រូវរបស់ភ័ស្តុតាង)[80]។ នៅក្នុងសំណុំរឿង ០០១ និង ០០២/០១ ឯកសារប្រភេទនេះត្រូវបានចាត់ទុកថា ជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុ ដូចជាអត្តសញ្ញាណ និង ចំនួនមនុស្សដែលត្រូវបានចាប់ និង ឃុំខ្លួនក្នុងមន្ទីរសន្តិសុខ។ បញ្ហាចំពោះមុខនៅពេលនេះ គឺថាតើឯកសារទាំងនេះ អាចអនុញ្ញាតឱ្យប្រើបានដែរ ឬ យ៉ាងណាសម្រាប់គោលបំណងនៃការបង្ហាញភ័ស្តុតាងដទៃទៀត បន្ថែមលើភ័ស្តុតាងដែលត្រូវបានទទួលស្គាល់ពីមុនរួចហើយនោះ ហើយប្រសិនបើអាចអនុញ្ញាតឱ្យលើកឡើងបានមែន តើត្រូវធ្វើយ៉ាងដូចម្តេច។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងមិនពិចារណាសាជាថ្មីលើភាពអាចទទួលយកបាននៃឯកសារប្រភេទនេះទេ ប៉ុន្តែ អង្គជំនុំជម្រះនឹងបញ្ជាក់ឱ្យច្បាស់អំពីការប្រើប្រាស់ជាភ័ស្តុតាងដែលត្រូវបានអនុញ្ញាត ដោយសារតែការទទួលយកភ័ស្តុតាងនេះត្រូវអនុលោមទៅតាមច្បាប់[81]។

៣១. ជាបឋម អង្គជំនុំជម្រះត្រូវកំណត់អំពីបទដ្ឋាន និងបន្ទុកក្នុងការបង្ហាញភ័ស្តុតាងដែលអាចអនុវត្តបាន ដើម្បីបញ្ជាក់ថា ភ័ស្តុតាងនោះបានមកដោយការធ្វើទារុណកម្ម។ សម្រាប់គោលបំណងនៃភ័ស្តុតាង កាលណាភ័ស្តុតាងត្រូវបានរកឃើញថាបានមកដោយការធ្វើទារុណកម្ម បញ្ហានឹងត្រូវចោទឡើងទៅលើការប្រើប្រាស់ភ័ស្តុតាងដែលច្បាប់អនុញ្ញាត ដោយពាក់ព័ន្ធជាពិសេសទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

---

[80] ក្នុងការទទួលយកឯកសារទាំងនេះ អង្គជំនុំជម្រះមិនបានផ្អែកលើវា ដើម្បីកំណត់អង្គហេតុនោះទេ។

[81] វិធាន ៨៧(៣)(ឃ)។

## ៥.២ បទដ្ឋាន និង បន្ទុក ក្នុងការបង្ហាញភស្តុតាង

៣២. លើកលែងតែករណីអញ្ញត្រកម្មដែលនឹងលើកយកមកពិនិត្យខាងក្រោម មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មចែងថា ភស្តុតាង "ដែលត្រូវបានរកឃើញ" ថាបានមកដោយការធ្វើទារុណកម្ម មិនត្រូវយកមកប្រើធ្វើជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយទេ។ មាត្រានេះមិនបានចែងពីបទដ្ឋាននៃការបង្ហាញភស្តុតាងពាក់ព័ន្ធ ឬ បញ្ជាក់ថាតើនរណាជាអ្នកត្រូវរកឱ្យឃើញថាភស្តុតាងនោះបានមកដោយការធ្វើទារុណកម្មឡើយ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាបញ្ហាទាំងនេះមានសារសំខាន់ក្នុងការបង្កើតក្របខ័ណ្ឌនីតិវិធីមួយ ដើម្បីវាយតម្លៃឯកសារដែលអាចបានមកដោយការធ្វើទារុណកម្មក្នុងករណីនេះ ហើយអង្គជំនុំជម្រះពិនិត្យលើបញ្ហាទាំងនេះដូចខាងក្រោម[82]។

### ៥.២.១ បទដ្ឋានក្នុងការបង្ហាញភស្តុតាង

៣៣. អង្គជំនុំជម្រះជឿជាក់ថា បទដ្ឋានក្នុងការបង្ហាញភស្តុតាង "ហានិភ័យពិតប្រាកដ" ដែលអនុវត្តដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្តល់នូវប្រសិទ្ធភាពក្នុងការហាមឃាត់ការប្រើប្រាស់ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ដែលមានចែងក្នុងមាត្រា ១៥។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ត្រូវបង្ហាញថាមាន *ហានិភ័យពិតប្រាកដ* ដែលបញ្ជាក់ថា ភស្តុតាងនេះពិតជាបានមកដោយការធ្វើទារុណកម្ម ទើបអាចបដិសេធបាន។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា វាមិនយុត្តិធម៌ទេ ដែលត្រូវដាក់បន្ទុកក្នុងការបង្ហាញភស្តុតាងឱ្យធ្ងន់ជាងនេះទៀត ដោយសារតែ "សំខាន់បំផុតនោះគឺ [...] មានបញ្ហាលំបាកយ៉ាងខ្លាំងក្នុងការរកឱ្យឃើញថាមានអំពើទារុណកម្មដូចការចោទប្រកាន់" ហើយការធ្វើទារុណកម្មច្រើនតែប្រព្រឹត្តឡើងដោយស្ងាត់ៗ ចំណែកឯក្បាលម៉ាស៊ីនរដ្ឋាភិបាលដែលមានភារកិច្ចទប់ស្កាត់កុំឱ្យមានអំពើនេះ ច្រើនតែជាអ្នកឃុបឃិតលាក់បាំងវា[83]។

---

[82] ដូចគ្នានឹង ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ១៦។

[83] *ករណីរបស់ Othman (Abu Qatada) ទល់នឹងចក្រភពអង់គ្លេស* កថាខណ្ឌ ២៧៦។ *ករណីរបស់ El Haski ទល់នឹងប្រទេសប៊ែលហ្ស៊ិក* កថាខណ្ឌ ៨៦, ៨៨។ របាយការណ៍របស់អ្នករាយការណ៍សិទ្ធិមនុស្សអង្គការសហប្រជាជាតិ ឆ្នាំ ២០១៤ កថាខណ្ឌ ៣១។

៣៤. គត្តាដូចគ្នាខាងលើជាច្រើន អាចអនុវត្តបាននៅក្នុងករណីរឿងក្តីបច្ចុប្បន្ននេះ។ ទោះបីជារដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យពុំអាចលាក់បាំងភ័ស្តុតាងនៃការធ្វើទារុណកម្មក្តី[84] ក៏នៅតែមានភ័ស្តុតាងជាច្រើនបង្ហាញថា អំពើទារុណកម្មត្រូវបានអនុវត្តដោយស្វាត់ៗពីឆ្នាំ ១៩៧៥-១៩៧៩។ ការពិចារណាបន្ថែមទៀតលើពេលវេលាដែលកន្លងទៅជាច្រើនទសវត្សរ៍ ចាប់តាំងពីបានភ័ស្តុតាងខាងលើ រឹតតែមានការលំបាកខ្លាំងឡើងក្នុងការរកឱ្យឃើញថា ភ័ស្តុតាងជាក់លាក់ណាមួយ ពិតជាបានមកដោយការធ្វើទារុណកម្ម។ ដោយសារតែបញ្ហាលំបាកទាំងនេះ អង្គជំនុំជម្រះយល់ឃើញថា ការអនុវត្តបទដ្ឋានខ្ពស់ជាងនេះដើម្បី "រកឱ្យឃើញ" ថាចម្លើយសារភាពពិតជាបានមកដោយការធ្វើទារុណ-កម្មនឹងកាន់តែបង្កើនគ្រោះថ្នាក់ដែលថា ភ័ស្តុតាងរបៀបនេះអាចនឹងមិនត្រូវបានលើកឡើងក្នុងពេលជំនុំជំម្រះ និង ធ្វើឱ្យខូចដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី[85]។

៣៥. ហេតុដូច្នេះ អង្គជំនុំជម្រះនឹងពិចារណាលើភ័ស្តុតាងទៅតាមករណីជាក់ស្តែងនីមួយៗ ដើម្បីសម្រេចថាតើមានហានិភ័យពិតប្រាកដដែរ ឬយ៉ាងណា ដែលថាភ័ស្តុតាងបានមកដោយការធ្វើទារុណកម្ម[86]។

### ៥.២.២ បន្ទុកក្នុងការបង្ហាញភ័ស្តុតាង

៣៦. អនុលោមតាមក្របខ័ណ្ឌច្បាប់ អ.វ.ត.ក ទោះជាភាគីមួយអាចជំទាស់ទៅនឹងការប្រើប្រាស់ភ័ស្តុ-តាងដែលគាត់ចោទប្រកាន់ថាបានមកដោយមិនត្រឹមត្រូវក៏ដោយ អង្គជំនុំជម្រះត្រូវវាយតម្លៃជាបឋមថា តើភ័ស្តុតាងបានមកដោយការធ្វើទារុណកម្មដែរឬទេ ដោយនេះជាផ្នែកមួយនៃករណីយកិច្ចរបស់អង្គជំនុំជម្រះក្នុងការធានានូវភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី[87]។ បន្ទាប់ពីអង្គជំនុំ-

---

[84] ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ១៧ (កត់សម្គាល់វិធាន ២១(១) ពាក់ព័ន្ធនឹងចម្លើយសារភាពដែលបានមកដោយស្ថាប័ន អ.វ.ត.ក និង មិនមែនបានមកពីមន្ត្រីរបស់បក្សកុម្មុនីស្តកម្ពុជា កាលពីជាង ៣០ ឆ្នាំមុន)។

[85] *ករណី R ទល់នឹង Oickle*, 2000 SCC 38, 66, តុលាការកំពូលកាណាដា (សំណុំរឿងលេខ 26535)។ *ករណី A និងអ្នកផ្សេងទៀត*, House of Lords, [2005] UKHL 71, ("*ករណី A និងអ្នកផ្សេងទៀត*"), កថាខណ្ឌ ៣៩, *ដកស្រង់លក្ខន្តិកៈក្រុងរ៉ូម*, មាត្រា ៦៩(៧)។

[86] *សូមមើលផងដែរ* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥៦-៥៧។

[87] ទោះបីកំណត់បន្ទុកបឋមលើជនជាប់ចោទក្នុងការបង្ហាញភ័ស្តុតាងស្តីពីការធ្វើទារុណកម្ម ក្នុងករណីដែលបទចោទត្រូវបានសំអាងលើចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្មដែលរងការចោទប្រកាន់ ដែលបានឆ្លើយដាក់ជនជាប់ចោទយ៉ាងណាក្តី តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា តុលាការត្រូវតែរកឱ្យឃើញគ្រប់គ្រាន់ថា មិនមានហានិភ័យពិតប្រាកដ ដែលថាអំពើទារុណ្ណកម្មត្រូវបានប្រើដើម្បីបានភ័ស្តុតាងដែលបានស្នើឡើង និងថា តុលាការមានការទទួលខុសត្រូវដោយស្វ័យប្រវត្តិក្នុង

ជម្រះចេញសេចក្ដីសម្រេចជាបឋមថាមានហានិភ័យពិតប្រាកដមែនដែលថា អំពើទារុណកម្មត្រូវបានប្រើប្រាស់ដើម្បីបានចម្លើយសារភាពនោះ ភាគីណាដែលស្នើការប្រើប្រាស់ភ័ស្តុតាងនោះ អាចជំទាស់ទៅនឹងការសម្រេចជាបឋមនេះ ជាពិសេសបន្ទាប់ពីបង្ហាញពីកាលៈទេសៈជាក់លាក់ផ្សេងៗដែលបដិសេធពីហានិភ័យនោះ[88]។ អង្គជំនុំជម្រះពិចារណាឃើញថា ការដាក់បន្ទុកនេះនឹងអាចកាត់បន្ថយហានិភ័យនៃការប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មដែលច្បាប់មិនអនុញ្ញាតឱ្យប្រើនៅពេលជំនុំជម្រះ។

**៥.២.៣ បទដ្ឋាន និងបន្ទុកក្នុងការបដិសេធ**

៣៧. បើទោះបីជាបានកត់សម្គាល់ថា បទដ្ឋាន និងបន្ទុកក្នុងការបង្ហាញភ័ស្តុតាង មិនទាន់ត្រូវបានដោះស្រាយដាច់ស្រេចនៅកម្រិតអន្តរជាតិក្តី ក៏អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការវាយតម្លៃជាបឋមថាមានអត្ថិភាពនៃហានិភ័យពិតប្រាកដដែលថា ភ័ស្តុតាងបានទទួលមកតាមរយៈការធ្វើទារុណកម្ម អាចត្រូវបានជំទាស់ ដោយបង្ហាញតាមបទដ្ឋានស្តីពីតុល្យភាពនៃភវនីយភាពថា ការធ្វើទារុណកម្មមិនត្រូវបានប្រើប្រាស់ទេ[89]។ ជាក់ស្តែង សំអាងហេតុនេះត្រូវបានចេញសម្រាប់តែស្ថានភាពជាក់លាក់នីមួយៗតែប៉ុណ្ណោះ គឺការទទួលយកចម្លើយពីមន្ទីរសន្តិសុខ ស-២១ ធ្វើជាភ័ស្តុតាងនៅក្នុងសវនាការលើបណ្តឹងសាទុក្ខនៅក្នុងកាលៈទេសៈមួយចំនួននៃសំណុំរឿង ០០២/០១ ប៉ុណ្ណោះ[90]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ថាការលើកឡើងទាក់ទងនឹងបទដ្ឋានក្នុងការបង្ហាញភ័ស្តុតាងជំទាស់ គឺជាការលើកឡើងមិនសំខាន់ប៉ុណ្ណោះ (*obiter dictum*)។

---

ការធានាថា ជនដែលបង្ហាញខ្លួននៅចំពោះមុខខ្លួន ទទួលបានសវនាការប្រកបដោយយុត្តិធម៌ និង ជាពិសេសតុលាការត្រូវបញ្ជាក់ឱ្យបានច្បាស់ថា ភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី មិនត្រូវបានប៉ះពាល់ដោយលក្ខខណ្ឌដែលខ្លួនយកមកសំអាងក្នុងការប្រើប្រាស់ភ័ស្តុតាងនោះ។ *សូមមើលផងដែរ ករណី El Haski ទល់នឹងប្រទេសប៊ែលហ្ស៊ិក* កថាខណ្ឌ ៨៨ និង ៨៩។ ដូចគ្នានឹងដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ១៦។

[88] ម្យ៉ាងវិញទៀត ភ័ស្តុតាងប្រភេទនេះអាចត្រូវអនុញ្ញាតឱ្យប្រើបាន ប្រសិនបើមានការបង្ហាញថា ភ័ស្តុតាងនេះទទួលយកបានដោយប្រើអញ្ញត្រកម្មដែលមានចែងក្នុងមាត្រា ១៥ ។ *សូមមើល ខាងក្រោម* ត្រង់ផ្នែក ៥.៥។

[89] *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៩, ៥៨។

[90] យ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលមិនបានអនុវត្តបទដ្ឋានស្តីពីការបង្ហាញភ័ស្តុតាងជំទាស់នេះចំពោះឯកសារដែលបានស្នើឡើងសម្រាប់សវនាការលើបណ្តឹងសាទុក្ខដែរ *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥៨, ៥៩, ៦៨។

៣៨. អង្គជំនុំជម្រះសាលាដំបូងពុំឃើញមានការគាំទ្រណាមួយ នៅក្នុងយុត្តិសាស្ត្រអន្តរជាតិដើម្បីគាំទ្របទដ្ឋានផ្សេងទៀតសម្រាប់ការបង្ហាញភ័ស្តុតាងជំទាស់ទេ[91]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការអនុវត្តបទដ្ឋានផ្សេងទៀតសម្រាប់ការបង្ហាញភ័ស្តុតាងជំទាស់ នឹងធ្វើឱ្យមានភាពស្មុគស្មាញដោយមិនចាំបាច់ ដល់ការវាយតម្លៃទៅលើភ័ស្តុតាងដែលត្រូវបានចោទប្រកាន់ថាបានមកដោយការធ្វើទារុណកម្ម ដោយសារតែមានបទដ្ឋានផ្សេងៗទៀតនៅដំណាក់កាលវាយតម្លៃបឋមទៅលើការធ្វើទារុណកម្ម នៅពេលដែលមានការស្នើសុំការប្រើប្រាស់ឯកសារ ហើយក្រោយមកទៀត នៅក្នុងការវាយតម្លៃទៅលើបទចោទនៅពេលការពិនិត្យភ័ស្តុតាងបានចប់សព្វគ្រប់។ ដូច្នេះ ក្នុងករណីដែលអង្គជំនុំជម្រះរកឃើញថាមានហានិភ័យពិតប្រាកដដែលថាមានការប្រើប្រាស់ការធ្វើទារុណកម្មដើម្បីទទួលបានភ័ស្តុតាង ប៉ុន្តែ ភាគីស្នើសុំការប្រើប្រាស់ភ័ស្តុតាងនោះ អង្គជំនុំជម្រះនឹងផ្តល់ឱកាសឱ្យភាគីទាំងអស់បង្ហាញភ័ស្តុតាង ឬដាក់សារណាដែលបង្ហាញថាភ័ស្តុតាងនោះមិនត្រូវបានទទួលដោយការធ្វើទារុណកម្មឡើយ។ បន្ទាប់ពីធ្វើការវាយតម្លៃទៅលើគ្រប់កាលៈទេសៈដែលពាក់ព័ន្ធទាំងអស់ អង្គជំនុំជម្រះនឹងកំណត់ថាតើមានហានិភ័យពិតប្រាកដដែលថា ភ័ស្តុតាងនោះត្រូវបានទទួលតាមរយៈការធ្វើទារុណកម្មដែរ ឬទេ។

### ៥.២.៤ ការវាយតម្លៃចុងក្រោយទៅលើភ័ស្តុតាងដោយអំពីទារុណកម្ម

៣៩. ខុសពីករណីផ្សេងទៀតដែលបទដ្ឋានហានិភ័យពិតប្រាកដត្រូវបានអនុវត្ត ជនជាប់ចោទនៅក្នុងករណីនេះ ត្រូវបានចោទប្រកាន់ពីបទទារុណកម្ម។ ហេតុដូច្នេះ អង្គជំនុំជម្រះត្រូវតែកំណត់បទដ្ឋាននៃការបង្ហាញភ័ស្តុតាងផ្សេងពីនេះ និង ខ្ពស់ជាងនេះមួយស្តីពីថាតើទារុណកម្មបានកើតឡើងដែរ ឬយ៉ាងណា[92]។ ហេតុនេះ ការកំណត់ជាបឋមរបស់អង្គជំនុំជម្រះអំពីថាតើមានហានិភ័យពិតប្រាកដ

---

[91] បើទោះជា *ករណី A និងអ្នកផ្សេងទៀត* យល់ឃើញថា បទដ្ឋានដំបូងស្តីពីតុល្យភាពនៃភីរនីយភាព គឺជាការសមស្របក្នុងការបង្ហាញពីការប្រើប្រាស់ការធ្វើទារុណកម្មក្តី ក៏បទដ្ឋាននេះមិនត្រូវបានអនុវត្តក្នុងការជំទាស់ដែរ។

[92] *សូមមើល* នួន ជា និង ខៀវ សំផន សំណុំរឿង 002/19-09-2007/អវតក/អជសង, សាលក្រម, E313, ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២២ ("ជនជាប់ចោទ ត្រូវបានសន្មតថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គាត់មិនទាន់ត្រូវបានរកឃើញ។ សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាង។ ដើម្បីអាចផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះត្រូវតែមានជំនឿ "ដោយលើសពីវិមតិសង្ស័យ" អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីដោះស្រាយភាពមិនស៊ីសង្វាក់គ្នារវាងការថែងខុសគ្នានៅក្នុងសំណៅភាសាផ្សេងៗនៃវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង ដែលបង្ហាញពីបទដ្ឋាន "ដោយលើសពីវិមតិសង្ស័យ" តាមច្បាប់ common law និង ទស្សនាទាន "ជំនឿដោយឥស្សរចិត្ត" (*intime conviction*) តាមច្បាប់ស៊ីវិល (Civil Law) អង្គជំនុំជម្រះ

ដែរ ឬ ទេ ដែលថា ភស្តុតាងបានមកដោយការធ្វើទារុណកម្ម អាចខុសពីសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួន ផ្អែកលើនិយាមសម្រាប់ការផ្តន្ទាទោសចំពោះការចោទប្រកាន់អំពីការធ្វើទារុណកម្ម ដោយពិចារណាទៅលើភស្តុតាងទាំងអស់ដែលមាននៅក្នុងដំណាក់កាលរៀបចំសាលក្រម។ ក្នុងករណីអង្គជំនុំជម្រះរកឃើញថា ការកំណត់នេះធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ភាគីដោយសារតែស្ថានភាពពិសេសនេះ អង្គជំនុំជម្រះអាចបើកសវនាការលើភស្តុតាងឡើងវិញ ដើម្បីអនុញ្ញាតឱ្យមានការតាំងសំណួរបន្ថែម ឬ ដាក់ភស្តុតាងបន្ថែម ដែលត្រូវបានហាមឃាត់កាលពីដំបូង។

## ៥.៣ ការពិចារណាលើការជំនុំជម្រះដោយយុត្តិធម៌

### ៥.៣.១ សច្ចធារណ៍និរទោស

៤០. អង្គជំនុំជម្រះបញ្ជាក់ថា សិទ្ធិសច្ចធារណ៍និរទោសរបស់ជនជាប់ចោទ មិនទាន់អាចអនុញ្ញាតឱ្យកំណត់ជាស្ថាពរទៅលើពិរុទ្ធភាពរបស់ជនជាប់ចោទចំពោះអំពើទារុណកម្មបាននោះទេ។ អង្គជំនុំ-ជម្រះត្រូវរង់ចាំរហូតទាល់តែភស្តុតាងទាំងអស់ត្រូវបានបង្ហាញរួចរាល់សិន ទើបអង្គជំនុំជម្រះអាចសម្រេចជាចុងក្រោយនៅក្នុងសាលក្រម។ អង្គជំនុំជម្រះពិចារណាឃើញថា ការរកឃើញជាបឋមដែលថាមានហានិភ័យពិតប្រាកដថាអំពើទារុណកម្មត្រូវបានប្រព្រឹត្តឡើង ដោយផ្អែកលើការវាយតម្លៃជាបឋមទៅលើភស្តុតាងនានានោះ គឺមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនេះទេ ព្រោះថា អង្គជំនុំជម្រះមិនបានប្រកាសអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ឬ តួនាទីដែលជនជាប់ចោទអាចមាននៅក្នុងការទទួលបានភស្តុតាងនោះនៅឡើយ។ ការសម្រេចបែបនេះគឺជាការចាំបាច់បឋមពាក់ព័ន្ធនឹងភស្តុតាងដើម្បីបំពេញតាមបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងអនុសញ្ញាប្រឆាំងទារុណកម្ម ។

៤១. ទោះបីជាមានភាពជាក់ស្តែង ឬ មានប្រសិទ្ធភាពជាងក្តី អង្គជំនុំជម្រះមិនអាចពន្យារពេលរហូតដល់ចាំសម្រេចរួមលើអង្គសេចក្តី ដើម្បីចាប់ផ្តើមវាយតម្លៃលើឯកសារណាមួយដែលបានមកដោយការធ្វើទារុណកម្ម ដូចដែលសហព្រះរាជអាជ្ញាបានស្នើឡើងបានទេ[93]។ ការស្នើឡើងបែបនេះ គឺ

---

បានប្រើប្រាស់វិធីសាស្ត្ររួមមួយ វាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃភស្តុតាង។ បន្ទាប់ពីបានវាយតម្លៃទៅលើភស្តុតាងដោយមានសំអាងហេតុរួច អង្គជំនុំជម្រះនឹងធ្វើការបកស្រាយវិមតិសង្ស័យដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ")។

[93] សារណារបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២ ("សហព្រះរាជអាជ្ញលើកឡើងថា មានតែវិធីមួយប៉ុណ្ណោះដែលអនុវត្តប្រកបទៅដោយប្រសិទ្ធភាព ក្នុងការដោះស្រាយជាមួយនឹងបញ្ហាភស្តុតាងនេះ គឺថាអង្គជំនុំជម្រះសាលាដំបូងត្រូវរង់ចាំរហូតដល់បញ្ចប់គ្រប់ភស្តុតាងទាំងអស់នៅក្នុងករណីនេះសិន [...]")។

ផ្ទុយទៅនឹងខ្លឹមសារនៃមាត្រា ១៥ ដែលចែងថា ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម "មិនអាចប្រើធ្វើជាភស្តុតាងបានទេទោះក្នុងកិច្ចដំណើរការនីតិវិធីណាក៏ដោយ"។ ខ្លឹមសារនៃមាត្រានេះមិនកម្រិតត្រឹមតែដំណាក់កាលសម្រេចចេញសាលក្រមប៉ុណ្ណោះទេ ប៉ុន្តែ វាមានអានុភាពអនុវត្តដូចគ្នា ក្នុងដំណាក់កាលបង្ហាញភស្តុតាង និង ការតាំងសំណួរទៅសាក្សី ដើម្បីបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនៅក្នុងអំឡុងពេលនៃការជំនុំជម្រះផងដែរ។ លើសពីនេះទៀត ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតឱ្យភាគីប្រើភស្តុតាងដែលអាចបានមកដោយការធ្វើទារុណកម្មនៅក្នុងដំណើរការជំនុំជម្រះទាំងមូលនោះ សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីសវនាការច្បាស់ជារងផលប៉ះពាល់ជាក់ជាមិនខាន។ ការរង់ចាំរហូតដល់ដំណាក់កាលសាលក្រមទើបដកចេញភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មនឹងមិនអាចជួសជុលការខូចខាតនេះបានឡើយ។បើធ្វើដូច្នេះមែនភាគី និងសាធារណ-ជនច្បាស់ជានឹងបានឃើញថាអង្គជំនុំជម្រះពឹងផ្អែកលើភស្តុតាងដែលបានមកដោយអំពើទារុណកម្មធ្វើជាសំអាងដើម្បីបញ្ជាក់ការពិតដែលធ្វើឱ្យការយកភស្តុតាង និង ការប្រើភស្តុតាងប្រភេទនេះនៅក្នុងពេលជំនុំជម្រះ ក្លាយជាការអនុវត្តជាទូទៅ និង នាំឱ្យអង្គជំនុំជម្រះធ្វើការសាកសួរដើម្បីបញ្ជាក់ការពិត។

### ៥.៣.២ សិទ្ធិបង្ហាញភស្តុតាងដោះបន្ទុក

៤២. បន្ទាប់តទៅនេះ អង្គជំនុំជម្រះពិចារណាលើសារណារបស់មេធាវីការពារក្តី នួន ជា ដែលលើកឡើងថា វិធានបដិសេធភស្តុតាង អនុវត្តបានចំពោះតែអាជ្ញាធររដ្ឋ (ក្នុងករណីនេះ គឺសហព្រះរាជអាជ្ញា) ដូច្នេះហើយ មិនអាចបកស្រាយថាអាចអនុវត្តបានចំពោះមេធាវីការពារក្តីនោះទេ ជាពិសេសនៅពេលមេធាវីការពារក្តីស្នើសុំប្រើប្រាស់ភស្តុតាងដែលបានមកដោយអំពើទារុណកម្ម ដោយមេធាវីអះអាងថាជាការដោះបន្ទុក[94]។

៤៣. ផ្ទុយទៅនឹងសារណារបស់មេធាវីការពារក្តី អង្គជំនុំជម្រះពិចារណាឃើញថា អនុសញ្ញាប្រឆាំងទារុណកម្ម មិនកម្រិតការអនុវត្តចំពោះតែអាជ្ញាធររដ្ឋទេ។ ខ្លឹមសារសាមញ្ញនៃមាត្រា ១៥ បញ្ជាក់ថា មាត្រានេះអាចអនុវត្តជាទូទៅ ហើយមិនផ្តល់សញ្ញាណថា មាត្រានេះគួរតែបកស្រាយក្នុងលក្ខណៈកម្រិតបែបនេះនោះទេ។ អ្នកធ្វើសេចក្តីព្រាងអនុសញ្ញាបានបង្កើតករណីអញ្ញត្រកម្មយ៉ាងច្បាស់ ដែលមានវិសាលភាពចង្អៀតសម្រាប់បុគ្គល និង អង្គហេតុចំពោះវិធានបដិសេធភស្តុតាង

[94] សារណារបស់មេធាវីការពារក្តី នួន ជា កថាខណ្ឌ ១៧។

នេះ។ អញ្ញត្រកម្មដែលមានលក្ខណៈចង្អៀតនេះ ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជន ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើទារុណកម្ម។ អញ្ញត្រកម្មនេះត្រូវបានបង្កើតឡើង ដើម្បីចៀសវាងការបកស្រាយវិធានបដិសេធភ័ស្តុតាង ឱ្យរារាំងដល់ការចោទប្រកាន់ចំពោះអ្នក ដែលទទួលខុសត្រូវចំពោះអំពើទារុណកម្ម។ ខ្លឹមសារនៃវិធាននេះមិនមែនសម្រាប់តែសហព្រះរាជ អាជ្ញានោះទេ ហើយការបកស្រាយអញ្ញត្រកម្ម ដោយគ្រាន់តែអានខ្លឹមសារនៃមាត្រានេះ គឺជាការ មិនត្រឹមត្រូវឡើយ។

៤៤. មិនតែប៉ុណ្ណោះ វិធានបដិសេធភ័ស្តុតាងត្រូវតែចាត់ទុកថាជាការបំពេញបន្ថែមទៅលើវិធានទូទៅ និងខ្លឹមសារនៃសន្ធិសញ្ញាដែលហាមឃាត់អំពើទារុណកម្ម។ ដោយសារតែសារសំខាន់នៃការការពារ តម្លៃនេះ ការហាមឃាត់អំពើទារុណកម្មនៅក្នុងច្បាប់អន្តរជាតិ បង្កើតបានជាបទដ្ឋានដាច់ខាត និង ច្បាស់លាស់មួយ[95]។ តុលាការអន្តរជាតិ ដែលដឹងអំពីសារសំខាន់នៃការដាក់អំពើព្រៃផ្សៃឱ្យនៅក្រៅ ច្បាប់ បានទទួលស្គាល់ថា ការហាមឃាត់អំពើទារុណកម្ម អាចអនុវត្តបាននៅកម្រិតរដ្ឋ និងកម្រិត បុគ្គល[96]។

៤៥. លើសពីនេះទៅទៀត តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា "ការទទួលយកភ័ស្តុតាងដែលបាន មកដោយអំពើទារុណកម្ម គឺមិនត្រឹមតែផ្ទុយគ្នាស្រឡះទៅនឹងបទប្បញ្ញត្តិនៃមាត្រា ៦ [របស់អនុ-សញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស] ប៉ុណ្ណោះទេ វាថែមទាំងផ្ទុយទៅនឹងបទដ្ឋានជាមូលដ្ឋានអន្តរជាតិនៃ ការជំនុំជម្រះដោយយុត្តិធម៌" ផងដែរ ហើយថា "វាមិនត្រឹមតែធ្វើឱ្យការជំនុំជម្រះទាំងមូលផ្ទុយនឹង សីលធម៌ និង ខុសច្បាប់ប៉ុណ្ណោះទេ វាថែមទាំងធ្វើឱ្យលទ្ធផលនៃការជំនុំជម្រះមិនអាចយកជាការ

---

[95] *ករណីរបស់ Othman Abu Qatada ទល់នឹងចក្រភពអង់គ្លេស*, កថាខណ្ឌ ២៦៦ ("បទដ្ឋានអន្តរជាតិ ដែលមានតិចតួចពាក់ព័ន្ធ នឹងសិទ្ធិទទួលបានការជំនុំជម្រះ ជាមូលដ្ឋានគ្រឹះសំខាន់ជាងការបដិសេធភ័ស្តុតាងដែលបានដោយការធ្វើទារុណកម្ម)។ *ករណី របស់ Cabrera García និង Montiel Flores ទល់នឹងម៉ិចស៊ីកូ*, កថាខណ្ឌ ១៦៥ ។

[96] *រដ្ឋអាជ្ញា* ទល់នឹង *Furundžija*, កថាខណ្ឌ ១៤៥-១៤៦ ("សហគមន៍អន្តរជាតិ ដោយដឹងអំពីសារសំខាន់នៃការដាក់ឱ្យនៅក្រៅ ច្បាប់ចំពោះអំពើព្រៃផ្សៃ បានសម្រេចបង្ក្រាបអំពើទារុណកម្ម តាមរយៈការអនុវត្តច្បាប់ប្រឆាំងទារុណកម្មនៅកម្រិតរដ្ឋ និង កម្រិតបុគ្គល។ គ្មានចន្លោះប្រហោងផ្នែកច្បាប់ណាមួយ ត្រូវបានអនុញ្ញាតឱ្យមាននោះឡើយ")។ *សូមមើលផងដែរ*ការជំនុំជម្រះ របស់ឧក្រិដ្ឋជនសង្គ្រាមធំៗ នៅចំពោះមុខសាលាក្តីសឹកអន្តរជាតិ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥-១ តុលា ឆ្នាំ ១៩៤៦ វ៉ុល XXII, ទំព័រទី ៤៤៦ ("បទឧក្រិដ្ឋប្រឆាំងនឹងច្បាប់អន្តរជាតិ ត្រូវបានប្រព្រឹត្តឡើងដោយមនុស្ស មិនមែនដោយអង្គភាព ដូច្នេះ ការផ្តន្ទា ទោសបុគ្គលដែលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ អាចជាការពង្រឹងការអនុវត្តច្បាប់អន្តរជាតិ")។

បាន"[97]។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភាពមិនអាចជឿទុកចិត្តជាមូលដ្ឋាននៃភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម មិនមានភាពខុសគ្នាទៅតាមភាគីដែលស្នើឡើងនោះទេ ហើយក៏មិនទៅតាមលក្ខណៈដោះបន្ទុកនៃភ័ស្តុតាងនោះដែរ។ គោលបំណងនៃវិធានបដិសេធភ័ស្តុតាង ដែលនឹងធានាឱ្យទទួលបានលទ្ធផលមួយដែលអាចយកជាការបានដើម្បីជាប្រយោជន៍នៃការជំនុំជម្រះក្តីដោយយុត្តិធម៌នោះនឹងមិនត្រូវបានសម្រេចឡើយ ប្រសិនបើភ័ស្តុតាងនោះត្រូវបានប្រើដោយគ្រប់ភាគី រួមទាំងជនជាប់ចោទផងនោះ។

៤៦. ក្នុងករណីនេះ នួន ជា ត្រូវបានចោទប្រកាន់ថាត្រូវទទួលខុសត្រូវចំពោះអំពើទារុណកម្មដែលបានធ្វើឱ្យប៉ះពាល់ដល់ភ័ស្តុតាងដែលកំពុងពិនិត្យ ហើយបច្ចុប្បន្ននេះ ស្នើសុំការប្រើប្រាស់ភ័ស្តុតាងដដែលនេះ ដែលគាត់អះអាងថាជាភ័ស្តុតាងដោះបន្ទុក។ នេះមិនមែនជាស្ថានភាពសំខាន់ដែលត្រូវបានប្រមើលដឹងនៅពេលដែលអនុសញ្ញានេះត្រូវបានអនុម័តទេ។ អ្នកធ្វើសេចក្តីព្រាងមាត្រា ១៥ នេះផ្តោតលើការប្រព្រឹត្តិបំពានពីសំណាក់អាជ្ញាធររដ្ឋទៅលើជនដែលត្រូវបានឃុំឃាំងក្នុងគោលបំណងយកព័ត៌មាន និង ក្រោយមក ផ្អែកលើភ័ស្តុតាងនោះដើម្បីធ្វើឱ្យមានពិរុទ្ធភាព[98]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះយល់ឃើញថា វិធានបដិសេធភ័ស្តុតាងដែលជាវិធានការសំខាន់ដែលមានក្នុងអនុសញ្ញាប្រឆាំងទារុណកម្ម មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងការហាមឃាត់អំពើទារុណកម្ម ហើយត្រូវតែអនុវត្តលើបុគ្គលផ្សេងៗ (រួមទាំងជនជាប់ចោទក្នុងករណីនេះ) ក៏ដូចជា អាជ្ញាធរក្នុងប្រទេសដែរ។

៤៧. ទោះបីជាមេធាវីការពារក្តី នួន ជា កត់សម្គាល់នូវបទប្បញ្ញត្តិច្បាប់ និង យុត្តិសាស្ត្រពីប្រទេសផ្សេងៗមួយចំនួន (រួមទាំងប្រទេសកម្ពុជា) ដែលពាក់ព័ន្ធនឹងចម្លើយសារភាពក្តី អង្គជំនុំជម្រះមិនទាន់បានរកឃើញករណីណាមួយដែលជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យប្រើភ័ស្តុតាងដែលបានមកដោយអំពើទារុណកម្ម ដោយផ្អែកលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ឬ ផ្អែក

---

[97] *ករណីរបស់* Othman Abu Qatada *ទល់នឹងចក្រភពអង់គ្លេស*, កថាខណ្ឌ ២៦៧។

[98] ឯកសារអង្គការសហប្រជាជាតិ E/CN.4/1314, ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ កិច្ចប្រជុំលើកទី ៣៥ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៧៨ កថាខណ្ឌ ១៣, ២១, ២៩, ៤៣-៤៥។ មានកិច្ចពិភាក្សាបន្តិចបន្តួចពាក់ព័ន្ធនឹងវិធានបដិសេធភ័ស្តុតាង ដែលមានចែងក្នុងមាត្រា ១៣។ *សូមមើល* កថាខណ្ឌ ៨៥-៨៦។

លើហេតុផលផ្សេងទៀតនោះទេ[99]។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ការអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងដែលមិនអាចទុកចិត្តបាន ដែលបានមកតាមមធ្យោបាយមិនស្របច្បាប់ មិនមែនជាប្រយោជន៍នៃសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ។ ជនជាប់ចោទគួរត្រូវបានអនុញ្ញាតឱ្យបង្ហាញភស្តុតាងដែលគាត់អះអាងថាជាភស្តុតាងដោះបន្ទុក ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីទេ[100]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វិធានបដិសេធភស្តុតាងក្នុងមាត្រា ១៥ អនុវត្តបានចំពោះគ្រប់ភាគីទាំងអស់នៅក្នុងករណីនេះ រួមទាំងមេធាវីការពារក្តីរបស់ នួន ជា ផងដែរ និងភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ដែលមេធាវីការពារក្តីអះអាងថាជាភស្តុតាងដោះបន្ទុក។

៤៨. បើទោះជាមិនបានឈានទៅដល់ការសម្រេចចុងក្រោយទៅលើបញ្ហានេះក្តី ក៏អង្គជំនុំជម្រះតុលាការកំពូលទុកបើកចំហរនូវលទ្ធភាពដែលថា "ករណីលើកលែងអាចកើតមាននៅក្នុងកាលៈទេសៈដែលចាំបាច់បំផុត ដោយផ្អែកលើកត្តាជាច្រើនរួមគ្នា ដូចជាប្រភពនៃភស្តុតាង ភាពអាចជឿទុកចិត្តបាន តម្លៃដោះបន្ទុកច្រើនលើសលប់ និងលក្ខណៈពិសេសរបស់វា[...]"។ នៅត្រង់ចំណុចនេះអង្គជំនុំជម្រះតុលាការកំពូលបង្កើតបទដ្ឋានខ្ពស់ខ្លាំងក្នុងការអនុញ្ញាតឱ្យជនជាប់ចោទប្រើប្រាស់ ភស្តុតាងដែលបានមកដោយការប្រើទារុណកម្ម។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយស្របជាមួយនឹងតុលាការអឺរ៉ុបដើម្បីសិទ្ធិមនុស្ស តុលាការអន្តរអាមេរិកដើម្បីសិទ្ធិមនុស្ស និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិផ្នែកទារុណកម្មថា វិធានបដិសេធភស្តុតាងគឺជាកាតព្វកិច្ចដែលមិនអាចលើកលែងបាន។ ដូច្នេះ វិធាននេះអនុវត្តចំពោះគ្រប់ភាគីទាំងអស់នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ រួមទាំងជនជាប់ចោទផងដែរ។ ក្នុងករណីណាក៏ដោយ ផ្អែកទៅលើកាលៈទេសៈទាំងអស់នេះ

---

[99] សូមមើល សារណារបស់ នួន ជា កថាខណ្ឌ ២១ ២២ ២៧។ មេធាវីការពារក្តីរបស់ នួន ជា ក៏ពឹងផ្អែកផងដែរលើករណីរបស់តុលាការជាន់ខ្ពស់នៃប្រទេសណូវែលហ្សេឡង់ ដើម្បីគាំទ្រជំហររបស់ខ្លួន។ ករណីនេះមិនពាក់ព័ន្ធនឹងភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម និង ចម្លើយសារភាពដូចដែលត្រូវបានទទួលយកជាភស្តុតាងរួចហើយនោះទេ។ *សូមមើលករណី R ទល់នឹង Vagaia*, HC AK CRI 2006-092-16228 [2008] NZHC 306, ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៨ កថាខណ្ឌ ១៥ (អាចរកបានត្រង់ F16.1.6)។

[100] ករណីរបស់ *A និងអ្នកផ្សេងទៀត*, កថាខណ្ឌ ៣៩, ៥២ ("គោលការណ៍នៃច្បាប់ common law, បើតាមគំនិតរបស់ខ្ញុំកំណត់ឱ្យបដិសេធភស្តុតាងនៃអំពើទារុណកម្មរបស់តតីយភាគី ដោយចាត់ទុកថាវាថាមិនបានការ មិនយុត្តិធម៌ មានលក្ខណៈវាយប្រហារទៅលើបទដ្ឋានធម្មតានៃមនុស្សជាតិ និងសុជីវធម៌ និងមិនសមស្របតាមគោលការណ៍ ដែលអង្គជំនុំជម្រះកំពុងខិតខំរៀបចំឱ្យមានយុត្តិធម៌នោះឡើយ")។

អង្គជំនុំជម្រះមិនជឿថា ជនជាប់ចោទបានបង្ហាញថា ការមិនអនុញ្ញាតឱ្យប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការប្រើទារុណកម្ម ដូចជាឯកសារដែលរៀបរាប់ដោយសង្ខេបនៅក្នុងចំណុច ៥.៥.២ នោះ នឹងធ្វើឱ្យមាន "យុត្តិនិសេធជាក់ស្តែង"[101]នោះទេ។

## ៥.៤ ការអនុវត្ត និងវិសាលភាពនៃវិធានបដិសេធភ័ស្តុតាង

៤៩. ជាចំណុចបឋម អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "[...] មាត្រា ១៥ ពុំបានកំណត់ជាទូទៅថាត្រូវដកចេញនូវកំណត់ហេតុទាំងមូលជុំវិញការសួរយកចម្លើយពីជនរងគ្រោះនៃការធ្វើទារុណកម្មឡើយ" និងថា "ព័ត៌មានរបស់បុគ្គលផ្សេងទៀតក្រៅពីជនរងគ្រោះនៃការធ្វើទារុណកម្ម" អាចត្រូវបានប្រើប្រាស់"[102]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ព័ត៌មានសត្យានុម័តមួយចំនួន ដែលមាននៅក្នុងចម្លើយសារភាព មិនមែនជាផ្នែកនៃចម្លើយដែលបានមកដោយការធ្វើទារុណកម្មនោះទេ។ ដូច្នេះ វាស្ថិតនៅក្រៅវង្វង់នៃវិធានបដិសេធភ័ស្តុតាងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម។ ភ័ស្តុតាងទាំងនេះ អាចរួមបញ្ចូលទាំងព័ត៌មានពាក់ព័ន្ធនឹងកំណត់ហេតុអំពីអត្តសញ្ញាណរបស់អ្នកជាប់ឃុំ ដែលនឹងត្រូវសួរចម្លើយ កាលបរិច្ឆេទចាប់ខ្លួនគាត់ និង កាលបរិច្ឆេទជាប់ឃុំ និង/ឬ សម្លាប់ ដែលត្រូវបានកត់ត្រាទុកនៅពេលគាត់ចុះឈ្មោះនៅមន្ទីរសន្តិសុខ ឬ នៅពេលចាប់ផ្តើមធ្វើឯកសារដែលមានផ្ទុកចម្លើយសារភាព (ជាទូទៅ សរសេរនៅទំព័រមុខ) ប៉ុន្តែ ព័ត៌មាននោះមិនមែនជាព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពផ្ទាល់នោះទេ[103]។ លើសពីនេះទៀត អង្គជំនុំជម្រះគូសបញ្ជាក់សាជាថ្មីនូវការអនុវត្តដែលមានភាពស៊ីសង្វាក់គ្នារបស់ខ្លួនក្នុងការអនុញ្ញាតឱ្យយោងទៅចំណារដែលចារដោយអ្នកសួរចម្លើយ ឬ ថ្នាក់លើដទៃទៀត នៅលើចម្លើយសារភាព ជាពិសេស នៅពេលពួកគេបញ្ជាក់អំពីចំណាត់ការដែលត្រូវធ្វើ ឬ ចំណាត់ការដែលបានធ្វើរួចហើយ ដោយចំណារទាំងនេះមិនមែនជាផ្នែកមួយនៃ "ចម្លើយសារភាព" ដូចដែលមានចែងក្នុងមាត្រា ១៥ នោះឡើយ[104]។

៥០. ក្រៅពីព័ត៌មានប្រភេទនេះ ក្រុមមេធាវីការពារក្តីបានលើកឡើងនូវមធ្យោបាយពីរ ដែលអាចបកស្រាយវិធានបដិសេធភ័ស្តុតាងថារួមបញ្ចូលទាំងភ័ស្តុតាងដែលមិនមែនបានមកពីការធ្វើទារុណកម្ម

---

[101] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៦៤-៦៥។ សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ខាងលើ កថាខណ្ឌ ២៥។

[102] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៦៨។

[103] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការបញ្ជាក់ថាតើអង្គហេតុទាំងនេះត្រូវបានទទួលមកដោយមានការធ្វើទារុណកម្ម ឬក៏អត់នោះ គឺជាបញ្ហាដែលត្រូវបង្ហាញតាមរយៈភ័ស្តុតាង។ *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៦៨។

[104] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៦៨។

ពោលគឺ ភ័ស្តុតាងដែលទទួលបានមកទោះបីតាមរយៈអំពើឃោរឃៅ អមនុស្សធម៌ ឬ ការបន្ទាបបន្ថោក (ការធ្វើបាប) ឬ ការបង្ខិតបង្ខំដែលមិនបំពេញបាននូវបទដ្ឋាននៃអំពើទារុណកម្ម និងភ័ស្តុតាងដែលកើតចេញពីភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មនោះ។ អង្គជំនុំជម្រះពិនិត្យមើលចំណុចនីមួយៗដូចខាងក្រោម ។

### ៥.៤.១ ភ័ស្តុតាងដែលបានមកដោយការបង្ខិតបង្ខំ ឬ ការធ្វើបាប

៥១. ទោះបីជាមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និង មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងអំពីភ័ស្តុតាងដែលបានមកដោយការបង្ខិតបង្ខំ ដែលអាចត្រូវបានចាត់ទុកថាជាអំពើមួយ ដែលមិនបំពេញលក្ខខណ្ឌអប្បបរមានៃអំពើទារុណកម្ម ក៏ច្បាប់កម្ពុជាមិនចែងដោយជាក់លាក់អំពីថាតើភ័ស្តុតាងដែលទទួលបានដោយការបង្ខិតបង្ខំ ត្រូវអនុលោមទៅតាមវិធានបដិសេធភ័ស្តុតាងឡើយ។

៥២. តាមរយៈពាក្យពេចន៍ក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាហាមមិនឱ្យមានការពឹងផ្អែកទៅលើចម្លើយសារភាពដែលបានមកតាមរយៈការបង្ខិតបង្ខំធ្វើជាភ័ស្តុតាងដាក់ពិរុទ្ធ ប៉ុន្តែមាត្រានេះកម្រិតត្រឹមតែការប្រើប្រាស់ចម្លើយរបស់ជនជាប់ចោទប៉ុណ្ណោះ ហេតុដូច្នេះ វាអាចការពារសិទ្ធិជាសារវ័ន្តរបស់គាត់ក្នុងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង[105]។ ចម្លើយដែលជាបញ្ហាចោទនៅទីនេះគឺមិនពាក់ព័ន្ធនឹងចម្លើយរបស់ជនជាប់ចោទនោះទេ។ ហេតុដូច្នេះ បទប្បញ្ញត្តិដែលពាក់ព័ន្ធជាងនេះនោះគឺមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលចែងថា “ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬ ខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភ័ស្តុតាងទេ”។

៥៣. យោងតាមអង្គជំនុំជម្រះតុលាការកំពូល មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អនុវត្តមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ត្រង់ចំណុចពាក់ព័ន្ធនឹងនីតិវិធីព្រហ្មទណ្ឌនៅកម្ពុជា និងបង្កើតវិធានបដិសេធភ័ស្តុតាងដែលទទួលបានមកតាមរយៈការបង្ខិតបង្ខំ (មិនធ្ងន់ដល់ទារុណកម្មឡើយ)[106]។ អង្គជំនុំជម្រះយល់ឃើញថា បើទោះជាពាក្យពេចន៍នៃមាត្រា ៣២១ មិនមានអញ្ញត្រ-កម្មចំពោះចម្លើយ “ប្រឆាំងជនជាប់ចោទនៃអំពើទារុណកម្ម” ដូចមាត្រា ១៥ នៃអនុសញ្ញាប្រឆាំង

---

[105] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ១៤ (ឆ)។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ ៣៣ និង ៣៨។

[106] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៣១, ៣៥-៣៧។

ទារុណកម្មក្តី ក៏អញ្ញត្រកម្មនៅក្នុងមាត្រា ១៥ "ពុំត្រូវបានលុបបំបាត់ចោលឡើយ"[107]។ នៅក្នុងការអនុវត្តជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលមិនអនុវត្តមាត្រា ៣២១ ចំពោះឯកសារដែលបានស្នើសុំនៅក្នុងសវនាការរបស់អង្គជំនុំជម្រះឡើយ ប៉ុន្តែបានពិនិត្យទៅលើបញ្ហានេះដោយផ្អែកលើមាត្រា ១៥ នៃអនុសញ្ញា ដែលជាការផ្តោតសំខាន់នៃទឡ្ហីករណ៍របស់ភាគីដែរ[108]។

៥៤. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវតែពិនិត្យជារួម ហើយនៅក្នុងបរិបទនៃមាត្រានេះ ដែលរួមមានទាំងវិធានស្តីពីការទទួលយក និងវាយតម្លៃភ័ស្តុតាងផង។ មាត្រា ៣២១ (១) ចែងថា "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភ័ស្តុតាងអាចជូនបានដោយសេរី"។ មាត្រាមួយនេះចែងច្បាស់អំពីអញ្ញត្រកម្មតែមួយចំពោះវិធានទូទៅនេះ (គឺ មាត្រា ៣២១(៤) ស្តីពីការទំនាក់ទំនងរវាងជនជាប់ចោទ និងមេធាវី)។ កថាខណ្ឌទីបីនៃមាត្រា ៣២១ មិនបានហាមឃាត់ការទទួលយកចម្លើយដោយមានការបង្ខិតបង្ខំផ្នែកផ្លូវកាយ និងផ្លូវចិត្តទេ ប៉ុន្តែចែងអំពីការវាយតម្លៃភ័ស្តុតាង ហើយបញ្ជាក់ថា ចម្លើយបែបនេះមិនមានតម្លៃជាភ័ស្តុតាងទេ ដូច្នេះមានន័យថា ផ្នែកនៃបទប្បញ្ញត្តិនេះអនុវត្តនៅដំណាក់កាលវាយតម្លៃភ័ស្តុតាង។ ដោយសារតែច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនចែងអំពីបញ្ហានៃការទទួលភ័ស្តុតាងដែលទទួលបានតាមការបង្ខិតបង្ខំ និង/ឬ ការធ្វើបាប អង្គជំនុំជម្រះស្វែងរកការណែនាំពីវិធាននីតិវិធីនៅកម្រិតអន្តរជាតិ[109]។

៥៥. អង្គជំនុំជម្រះកត់សម្គាល់ថា ពាក្យពេចន៍នៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម មិនបានកំណត់អំពីការបដិសេធភ័ស្តុតាងដែលបានមកដោយ "ការធ្វើបាប"[110] ទេ។ ចម្លើយដែលបានមក

---

[107] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៣៧។

[108] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៣៨។

[109] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១), ច្បាប់ អ.វ.ត.ក មាត្រា ២៣ ថ្មី។

[110] អង្គជំនុំជម្រះកត់សម្គាល់ថា "ការធ្វើបាប" ត្រូវបានយល់ជាទូទៅថាជា "អំពើឃោរឃៅ អមនុស្សធម៌ និងការបន្ទាបបន្ថោកនោះទេ"។ *សូមមើល* របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ឆ្នាំ ២០១៤ កថាខណ្ឌ ១៧, *សូមមើលផងដែរ* UN Doc. CAT/C/GC/2, គណៈកម្មាធិការប្រឆាំងទារុណកម្ម ការអត្ថាធិប្បាយទូទៅ លេខ 2, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៨, កថាខណ្ឌ ៣។ មានលក្ខណៈខុសគ្នាពីរវាងការធ្វើទារុណកម្ម និងការធ្វើបាបផ្សេងទៀត។ មានការយល់ជាទូទៅថា មានភាពខុសគ្នាមួយពាក់ព័ន្ធនឹងការរងទុក្ខពីការធ្វើទារុណកម្មកម្រិតធ្ងន់ និងការប្រព្រឹត្តិដើម្បីបន្ទាបបន្ថោកក្នុងកម្រិតទាបបំផុតមួយ។ *សូមមើល* ករណីប្រទេសអៀកឡង់ ទល់នឹង ចក្រភពអង់គ្លេស សាលក្រមរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ពាក្យបណ្តឹងលេខ 5310/71), កិច្ចប្រជុំពេញអង្គរបស់តុលារសិទ្ធិមនុស្សអឺរ៉ុប, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៧៨, កថាខណ្ឌ ១៦៧។ ករណីរបស់ *Gäfgen* ទល់នឹងប្រទេសអាល្លឺម៉ង់ សាលក្រម (ពាក្យបណ្តឹងលេខ 22978/05) អង្គជំនុំជម្រះជាន់ខ្ពស់របស់តុលាការសិទ្ធិ

ដោយការធ្វើបាប មានចែងក្នុងវិធានបដិសេធភ័ស្តុតាងក្នុងសេចក្តីប្រកាសជាសាកលនៃមហាសន្និបាតរបស់អង្គការសហប្រជាជាតិឆ្នាំ ១៩៧៥ ដែលមានមុនអនុសញ្ញាប្រឆាំងទារុណកម្ម[111] ការលើកឡើងពីការធ្វើបាបនេះ ត្រូវបានលុបចេញពីមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម នៅក្នុងអំឡុងពេលចរចាសន្និសញ្ញាឆ្នាំ ១៩៨៤[112]។ សញ្ញាណនៃពាក្យអំពើឃោរឃៅ ការប្រព្រឹត្តិអមនុស្សធម៌ និង បន្ទាបបន្ថោក ពុំមានកំណត់និយមន័យនៅក្នុងអនុញ្ញាប្រឆាំងទារុណកម្មទេ។

៥៦. មានបទប្បញ្ញត្តិជាច្រើនផ្សេងទៀតនៃអនុសញ្ញាប្រឆាំងទារុណកម្ម ដែលអនុវត្តបានចំពោះអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬ ការប្រព្រឹត្តិបែបបន្ទាបបន្ថោក រួមទាំងកាតព្វកិច្ចការពារកុំឱ្យមាន

---

មនុស្សអឺរ៉ុប, សាលក្រម, ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០ (“*ករណីរបស់ Gäfgen ទល់នឹងប្រទេសអាល្លឺម៉ង់*”) កថាខណ្ឌ ៨៨-៩០។ ការធ្វើទារុណកម្មមានលក្ខណៈពិសេសផងដែរ ដោយសារ វាតម្រូវថា ការធ្វើបាបនោះត្រូវតែមានគោលបំណងជាក់លាក់ណាមួយ (ឧទាហរណ៍ ដើម្បីបានព័ត៌មាន ដើម្បីដាក់ទណ្ឌកម្ម ដើម្បីបង្ខិតបង្ខំ ឬ ដើម្បីមូលហេតុណាផ្សេងដែលផ្អែកលើការរើសអើង)។ សូមមើល ករណី *Ilhan* ទល់នឹងប្រទេស ទួរគី (សំណុំរឿងលេខ 22277/93), តុលាការសិទ្ធិមនុស្សអឺរ៉ុប, សាលក្រម, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០, កថាខណ្ឌ ៨៥ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងទារុណកម្ម មាត្រា ១(១)។

[111] សេចក្តីសម្រេចនៃមហាសន្និបាតអង្គការសហប្រជាជាតិ - សេចក្តីប្រកាសស្តីពីការការពារជនគ្រប់រូបពីការរងអំពើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោកដទៃទៀត ឯកសារអង្គការសហប្រជាជាតិលេខ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧៥ មាត្រា ១២ (“រាល់ចម្លើយទាំងឡាយណា ដែលត្រូវបានរកឃើញថាបានមកដោយសារអំពើទារុណកម្ម ឬការប្រព្រឹត្តិឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោកដទៃទៀត ឬ ការដាក់ទណ្ឌកម្ម អាចមិនត្រូវបានអនុញ្ញាតឱ្យប្រើជាភ័ស្តុតាងប្រឆាំងជនដែលពាក់ព័ន្ធ ឬ ប្រឆាំងជនដទៃទៀតណាម្នាក់នៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយ”។ (មានគូសបញ្ជាក់បន្ថែម)។

[112] ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គមអង្គការសហប្រជាជាតិ កិច្ចប្រជុំលើកទី ៣៤ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៧៨ ឯកសារអង្គការសហប្រជាជាតិ E/CN.4/1285 (ពង្រាងប្រទេសស៊ុយអែត) ។ Herman Burgers និង Hans Danelius, *អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹង ទារុណកម្ម – សៀវភៅកំណត់ហេតុអំពីអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និង ការប្រព្រឹត្តិឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោកដទៃទៀត ឬ ការដាក់ទណ្ឌកម្ម* (Dordrecht: Martinus Nijhoff, 1988), (“Burgers និង Danelius”) ទំព័រទី ១៤៧-១៤៨ (“ខុសពីបទប្បញ្ញត្តិនៃ សេចក្តីប្រកាស [ស្តីពីការការពារលើជនគ្រប់រូប កុំឱ្យរងអំពើទារុណកម្ម និង ការប្រព្រឹត្តិឃោរឃៅ អមនុស្សធម៌ ឬ ការបន្ទាបបន្ថោក] មាត្រា ១៥ នៃអនុសញ្ញាបច្ចុប្បន្នអាចអនុវត្តតែចំពោះការធ្វើទារុណកម្មប៉ុណ្ណោះ”)។ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងទារុណកម្ម –Oxford Commentaries, ទំព័រទី ៥៣៤-៥៣៥ (ដោយកត់សម្គាល់ថា មាត្រា ១៥ យោងតែទៅលើអំពើ ទារុណកម្ម មិនមែនយោងទៅលើការធ្វើបាបនោះទេ ដោយសារតែរដ្ឋទាំងឡាយមិនបានយល់ស្របគ្នាជាឯកច្ឆ័ន្ទលើថាតើរដ្ឋណាមានកាតព្វកិច្ចអនុវត្តរាល់ទម្រង់នៃការធ្វើបាប និង រដ្ឋណាមានកាតព្វកិច្ចអនុវត្តតែចំពោះការធ្វើទារុណកម្ម)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមថា មាត្រា ១៦ នៃអនុសញ្ញាប្រឆាំងទារុណកម្ម មានបញ្ចូលអំពើឃោរឃៅ អំពើអមនុស្សធម៌ និង ការបន្ទាបបន្ថោកទៅជាបួនមាត្រាបន្ថែមទៀត (រួមមានមាត្រា ១០, ១១, ១២, ១៣), ប៉ុន្តែ មិនបានបញ្ចូលក្នុងមាត្រា ១៥ នោះទេ។

ការអនុវត្តបែបនេះផងដែរ។ ក្នុងការកំណត់មធ្យោបាយបង្ការការធ្វើបាប មាត្រា ១៦ បញ្ជាក់ "ជាពិសេស" ចំពោះវិធានការដែលមានចែងក្នុងមាត្រា ១០ ដល់ មាត្រា ១៣ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ប៉ុន្តែមិនបានកម្រិតច្បាស់លាស់លើការអនុវត្តវាចំពោះមាត្រាទាំងនេះនោះទេ[113]។

៥៧. មិនតែប៉ុណ្ណោះ ក្នុងការអនុវត្តជាក់ស្តែង កាតព្វកិច្ចក្នុងការបង្ការការធ្វើបាបនេះត្រួតគ្នា និងមានលក្ខណៈដូចគ្នាទៅនឹងកាតព្វកិច្ចក្នុងការបង្ការអំពើទារុណកម្ម។ ដូចអ្វីដែលបានគូសបញ្ជាក់ដោយគណៈកម្មាធិការប្រឆាំងទារុណកម្មក្នុងឆ្នាំ២០០៧ "ក្នុងការអនុវត្តជាក់ស្តែង និយមន័យនៃលក្ខខណ្ឌតម្រូវជាអបប្បបរមានៃការធ្វើបាប និងអំពើទារុណកម្ម ជាញឹកញាប់ មានភាពមិនច្បាស់លាស់។ បទពិសោធន៍បង្ហាញថា ស្ថានភាពដែលនាំឱ្យមានការធ្វើបាបជាញឹកញាប់បង្កលក្ខណៈឱ្យមានអំពើទារុណកម្ម ដូច្នេះ វិធានដែលតម្រូវដើម្បីបង្ការអំពើទារុណកម្ម ត្រូវតែយកមកអនុវត្តដើម្បីបង្ការការធ្វើបាបផងដែរ"។ ដូច្នេះ គណៈកម្មាធិការប្រឆាំងទារុណកម្ម មិនមែនត្រឹមតែយល់ឃើញថា ការប្រើភស្តុតាងដែលបានមកដោយការធ្វើបាប មិនអាចត្រូវបានអនុញ្ញាតប៉ុណ្ណោះទេ ប៉ុន្តែ ដូចគ្នាដែរ ការហាមឃាត់នេះមិនអាចមើលរំលងបានទេនៅក្នុងអនុសញ្ញានេះ[114]។ ក្រោយមក នៅឆ្នាំ ២០០៨ គណៈកម្មាធិការនេះបានពិចារណាឃើញថា មាត្រា ៣ ដល់ មាត្រា ១៥ ត្រូវតែអនុវត្តជាដាច់ខាតចំពោះអំពើទារុណកម្ម និងការធ្វើបាប[115]។ សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០១៣ មានខ្លឹមសារស្របនឹងទិសដៅនេះ ដោយលើកទឹក

---

[113] អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងទារុណកម្ម, មាត្រា ១៦ ("ក្នុងទឹកដីដែលជាដែនយុត្តាធិការរបស់ខ្លួន រដ្ឋជាភាគីនីមួយៗត្រូវអនុវត្តដើម្បីបង្ការកុំឱ្យមានការប្រព្រឹត្តិអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬ ការបន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្មណាមួយ ដែលមិនបង្កើតបានជាអំពើទារុណកម្មដូចបានកំណត់និយមន័យក្នុងមាត្រា ១ កាលណាអំពើនោះត្រូវបានប្រព្រឹត្តដោយ ឬ តាមរយៈការញុះញង់របស់ ឬ ដោយមានការយល់ព្រម ឬ ទទួលស្គាល់ពីមន្ត្រីសាធារណៈ ឬ អ្នកដទៃទៀតដែលបំពេញភារកិច្ចមន្ត្រីរដ្ឋការ។ ជាពិសេស កាតព្វកិច្ចទាំងនេះមានចែងក្នុងមាត្រា ១០, ១១, ១២ និង ១៣ ត្រូវអនុវត្តជំនួសការយោងទៅអំពើទារុណកម្មដែលយោងទៅទម្រង់ដទៃទៀតនៃអំពើឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម" (មានគូសបញ្ជាក់បន្ថែម))។

[114] មតិទូទៅទី ២ កថាខណ្ឌ ៣, ៦។ របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ឆ្នាំ ២០១៤ កថាខណ្ឌ ២០-២២ (*លើកឡើងអំពី* អំពើទារុណកម្ម និង ការធ្វើបាបផ្សេងទៀតដោយគ្មានភាពខុសគ្នាពាក់ព័ន្ធនឹងមាត្រា ១៥)។

[115] មតិទូទៅទី ២ កថាខណ្ឌ ៦។

ចិត្តឱ្យរដ្ឋទាំងឡាយពង្រីកការហាមឃាត់ការប្រើប្រាស់ភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មរហូតដល់ភ័ស្តុតាងដែលបានមកដោយការធ្វើបាបផងដែរ[116]។

៩៨. បទប្បញ្ញត្តិដែលពាក់ព័ន្ធនៃអនុសញ្ញាអាមេរិក និងអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ហាមប្រាមការប្រើអំពើទារុណកម្ម និងការធ្វើបាប[117]។ មាត្រា ៨(៣) នៃអនុសញ្ញាអាមេរិក ចែងបន្ថែមទៀត និងចែងជាពិសេសថា "ការសារភាពកំហុសណាមួយរបស់ជនជាប់ចោទ ត្រូវតែធ្វើឡើងដោយត្រឹមត្រូវ និងគ្មានការបង្ខិតបង្ខំដោយប្រការណាមួយឡើយ"[118]។

៩៩. ទោះជាយ៉ាងនេះក្តី យុត្តិសាស្ត្រពីតុលាការសិទ្ធិមនុស្សមានភាពមិនស្របគ្នាជាឯកច្ឆ័ន្ទចំពោះថាតើជាវិធានទូទៅ ភ័ស្តុតាងដែលបានមកដោយការធ្វើបាបគួរតែត្រូវបដិសេធនៅរាល់កិច្ចដំណើរការនីតិវិធី ឬ យ៉ាងណា។ គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្សបានសម្រេចថា កាលណារកឃើញថាទម្រង់នៃការបង្ខិតបង្ខំណាមួយបានជ្រៀតជ្រែកដល់ការបញ្ចេញមតិដោយស្ម័គ្រចិត្តរបស់ជនណាម្នាក់ ភ័ស្តុតាងបែបនេះត្រូវតែបដិសេធជាចាំបាច់នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។ តុលាការបញ្ជាក់ថា ចម្លើយសារភាពណាដែលបានមកដោយការបង្ខិតបង្ខំ កម្រជាការពិតណាស់ ព្រោះអ្នកឆ្លើយចេះតែឆ្លើយ ដើម្បីឱ្យគេឈប់ប្រព្រឹត្តអំពើឃោរឃៅ ឬ ធ្វើទារុណកម្មមកលើខ្លួន[119]។

---

[116] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ 67/161 - អំពើទារុណកម្ម និង អំពើឃោរឃៅ អមនុស្សធម៌ ឬ ការបន្ទាបបន្ថោកដទៃទៀត ឬ ការធ្វើទណ្ឌកម្ម UN Doc. No. A/RES/67/161, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៣, កថាខណ្ឌ ១៦ ("ជំរុញយ៉ាងខ្លាំងដល់រដ្ឋទាំងឡាយឱ្យធានាឱ្យបានថា គ្មានចម្លើយសារភាពណាមួយដែលត្រូវបានរកឃើញថាបានមកដោយការធ្វើទារុណកម្ម ត្រូវបានប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយ លើកលែងតែប្រើសម្រាប់ប្រឆាំងជនដែលត្រូវបានចោទប្រកាន់អំពីបទធ្វើទារុណកម្ម ដើម្បីបញ្ជាក់ថា ចម្លើយសារភាពនោះពិតជាត្រូវបានធ្វើឡើងដោយសារធ្វើទារុណកម្មពិតមែនប៉ុណ្ណោះ និង លើកទឹកចិត្តឱ្យរដ្ឋទាំងឡាយពង្រីកការហាមឃាត់ការប្រើចម្លើយសារភាពដែលបានមកដោយអំពើឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការធ្វើទណ្ឌកម្ម [...]")។

[117] *សូមមើល* មាត្រា ៥(២) នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស និង មាត្រា ៣ នៃអនុសញ្ញាអឺរ៉ុបដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលធានាឱ្យបានថា គ្មានជនណាម្នាក់ត្រូវទទួលរងអំពើទារុណកម្ម ឬ អំពើឃោរឃៅ អមនុស្សមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការធ្វើទណ្ឌកម្មនោះឡើយ។

[118] អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ៨(៣)។

[119] សូមប្រៀបធៀបករណី *Cabrera Garcia* និង *Montiel Flores* ទល់នឹងប្រទេសម៉ិចស៊ីកូ, កថាខណ្ឌ ១៦៥-១៦៧។ *សូមមើលផងដែរ* ករណី *Garcia Cruz* និង *Sanchez Silvestre* ទល់នឹងប្រទេសម៉ិចស៊ីកូ សាលក្រម, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣, កថាខណ្ឌ ៥៨។

ខុសពីនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ការទទួលយកភ័ស្តុតាងដែលបានមកដោយការធ្វើបាប ប៉ុន្តែមិនដល់ថ្នាក់ធ្វើទារុណកម្ម អាចរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ តែក្នុងករណីរកឃើញថា ការទទួលស្គាល់ភ័ស្តុតាងដែលបានមកដោយការធ្វើបាបនោះមានផលប៉ះពាល់ដល់ការរកឃើញពិរុទ្ធភាព ឬការកំណត់ទោសលើជនជាប់ចោទប៉ុណ្ណោះ[120]។

៦០. នៅក្នុងយុត្តិសាស្ត្រដែលពាក់ព័ន្ធមួយ សាលាក្តីព្រហ្មទណ្ឌអន្តរជាតិតាំងពីសាលាក្តី Nuremberg បានទទួលស្គាល់ថា ភ័ស្តុតាងដែលបានមកដោយការធ្វើបាប គួរត្រូវបដិសេធចោល[121]។ តុលាការព្រហ្មទណ្ឌអន្តរជាតិ និងសាលាក្តីពិសេស មានវិធានជាក់លាក់ដែលហាមឃាត់ការទទួលយកភ័ស្តុ-តាងដែលបានមកដោយវិធីដែលមានមន្ទិលចំពោះភាពគួរឱ្យជឿជាក់របស់វា ឬ កាលណាការទទួលយកភ័ស្តុតាងនេះ អាចនឹងធ្វើឱ្យអន្តរាយដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី[122]។ វិធាន

---

[120] ករណី *Gäfgen* ទល់នឹងប្រទេសអាល្លឺម៉ង់ កថាខណ្ឌ ១៧៨ ("តុលាការពិចារណាឃើញថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ការការពារប្រកបដោយប្រសិទ្ធភាពនៃការហាមឃាត់ដាច់ខាតតាមមាត្រា ៣ [ការធ្វើទារុណកម្ម និង ការធ្វើបាប] ក្នុងបរិបទនេះ មានបញ្ហាតែក្នុងករណីដែលបង្ហាញថា ការរំលោភបំពានមាត្រា ៣ ប៉ះពាល់ដល់លទ្ធផលនៃកិច្ចដំណើរការនីតិវិធីប្រឆាំងជនជាប់ចោទ ដែលមានផលប៉ះពាល់ដល់ការរកឃើញពិរុទ្ធភាព ឬ ការកំណត់ទោសលើរូបគាត់ប៉ុណ្ណោះ")។ ករណី *El Haski* ទល់នឹងប្រទេសប៊ែលហ្សិក កថាខណ្ឌ ៨៥ ("ការទទួលយកភ័ស្តុតាងដែលបានមកដោយអំពើដែលត្រូវបានចាត់ទុកថាជាការប្រព្រឹត្តិអមនុស្សធម៌ ដែលរំលោភបំពានមាត្រា ៣ ប៉ុន្តែមិនដល់កម្រិតនៃការធ្វើទារុណកម្ម នឹងបំពានមាត្រា ៦ តែក្នុងករណីការជំនុំជម្រះក្តីដោយយុត្តិធម៌ប៉ុណ្ណោះ ប៉ុន្តែតែក្នុងករណីវាបង្ហាញថាការរំលោភបំពាន មាត្រា ៣ នេះមានផលប៉ះពាល់ដល់លទ្ធផលនៃកិច្ចដំណើរការនីតិវិធីប្រឆាំងជនជាប់ចោទ ពោលគឺវាមានផលប៉ះពាល់ទៅលើការរកឃើញអំពីពិរុទ្ធភាព ឬ ការកំណត់ទោសរបស់គាត់")។

[121] សហរដ្ឋអាមេរិក ទល់នឹង *Greifelt* និង អ្នកឯទៀត (ករណី RuSHA), សាលក្រមថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៤៨ បោះពុម្ពឡើងវិញក្នុងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា Nuernberg នៅក្រោមច្បាប់របស់ក្រុមប្រឹក្សាគ្រប់គ្រងលេខ 10, Vol. IV, ទំព័រទី ៨៨ ("ក្នុងអំឡុងនៃសវនាការស្តាប់សាក្សីជាច្រើននាក់ រួមទាំងជនជាប់ចោទមួយចំនួនដែលបានធ្វើលិខិតថ្លែងសច្ចា ដែលត្រូវបានផ្តល់ជូនជាភ័ស្តុតាងដោយព្រះរាជអាជ្ញា បានផ្តល់សក្ខីកម្មថា ពួកគាត់ត្រូវបានគេគម្រាមកំហែង និងថា អ្នកសួរចម្លើយអនុវត្តការបង្ខិតបង្ខំដែលមានលក្ខណៈមិនត្រឹមត្រូវ។ លិខិតថ្លែងសច្ចាដែលត្រូវបានយកជាឯកសារយោងនោះ ត្រូវបានបដិសេធមិនឱ្យប្រើជាភ័ស្តុតាង និង មិនត្រូវបានពិចារណាដោយសាលាក្តីនេះនោះទេ")។

[122] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៦៩(៧) ("ភ័ស្តុតាងដែលបានមកដោយមធ្យោបាយនៃការរំលោភបំពានលើលក្ខន្តិកៈនេះ ឬ សិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ មិនត្រូវទទួលយកបានទេ ប្រសិនបើ៖ (ក) ការរំលោភបំពានមានវិមតិសង្ស័យច្រើនទៅលើភាពគួរឱ្យជឿជាក់នៃភ័ស្តុតាងនោះ ឬ (ខ) ការទទួលយកភ័ស្តុតាងនោះ នឹងនាំឱ្យផ្ទុយទៅនឹង ឬនឹងបង្កភាពអន្តរាយដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី។ តុលាការ ICTY RPE 95 ("គ្មានភ័ស្តុតាងណាមួយត្រូវបានទទួលយកនោះទេ ប្រសិនបើភ័ស្តុតាងនោះបានមកដោយវិធីដែលមានវិមតិសង្ស័យច្រើនទៅលើភាពគួរឱ្យជឿជាក់របស់វា ឬ ប្រសិន

ទាំងនេះអាចអនុវត្តបានចំពោះភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មនិងការធ្វើបាប[123] ប៉ុន្តែត្រូវបានអនុវត្តជាវិធានការការពារផ្នែកនីតិវិធី ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ[124]។ យ៉ាងណាក៏ដោយ វិធានទាំងនេះមិនបានតម្រូវជាស្វ័យប្រវត្តិឱ្យ

---

បើការទទួលយកវា នាំឱ្យផ្ទុយទៅនឹង និងនាំឱ្យអន្តរាយដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី)។ តុលាការ ICTR RPE 95 (ដូចគ្នា)។

[123] ព្រះរាជអាជ្ញា ទល់នឹង *Lubanga,* អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC-01-04-01/06), សាលដីកាសម្រេចលើការបញ្ជាក់ការចោទប្រកាន់ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៧ ("រដ្ឋអាជ្ញា ទល់នឹង *Lubanga*") កថាខណ្ឌ ៨៥ បានដកស្រង់ H-J Behrens, "កិច្ចដំណើរការនីតិវិធីជំនុំជម្រះ" នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ, ការធ្វើលក្ខន្តិកៈក្រុងរ៉ូម, ក្រុងឡាអេ, Kluwer Law international, 1999, ទំព័រទី ៩១៤ កថាខណ្ឌ ៧៦ ("ទម្រង់ខ្លះនៃភាពមិនស្របច្បាប់ ឬ ការរំលោភបំពានលើសិទ្ធិមនុស្ស បង្កើតបានជាគ្រោះថ្នាក់ដែលនាំឱ្យភ័ស្តុតាង ដែលមានជាអាទិ៍ ចម្លើយសារភាព [sic] ដែលបានមកពីជនណាម្នាក់ក្នុងអំឡុងពេលនៃការសួរចម្លើយ មិនអាចមានភាពពិតប្រាកដ ឬ គួរឱ្យទុកចិត្តបានទេ ដោយសារតែភ័ស្តុតាងបែបនេះអាចបានមកដោយសារការបង្ខិតបង្ខំ ដែលកើតចេញពីកាលៈទេសៈនៃការរំលោភបំពាន")។

[124] សាលាក្តីពិសេសបានអនុវត្តបទប្បញ្ញត្តិដែលមានភាពរឹតត្បិតនៅក្នុងវិធាន ៩៥ នៅពេលដែលមានការចោទប្រកាន់ថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានមេធាវី ត្រូវបានបដិសេធ នៅពេលដែលជនជាប់ចោទមិនទទួលបានព័ត៌មានត្រឹមត្រូវអំពីសិទ្ធិរបស់គាត់ និងនៅពេលដែលសាក្សីណាម្នាក់ត្រូវបានទាក់ទងដោយរំលោភបំពានលើដីកាការពារ។ សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង *Delalic* និង អ្នកផ្សេងទៀត, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-96-21-T), សេចក្តីសម្រេចស្តីពីសំណើរបស់ Zdravko Mucic ស្នើសុំបដិសេធភ័ស្តុតាង, ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៧។ រដ្ឋអាជ្ញា ទល់នឹង *Mrskic* និង អ្នកផ្សេងទៀត, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-13/1-T), សេចក្តីសម្រេចពាក់ព័ន្ធនឹងការប្រើចម្លើយសារភាពដែលផ្តល់ដោយជនជាប់ចោទ, ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៦។ រដ្ឋអាជ្ញា ទល់នឹង *Karemera* និង អ្នកផ្សេងទៀត, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-98-44-T), សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំទទួលយកភ័ស្តុតាងនៃការស្តាប់ចម្លើយក្រោយពេលចាប់ខ្លួន Joseph Nzirorera និង Mathieu Ngirumpatse, ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០៧, កថាខណ្ឌ ៣២។ រដ្ឋអាជ្ញា ទល់នឹង *Bagosora* និង អ្នកផ្សេងទៀត, (ICTR-98-41-T), សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំឯកសារជាក់លាក់ក្រោមវិធាន ៨៩(គ), ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៤, កថាខណ្ឌ ២១។ រដ្ឋអាជ្ញា ទល់នឹង *Zigiranyirazo*, (ICTR-2001-73-T), សេចក្តីសម្រេចលើសវនាការ Voir Dire ពាក់ព័ន្ធនឹងជីវប្រវត្តិរបស់ជនជាប់ចោទ, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១៣។ រដ្ឋអាជ្ញា ទល់នឹង *Prlic* និង អ្នកផ្សេងទៀត, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-04-74-T), សេចក្តីសម្រេចលើការទទួលយកភ័ស្តុតាងនៃភ័ស្តុតាងរបស់ Slobodan Praljak ក្នុងសំណុំរឿង Natelic និង Martinovic, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៧, កថាខណ្ឌ ២២-២៣។ រដ្ឋអាជ្ញា ទល់នឹង *Nyiramasuhuko* និង អ្នកផ្សេងទៀត, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-98-42-T), សេចក្តីសម្រេចលើសំណើផ្ទាល់មាត់របស់ Kanyabashi សុំសួរដេញដោល Ntahobali ដោយប្រើចម្លើយសារភាពរបស់ Ntahobali សម្រាប់អ្នកស៊ើបអង្កេតខាងរដ្ឋអាជ្ញា នៅក្នុងខែ កក្កដា ឆ្នាំ ១៩៩៧, ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៦ កថាខណ្ឌ ៨០-៨២។ រដ្ឋអាជ្ញា ទល់នឹង *Kajelijeli,* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-98-44A-

បដិសេធភ័ស្តុតាងដែលបានមកដោយមធ្យោបាយខុសច្បាប់ ហើយតុលាការអន្តរជាតិមួយចំនួនបាន សម្រេចថា ក្នុងការសម្រេចលើភាពអាចទទួលយកបាននៃភ័ស្តុតាងប្រភេទនេះ តុលាការត្រូវតែ រក្សាឱ្យបាននូវតុល្យភាពត្រឹមត្រូវមួយរវាងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ និងផលប្រយោជន៍ សំខាន់របស់សហគមន៍អន្តរជាតិ នៅក្នុងការចោទប្រកាន់ជនទាំងឡាយដែលត្រូវបានចោទប្រកាន់ អំពីអំពើរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ[125]។

៦១. តាមការពិនិត្យទៅលើលិខិតុបករណ៍អន្តរជាតិ និង យុត្តិសាស្ត្រទាំងនេះ មិនឃើញអត្ថិភាពនៃ បទដ្ឋានដែលត្រូវបានទទួលស្គាល់ជាសាកលណាមួយ ដែលអាចពង្រីកការបដិសេធភ័ស្តុតាងដែល បានមកដោយការធ្វើទារុណកម្ម រហូតដល់ភ័ស្តុតាងទាំងអស់ដែលបានមកដោយអំពើឃោរឃៅ អមនុស្សធម៌ និងការបន្ទាបបន្ថោកនោះទេ[126]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម មិនមានវិសាលភាពគ្របដណ្តប់លើភ័ស្តុតាងដែលបានមក ដោយការធ្វើបាបនោះទេ។

៦២. យ៉ាងណាក៏ដោយ អង្គជំនុំជម្រះពិចារណាឃើញថា មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ជាមាត្រាបំពេញទៅលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម។ ទោះបីជាមាត្រា ៣២១ អាច អនុវត្តបានតែក្នុងដំណាក់កាលធ្វើសាលក្រម ដោយទប់ស្កាត់កុំឱ្យពឹងផ្អែកលើចម្លើយដែលបាន

---

T), សេចក្តីសម្រេចលើសំណើរបស់ Kajelijeli ស្នើសុំឱ្យដាក់ពិន័យសមាជិកខាងការិយាល័យរដ្ឋអាជ្ញាពីបទប្រមាថសាលាក្តី (វិធាន ៧៧(គ)), ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០២ កថាខណ្ឌ ១៤។

[125] រដ្ឋអាជ្ញា ទល់នឹង *Lubanga,* កថាខណ្ឌ ៦៩, ៨៤, ៨៦, ៨៩-៩០។ សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង *Brdjanin,* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-99-36), សេចក្តីសម្រេចលើ "ការជំទាស់របស់មេធាវីការពារក្តីក្នុងការទទួលភ័ស្តុតាង", ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០ កថាខណ្ឌ ៦១-៦២ (ក្នុងការកំណត់ថាតើការទទួលយកភ័ស្តុតាង នឹងធ្វើឱ្យ អន្តរាយដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីឬយ៉ាងណានោះ តុលាការត្រូវរក្សាឱ្យបាននូវតុល្យភាពត្រឹមត្រូវមួយរវាងសិទ្ធិជាមូលដ្ឋាន និងផលប្រយោជន៍សំខាន់នៃសហគមន៍អន្តរជាតិ ក្នុងការចោទប្រកាន់ជនណាដែលត្រូវបានចោទប្រកាន់ពីបទរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ)។

[126] អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ផលប៉ះពាល់ជាក់ស្តែងនៃការសម្រេចនេះអាចមិនមានអានុភាពធំធេងទេសម្រាប់ករណីនេះ ដោយសារតែបទដ្ឋាននៃការបង្ហាញភ័ស្តុតាងដែលពាក់ព័ន្ធ។ ប្រសិនបើមានហានិភ័យពិតប្រាកដនៃការធ្វើទារុណកម្ម នោះក៏អាចមានហានិភ័យពិតប្រាកដចំពោះការធ្វើបាបផងដែរ។ មិនតែប៉ុណ្ណោះ ភ័ស្តុតាងភាគច្រើនត្រូវបានប្រមូលមកពីមន្ទីរសន្តិសុខនានា។ ភាគីមិនទាន់បានកំណត់ភ័ស្តុតាងណាមួយ ដែលអាចបានមកដោយការធ្វើបាប ដែលមិនមែនជាការធ្វើទារុណកម្មនោះទេ។

ដោយការបង្ខិតបង្ខំ មាត្រា ១៥ ហាមឃាត់ការប្រើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី។

### ៥.៤.២ ភស្តុតាងក្លាយ

៦៣. បន្ថែមលើភស្តុតាងដែលត្រូវបានកំណត់ថាបានមកដោយការធ្វើទារុណកម្ម ភាគីអាចស្នើសុំឱ្យប្រើភស្តុតាងដទៃទៀត ដែលចេញពីភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ពោលគឺ ភស្តុតាងដែលមិនមែនបានមកដោយអំពើទារុណកម្មដោយផ្ទាល់ ប៉ុន្តែ ជាភស្តុតាងដែលត្រូវបានរកឃើញតាមរយៈភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មនោះ[127]។ ច្បាប់កម្ពុជាមិនបានចែងអំពីការប្រើភស្តុតាងក្លាយនេះទេ ហើយមាត្រា ១៥ លើកឡើងតែអំពីការបដិសេធថា "ឯកសាររាយការណ៍ទាំងឡាយដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម" ប៉ុណ្ណោះ ដោយគ្មានការបញ្ជាក់បន្ថែមផ្សេងទៀតឡើយ។ ហេតុនេះ អង្គជំនុំជម្រះពិចារណាទៅលើសេចក្តីព្រាងនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងយុត្តិសាស្ត្រអន្តរជាតិផ្សេងៗទៀត។

៦៤. សេចក្តីព្រាងដំបូងៗនៃមាត្រា ១៥ បានបង្ហាញថា អ្នកធ្វើសេចក្តីព្រាងគ្មានបំណងបញ្ចូលភស្តុតាងក្លាយទៅក្នុងវិធានបដិសេធភស្តុតាងនោះទេ។ សេចក្តីព្រាងដំបូងនៃមាត្រា ១៥ ដែលដាក់ជូនដោយក្រុមប្រឹក្សាច្បាប់ព្រហ្មទណ្ឌនៃសមាគមន៍អន្តរជាតិ (International Association of Penal Law) បានគាំទ្រដល់ការបដិសេធ "សេចក្តីថ្លែងការណ៍ផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ឬ ចម្លើយសារភាពណា ដែលបានមកដោយការធ្វើទារុណកម្ម ឬ <u>ភស្តុតាងដទៃផ្សេងទៀត ដែលកើតចេញពីភស្តុតាងនោះ</u>"[128]។ ពាក្យពេចន៍ដែលមានគូសបន្ទាត់ពីក្រោមនេះ ត្រូវបានលុបចេញនៅក្នុងសំណៅចុងក្រោយនៃមាត្រា១៥ ដែលបង្ហាញថា អ្នកធ្វើសេចក្តីព្រាងមានចេតនាលុបចោលភស្តុតាងក្លាយ។

---

[127] ឧទាហរណ៍ជាក់ស្តែងមួយនៃភស្តុតាងបែបនេះ គឺថាសាកសពរបស់ជនរងគ្រោះម្នាក់ត្រូវបានប្រទះឃើញ បន្ទាប់ពីអាជ្ញាធរបានធ្វើទារុណកម្មទៅលើជនសង្ស័យ ដើម្បីបានចម្លើយសារភាពពាក់ព័ន្ធនឹងទីតាំងរបស់សាកសពនោះ។ *សូមមើលករណីរបស់ Gäfgen ទល់នឹងអាល្លឺម៉ង់* ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ១៥-១៦, ៧៣-៧៤, ១៧១។

[128] សេចក្តីព្រាងអនុសញ្ញាទប់ស្កាត់ និងបង្ក្រាបអំពើទារុណកម្ម ដែលដាក់ជូនដោយសមាគមអន្តរជាតិនៃក្រុមប្រឹក្សាច្បាប់ ឯកសារអង្គការសហប្រជាជាតិ UN Doc. E/CN.4/NGO/213, ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៧៨ (មានគូសបញ្ជាក់បន្ថែម)។

៦៥. អង្គជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា នៅប្រទេសកម្ពុជា ក៏ដូចជានៅប្រទេសដែលប្រើច្បាប់ស៊ីវិលដទៃទៀតដែរ វិធានទូទៅគឺថា រាល់ភស្តុតាងទាំងអស់អាចទទួលយកបាន[129]។ វិធាននេះជំរុញឱ្យមានការអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងក្លាយ។ យ៉ាងណាក៏ដោយ មិនទាន់មានការឯកភាពគ្នាទាំងស្រុងក្នុងចំណោមប្រភពអន្តរជាតិអំពីថា តើវិធានបដិសេធភស្តុតាងនេះត្រូវអនុវត្តចំពោះភស្តុតាងក្លាយ ហើយបើដូច្នេះ តើត្រូវអនុវត្តក្នុងកាលៈទេសៈណាខ្លះ[130]។

៦៦. តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចលើបញ្ហានេះ នៅក្នុងរឿងក្តីមួយដោយតុលាការនេះបានរកឃើញថា ក្នុងអំឡុងពេលប៉ូលីសធ្វើការស៊ើបអង្កេត ជនជាប់ចោទបានរងការសួរចម្លើយតាមរបៀបមួយប្រភេទដែលត្រូវបានចាត់ទុកថាជាការប្រព្រឹត្តិប្រកបដោយអមនុស្សធម៌ ដែលមិនបំពេញលក្ខខណ្ឌនៃការធ្វើទារុណកម្មឡើយ។ តុលាការនេះបានបដិសេធដាច់ខាតក្នុងការពង្រីកវិធានបដិសេធភស្តុតាងទៅអនុវត្តចំពោះភស្តុតាងក្លាយនោះដែលបានទទួលក្រោមកាលៈទេសៈទាំងនេះ ។ ផ្ទុយទៅវិញ តុលាការនេះបានយល់ឃើញថា ការប្រើភស្តុតាងបែបនេះនឹងនាំឱ្យមានភាពអយុត្តិធម៌ក្នុងកិច្ចដំណើរការនីតិវិធី តែក្នុងករណីវាមានផលប៉ះពាល់ទៅលើការរកឃើញពិរុទ្ធភាព ឬ ការកំណត់ទោសលើជនជាប់ចោទតែប៉ុណ្ណោះ [131]។ កាលណាភស្តុតាងដែលចេញពីការធ្វើបាបបានមកពីប្រភពមួយផ្សេងទៀត ដែលមិនជាប់ពាក់ព័ន្ធនឹងអំពើខុសច្បាប់ តុលាការសិទ្ធិមនុស្សអឺរ៉ុបយល់ឃើញថា កិច្ចដំណើរការនីតិវិធីបែបនេះមានភាពយុត្តិធម៌[132]។

៦៧. តុលាការអន្តរអាមេរិកដើម្បីសិទ្ធិមនុស្សបានសន្និដ្ឋានខុសពីនេះ ដោយលើកឡើងថា "ការបដិសេធភស្តុតាងដែលបានមក ឬ ដែលចេញពីព័ត៌មានដែលបានមកពីការបង្ខិតបង្ខំ មានភាពគ្រប់គ្រាន់ក្នុងការធានាដល់វិធានបដិសេធភស្តុតាង"[133]។ ក្នុងករណីនេះ តុលាការអន្តរអាមេរិកដើម្បីសិទ្ធិមនុស្ស

---

[129] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣២១។ វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[130] ករណី *Gäfgen* ទល់នឹងប្រទេសអាល្លឺម៉ង់ កថាខណ្ឌ ៦៩-៧៤ និង ១៧៤ (តុលាការកត់សម្គាល់ថា ពុំមានការយល់ឃើញដូចគ្នារវាងប្រទេសសមាជិកនៃអនុសញ្ញា តុលាការនៃប្រទេសសមាជិកនីមួយៗ ឬ ស្ថាប័នផ្នែកសិទ្ធិមនុស្សនានា ទៅលើវិសាលភាពនៃការអនុវត្តវិធានបដិសេធភស្តុតាងទេ)។

[131] ករណី *Gäfgen* ទល់នឹងប្រទេសអាល្លឺម៉ង់ កថាខណ្ឌ ១៧៨។ សូមមើលផងដែរ ករណី *Jalloh* ទល់នឹងប្រទេសអាល្លឺម៉ង់ (សំណុំរឿងលេខ 54810/00), អង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប, សាលដីកា, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៦, កថាខណ្ឌ ១០៤-១០៨។

[132] ករណី *Gäfgen* ទល់នឹងប្រទេសអាល្លឺម៉ង់ កថាខណ្ឌ ១៧៨-១៨៧។

[133] ករណី *Cabrera Garcia* និង *Montiel Flores* ទល់នឹងប្រទេសម៉ិចស៊ិកូ កថាខណ្ឌ ១៦៧។

មិនបានរកឃើញកាលៈទេសៈ ដែលអនុវត្តវិធានបដិសេធភស្តុតាងចំពោះភស្តុតាងក្លាយនោះឡើយ ដោយសារតែភស្តុតាងដែលពិភាក្សានោះមានចម្លើយសារភាពដែលផ្តល់ដោយជនរងគ្រោះ ដែលរងគ្រោះដោយផ្ទាល់ពីការធ្វើទារុណកម្ម ឬការធ្វើបាប[134]។ ដោយពិចារណាឃើញថា តុលាការអន្តរ-អាមេរិកដើម្បីសិទ្ធិមនុស្សមិនបានដកស្រង់សំអាងផ្អែកច្បាប់សម្រាប់ការស្នើថា វិធានបដិសេធភស្តុតាងអនុវត្តបាន ទាំងចំពោះភស្តុតាងក្លាយ ហើយថា ដោយសារតែស្ថានភាពនោះមិនតម្រូវឱ្យតុលាការសម្រេចទៅលើចំណុចនេះ ហើយអ្វីដែលលើកឡើងគឺគ្រាន់តែជាការលើកឡើងមិនសំខាន់ (*obiter dictum*) ដូច្នេះអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សេចក្តីសម្រេចរបស់តុលាការអន្តរអាមេរិកដើម្បីសិទ្ធិមនុស្សមិនមែនជាសេចក្តីសម្រេចដែលមានឥទ្ធិពលដោយផ្ទាល់ដល់សម្រេចលើករណីនេះឡើយ។

៦៨. សាលាឧទ្ធរណ៍របស់ប្រទេសអាហ្វ្រិកខាងត្បូងបានសម្រេចផងដែរថា វិធានបដិសេធភស្តុតាងអនុ-វត្តបានទាំងភស្តុតាងដែលកើតចេញពីអំពើទារុណកម្មផងដែរ ដោយបានសន្និដ្ឋានថា "សម្រាប់រយៈពេលយូរអង្វែង ការទទួលយកភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម អាចធ្វើឱ្យសឹករេចរិលដល់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ បើតាមគំនិតខ្ញុំ ប្រយោជន៍សាធារណៈតម្រូវឱ្យបដិសេធភស្តុតាងបែបនេះ មិនថា ភស្តុតាងនេះមាន ឬ មិនមានផលប៉ះពាល់លើការជំនុំជម្រះដោយយុត្តិធម៌នោះទេ"[135]។ ទោះជាយ៉ាងនេះក្តី ចៅក្រមក្នុងរឿងក្តីនោះបានទទួលស្គាល់ថា ភស្តុតាងក្លាយមិនត្រូវបដិសេធចោលដាច់ខាតគ្រប់ពេលនោះទេ ហើយថា ភស្តុតាងបែបនេះអាចទទួលយកបានផងដែរ ប្រសិនបើរកភស្តុតាងនេះបានមកពីប្រភពមួយដែលគ្មានការធ្វើទារុណកម្ម ឬ ប្រសិនបើរកបានដោយចៀសមិនរួច"[136]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា វិធានដាច់ខាតក្នុងការបដិសេធភស្តុតាងដែលកើតចេញពីភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ឬការធ្វើបាប មានលក្ខណៈទូលំទូលាយខ្លាំងពេក។

---

[134] ករណី *Cabrera Garcia* និង *Montiel Flores* ទល់នឹងប្រទេសម៉ិចស៊ិក្ក កថាខណ្ឌ ១៣៤-១៣០។

[135] *Mthembu* ទល់នឹងរដ្ឋ, (379/2007)[2008] ZASCA 51 (ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨), ("*Mthembu* ទល់នឹងរដ្ឋ") កថាខណ្ឌ ៣៦។ ដូចគ្នាដែរ តុលាការស្រុកនៅសហរដ្ឋអាមេរិកបានសម្រេចថា ភស្តុតាងដែលបានពីជនសង្ស័យនៃការបោកគ្រាប់បែកភាវរកម្មនៅតាន់ហ្សានា ដែលបានមកដោយប្រើប្រាស់ "វិធីសាស្ត្រសួរចម្លើយដោយឃោរឃៅ" ហើយមិនមានវត្តមានមេធាវីការពារក្តី ត្រូវបានដកចេញពីដំណើរការនីតិវិធី។ *សូមមើល សហរដ្ឋអាមេរិក ទល់នឹង Ghailani,* 743 F. Supp. 2d 242 (S.D.N.Y. 2010) *conviction aff'd U.S. v. Ghailani et al.*, 733 F.3d 29 (2nd Cir. 2013)។

[136] *Mthembu* ទល់នឹងរដ្ឋ កថាខណ្ឌ ៣៣, ៣៥។

៦៩. ដោយគ្មានយុត្តិសាស្ត្រស៊ីសង្វាក់គ្នាក្នុងកម្រិតអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងការប្រើភ័ស្តុតាងដែលកើតចេញពីការធ្វើទារុណកម្ម មិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ។

៧០. ដោយសារតែមូលហេតុទាំងនេះ អង្គជំនុំជម្រះយល់ឃើញថា ការពង្រីកវិសាលភាពនៃវិធានបដិសេធភ័ស្តុតាង មិនត្រូវបានគាំទ្រដោយសេចក្តីព្រាងដំបូងៗនៃអនុសញ្ញាប្រឆាំងទារុណកម្ម ឬយុត្តិសាស្ត្រដែលមានភាពស៊ីសង្វាក់គ្នានៅកម្រិតអន្តរជាតិនោះទេ។ ការទទួលយកភ័ស្តុតាងទូទៅដើម្បីគាំទ្រដល់ការទទួលយកភ័ស្តុតាងក្លាយ អាចធ្វើទៅបានដរាបណាការប្រើប្រាស់ភ័ស្តុតាងដែលបានស្នើនេះ មិនងាកចេញពីការហាមឃាត់មិនឱ្យប្រើខ្លឹមសារនៃភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មដើម្បីបញ្ជាក់ការពិតឡើយ។ ទោះជាយ៉ាងនេះក៏ដោយ តម្លៃភ័ស្តុតាងនៃភ័ស្តុតាងប្រភេទនេះនឹងត្រូវវាយតម្លៃទៅតាមករណីជាក់ស្តែងនីមួយៗ។ ឥឡូវនេះ អង្គជំនុំជម្រះសូមងាកទៅពិចារណាលើបញ្ហាដែលថា នៅពេលដែលភ័ស្តុតាងត្រូវបានកំណត់ថាបានមកដោយការធ្វើទារុណកម្ម ក៏អាចត្រូវបានប្រើនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីទាំងនេះដែរ។

## ៥.៥ អញ្ញត្រកម្មចំពោះវិធានបដិសេធភ័ស្តុតាងដែលមាននៅក្នុងមាត្រា ១៥

៧១. លើសពីនេះទៀត មាត្រា ១៥ ចែងថា ភ័ស្តុតាងបែបនេះអាចត្រូវបានអនុញ្ញាតឱ្យប្រើបាន "ប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តអំពើទារុណកម្ម ដើម្បីបង្ហាញភ័ស្តុតាងថា ចម្លើយសារភាពនោះពិតជាត្រូវបានធ្វើឡើងមែន"[137]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើកឡើងថា "សំណុំរឿង ០០២/០១ ពុំមានការជាប់ពាក់ព័ន្ធទៅនឹងបទចោទនៃការធ្វើទារុណកម្មឡើយ។ អាស្រ័យហេតុនេះ ករណីលើកលែងតែមួយនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយដែលបានមកពីការធ្វើទារុណកម្ម [...] ពុំអាច

[137] *ករណីរបស់ Othman (Abu Qatada) ទល់នឹងចក្រភពអង់គ្លេស* កថាខណ្ឌ ២៦៦ ("តាមពិត អញ្ញត្រកម្មតែមួយចំពោះការហាមឃាត់ដែលត្រូវបានអនុញ្ញាតដោយមាត្រា ១៥ គឺនៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងជនដែលត្រូវចោទប្រកាន់អំពីបទទារុណកម្ម")។

អនុវត្តបានឡើយ"។ បទចោទនៅក្នុងសំណុំរឿង ០០២/០២ រួមមានការធ្វើទារុណកម្មដែរ ដូច្នេះ ត្រូវធ្វើការវាយតម្លៃទៅលើភស្តុតាងដែលអាចស្ថិតនៅក្នុងអញ្ញត្រកម្មនេះ[138]។

៧២. ពាក្យពេចន៍នៃអញ្ញត្រកម្មនេះបង្ហាញថា ត្រូវបកស្រាយមាត្រានេះក្នុងន័យចង្អៀត[139]។ មាត្រានេះ ចែងអំពីករណីតែមួយប៉ុណ្ណោះ អ្វីដែលត្រូវបង្ហាញគឺថា "ចម្លើយសារភាពនោះពិតជាត្រូវបានធ្វើឡើងមែន"។ ពាក្យពេចន៍នៃមាត្រា ១៥ មិនបានបញ្ជាក់ថា តើចម្លើយសារភាពអាចត្រូវបានប្រើសម្រាប់គោលបំណងអ្វីនោះទេ។ ដោយសារតែភាពមិនច្បាស់លាស់នៃពាក្យពេចន៍នៃមាត្រា ១៥ នេះ អង្គជំនុំជម្រះយោងទៅគោលបំណងនៃមាត្រា ១៥ ទាំងមូល និងប្រវត្តិនៃការធ្វើសេចក្ដីព្រាងនៃមាត្រានេះ[140]។

៧៣. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្ដីព្រាងដំបូងរបស់ក្រុមការងារដែលព្រាងមាត្រា ១៥ មិនបានចែងអំពីលទ្ធភាពណាមួយក្នុងការអនុញ្ញាតឱ្យប្រើភស្តុតាង ដែលបានដោយការធ្វើទារុណកម្មទេ។ នៅក្នុងពេលកំពុងធ្វើសេចក្ដីព្រាងអនុសញ្ញានេះ ពាក្យពេចន៍ត្រូវបានសរសេរបន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការរារាំងនៅក្នុងមាត្រានេះ ដោយអនុញ្ញាតឱ្យប្រើចម្លើយសារភាព ដើម្បីចោទប្រកាន់ជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើទារុណកម្ម[141]។ ប៉ុន្តែ ប្រសិនគេបកស្រាយពាក្យពេចន៍នេះក្នុងន័យទូលាយនោះ វាអាចប៉ះពាល់ដល់វិធានទូទៅ ដែលបដិសេធភស្តុតាងប្រភេទនេះ។ ដូច្នេះ វិសាលភាពនៃការអនុញ្ញាតឱ្យប្រើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ត្រូវតែកំណត់ឱ្យស្របគ្នាទៅនឹងគោលបំណងទូទៅរបស់មាត្រា ១៥ ទាំងមូល។ ចំណុចទាំងនេះរួមមាន ១) គោលនយោបាយសាធារណៈនៃការមិនលើកទឹកចិត្តឱ្យមានការធ្វើទារុណកម្ម ២) ការទប់ស្កាត់ការប្រើភស្តុតាងដែលមិនគួរឱ្យទុកចិត្តបាន ដោយសារវាមិនអាចនាំ

---

[138] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៦៧, *សូមមើលផងដែរ* សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ២៧ ជើងទំព័រ ៥៤។

[139] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៦៧។

[140] ចៅក្រម Fenz ជំទាស់ ពីផ្នែក ៥.៥ នៃសេចក្ដីសម្រេច ដែលសេចក្ដីសម្រេចមានសម្អាងហេតុនឹងចេញនៅពេលក្រោយ។

[141] សេចក្ដីព្រាងដំបូងនៃមាត្រា ១៥ ដែលដាក់ស្នើឡើងដោយប្រទេសស៊ុយអែត មិនបានបញ្ចូលបញ្ហាអញ្ញត្រកម្មទេ។ សូមមើលសេចក្ដីព្រាងដែលស្នើដោយប្រទេស ស៊ុយអែត។

ទៅរកការស្វែងរកពិត ៣) ការរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និង ៤) ការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ រួមទាំងកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ[142]។

៧៤. ទីមួយ មាត្រា ១៥ មានបំណងបញ្ឈប់ការប្រើទារុណកម្មពីសំណាក់អាជ្ញាធររដ្ឋក្នុងគោលបំណងទាញយកព័ត៌មាន។ ដូចដែលអ្នកធ្វើអត្ថាធិប្បាយម្នាក់ដែលបានចូលរួមក្នុងការធ្វើសេចក្តីព្រាងនៃអនុសញ្ញា បានលើកឡើងថា "ប្រសិនបើចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម មិនត្រូវបានអនុញ្ញាតឱ្យប្រើជាភស្តុតាង មូលហេតុសំខាន់មួយសម្រាប់ការប្រើអំពើទារុណកម្មត្រូវបានបដិសេធ ដូច្នេះហើយការហាមឃាត់ការប្រើចម្លើយសារភាពប្រភេទនេះធ្វើជាភស្តុតាងនៅចំពោះមុខតុលាការ អាចមានឥទ្ធិពលដោយប្រយោលក្នុងការទប់ស្កាត់អំពើទារុណកម្ម"[143]។ ទោះជាយ៉ាងនេះក្តី មូលហេតុសំខាន់ក្នុងការបដិសេធភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម គឺការមិនរារាំងមិនឱ្យពឹងផ្អែកលើភស្តុតាងប្រភេទនេះ ដើម្បីទទួលផលប្រយោជន៍ ការធ្វើបែបនេះដើម្បីទប់-ស្កាត់អំពើទារុណកម្ម។ គោលបំណងនេះអាចមិនបានសម្រេចទេ ប្រសិនបើភស្តុតាងបែបនេះត្រូវបានហាមឃាត់ទាំងអស់ ក្នុងការចោទប្រកាន់ជនដែលទទួលខុសត្រូវចំពោះអំពើទារុណកម្មនោះ ដែលការនេះ នឹងទៅជាការជួយដល់បុគ្គលដែលត្រូវបានចោទប្រកាន់ពីបទល្មើសនេះទៅវិញ។ ស្ថានភាពបែបនេះ នឹងមិនធ្វើឱ្យមានការបញ្ឈប់ការប្រើប្រាស់អំពើទារុណកម្មនាពេលអនាគតនោះឡើយ។ ដូចសហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់នៅក្នុងដីកាសម្រេចរបស់ខ្លួនក្នុងករណីនេះថា "ការហាមឃាត់ការប្រើប្រាស់ព័ត៌មានប្រភេទនេះ នៅក្នុងបរិបទនៃករណីនេះ នឹងមិនអាចទប់ស្កាត់ រារាំងមិនឱ្យមានការប្រព្រឹត្តិអំពើទារុណកម្មនោះបានទេ ផ្ទុយទៅវិញវាបែរជាអនុញ្ញាតឱ្យជនដែលរងការចោទប្រកាន់ពីបទទារុណកម្មនេះ អាចប្រើប្រាស់បទប្បញ្ញត្តិច្បាប់នេះ ដើម្បីគេចចេញពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទៅវិញ"[144]។ ហេតុដូច្នេះហើយ អង្គជំនុំជម្រះយល់ឃើញថា

---

142 របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ឆ្នាំ ២០១៤ កថាខណ្ឌ ២១។ Burgers និង Danelius, ទំព័រ ១៤៨ ("វិធានដែលមានចែងក្នុងមាត្រា ១៥ មើលទៅទំនងជាផ្អែកលើការពិចារណាចំនួនពីរខុសគ្នា។ ដំបូង វាបង្ហាញឱ្យឃើញច្បាស់ថា ចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម ជារឿយៗគឺជាចម្លើយសារភាពដែលមិនអាចទុកចិត្តបាន និងអាចផ្ទុយទៅនឹងគោលការណ៍នៃ "ការជំនុំជម្រះក្តីដោយយុត្តិធម៌" ប្រសិនបើប្រើប្រាស់ចម្លើយសារភាពបែបនេះធ្វើជាភស្តុតាងនៅចំពោះតុលាការ")។

143 Burgers និង Danelius, ទំព័រ ១៤៨។

144 ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ២៤។

ការអនុញ្ញាតឱ្យប្រើព័ត៌មានជាក់លាក់មួយចំនួន ដើម្បីប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម គឺមិនផ្ទុយទៅនឹងគោលបំណងទូទៅនៃមាត្រា ១៥ នោះទេ។

៧៥. ទីពីរ វិធានបដិសេធភស្តុតាងមានបំណងការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយក្នុងចំណោមនោះគឺការទប់ស្កាត់ការប្រើភស្តុតាងដែលមិនអាចទុកចិត្តបាន។ រីតែច្បាស់ជាងនេះគឺថា នេះជាយន្តការមួយដើម្បីទប់ស្កាត់ការប្រើចម្លើយសារភាពដែលធ្វើឡើងដោយជនជាប់ចោទ ឬ ដោយអ្នកដទៃដោយការធ្វើទារុណកម្ម ធ្វើជាភស្តុតាងបញ្ជាក់ពីសច្ចភាពនៃចម្លើយសារភាព ឬ បញ្ហាដទៃទៀតដែលអះអាងនៅក្នុងចម្លើយសារភាពនោះ ព្រោះថានៅក្នុងកាលៈទេសៈនេះ ភស្តុតាងនេះមិនអាចទុកចិត្តបានទេ[145]។ អង្គជំនុំជម្រះយល់ឃើញថា ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម អាចត្រូវបានអនុញ្ញាតឱ្យប្រើដើម្បីបញ្ជាក់អង្គហេតុ ជាជាងប្រើដើម្បីបញ្ជាក់សច្ចភាពនៃចម្លើយសារភាពនោះ ប៉ុន្តែប្រើបានតែក្នុងគោលបំណងកំណត់ថាតើមានអំពើអ្វីបានកើតឡើង ផ្អែកលើ អង្គហេតុដែលថា ចម្លើយសារភាពនោះត្រូវបានធ្វើឡើង។ ភាពគួរឱ្យជឿទុកចិត្តបាននៃព័ត៌មានដែលមាននៅក្នុងភស្តុតាងដែលបានដោយការធ្វើទារុណកម្មមិនត្រូវបានប៉ះពាល់ទេ ប្រសិនបើការប្រើវាមានកម្រិតបែបនេះនោះ[146]។ ឧទាហរណ៍ នៅពេលដែលព័ត៌មានត្រូវបានបង្ហាញទៅអ្នកសួរចម្លើយ ដោយសារចម្លើយសារភាពមួយត្រូវបាន

---

[145] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រទី ៧-៩។ ឯកសារ E74 ទំព័រទី ៣។ ឯកសារ E185 កថាខណ្ឌ ២១។ *សូមមើលផងដែរ* Burgers និង Danelius, ទំព័រ ១៤៨ (នៅពេលភស្តុតាងប្រភេទនេះ ត្រូវបានប្រើប្រឆាំងជនជាប់ចោទ, "គោលបំណងរបស់វា គឺមិនមែនដើម្បីបញ្ជាក់ថា ចម្លើយសារភាពនោះជាចម្លើយសារភាពពិតនោះទេ។ គោលបំណងរបស់វា គឺដើម្បីបញ្ជាក់ថា ចម្លើយសារភាពជាក់លាក់មួយត្រូវបានធ្វើឡើងដោយមានអំពើទារុណកម្ម [...]")។ មហាសន្និបាតអង្គការសហប្រជាជាតិ, អំពើទារុណកម្ម និង ការប្រព្រឹត្តិឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោកដទៃទៀត, ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ ឯកសារអង្គការសហប្រជាជាតិ UN Doc. A/61/259, កថាខណ្ឌ ៤៥។ *សូមមើលផងដែរ* លក្ខន្តិកៈក្រុងរ៉ូម, មាត្រា ៦៩(៧) ដែលហាមឃាត់ការទទួលយកភស្តុតាង ដែលបានមកដោយមធ្យោបាយរំលោភបំពានទៅលើលក្ខន្តិកៈក្រុងរ៉ូម ឬ សិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិ ប្រសិនបើ "(ក) ការរំលោភបំពាននោះបង្ហាញនូវវិមតិសង្ស័យគ្រប់គ្រាន់លើភាពគួរឱ្យជឿទុកចិត្តបាននៃភស្តុតាង ឬ ខ) ការទទួលយកភស្តុតាងនេះ អាចផ្ទុយ និង អាចធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី"។

[146] ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រទី ១០៨ (ប្រធាន៖ "អង្គជំនុំជម្រះនៅតែរក្សាជំហររបស់ខ្លួនយ៉ាងម៉ឺងម៉ាត់ថា អង្គជំនុំជម្រះនឹងនៅតែគោរពតាមអនុសញ្ញាប្រឆាំងទារុណកម្មជានិច្ច។ [...] និង នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យភាគីយោងទៅលើខ្លឹមសារនៃចម្លើយសារភាពណាមួយ ដែលបានមកដោយការធ្វើទារុណកម្មដោយសារតែខ្លឹមសារនៃចម្លើយសារភាពនោះ គឺបានមកដោយសារការធ្វើទារុណកម្ម និង ប្រសិនបើភាគីចង់យោងទៅចំណារដទៃទៀត ឬ កាលបរិច្ឆេទនៅលើចម្លើយសារភាព ភាគីត្រូវបានអនុញ្ញាតឱ្យធ្វើដូច្នេះបាន")។

ធ្វើឡើងដោយបុគ្គលដែលត្រូវរងអំពើទារុណកម្ម ការបង្ហាញព័ត៌មានបែបនេះគឺជាអង្គហេតុមួយ ដែលកើតមានដាច់ដោយឡែកពីសច្ចភាពនៃចម្លើយសារភាពនោះ។ អង្គហេតុប្រភេទនេះ អាចត្រូវបានប្រើជាភស្តុតាងនៃចំណាត់ការមួយដែលបានធ្វើឡើង ក្រោយពីមានចម្លើយសារភាពមួយ ដូចជាភស្តុតាងនៃការចាប់ខ្លួនមនុស្សបន្ថែមទៀត ដោយសារតែការបង្ហាញឈ្មោះ ឬ គោលនយោបាយ ឬ ដំណើរការបោសសម្អាត។ តាមរយៈការដាក់កំហិតលើការអនុញ្ញាតឱ្យប្រើភស្តុតាងប្រភេទនេះតាមបែបនេះ កង្វល់អំពីការមិនទុកចិត្តបាននៃភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មត្រូវបានកាត់បន្ថយ។

៧៦. ទីបី វិធានបដិសេធភស្តុតាង ក៏មានបំណងថែរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី តាមរយៈការទប់ស្កាត់មិនឱ្យអង្គជំនុំជម្រះបន្សល់កេរដំណែលណាមួយផ្នែកតុលាការ ដែលជិតដាមទៅដោយការប្រព្រឹត្តិគួរឱ្យស្អប់ខ្ពើមនៅក្នុងដំណើរការនៃការទាញយកភស្តុតាងនោះ[147]។ ទោះជាយ៉ាងនេះក្តីក៏បញ្ហានេះត្រូវតែបានពិចារណារួមគ្នា ជាមួយនឹងសេចក្តីត្រូវការក្នុងការធានាភាពអាចរកបាននូវ ភស្តុតាង ដើម្បីចោទប្រកាន់ជនដែលត្រូវបានចោទប្រកាន់ចំពោះអំពើទារុណកម្ម។ អង្គជំនុំជម្រះយល់ឃើញថា ការកំហិតទៅលើការប្រើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មដូចដែលរំពឹងទុក មិនមែនមានន័យថាជាការផ្តល់ភាពស្របច្បាប់ដល់ការធ្វើទារុណកម្មនោះឡើយ។ ផ្ទុយទៅវិញ វាអនុញ្ញាតឱ្យមានការវាយតម្លៃពេញលេញមួយទៅលើអំពើដែលរងការចោទប្រកាន់នៅក្នុងករណីនេះ។ ដោយសារតែមានការកំហិតទៅលើការប្រើភស្តុតាងបែបនេះ ភស្តុតាងនេះនឹងជួយអង្គជំនុំជម្រះក្នុងការស្វែងរកការពិត និងបង្ហាញឱ្យឃើញនូវការប្រព្រឹត្តិអាក្រក់ និងអមនុស្សធម៌ ប្រសិនបើកើតមានមែន អនុលោមតាមកាតព្វកិច្ចដែលកំណត់នៅក្នុង អនុសញ្ញាប្រឆាំងទារុណកម្ម[148]។ ហេតុដូច្នេះ នៅក្នុងករណីនេះ តម្រូវការចាំបាច់ក្នុងការធានាសុចរិតភាព

---

[147] ករណីរបស់ *A និង* អ្នកដទៃ កថាខណ្ឌ ៣៩ (*កត់សម្គាល់* ការជំទាស់របស់អ្នកប្តឹងឧទ្ធរណ៍ ដែលអនុញ្ញាតឱ្យប្រើចម្លើយសារភាពដែលបានដោយការធ្វើទារុណកម្ម នឹងប៉ះពាល់ដល់សិទ្ធិភាគី និង ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និង ធ្វើឱ្យភ្ញាក់ផ្អើលដល់សម្បជញ្ញៈតុលាការ និង រំលោភបំពាន ឬ ធ្វើឱ្យអាប់អន់ដល់កិច្ចដំណើរការនីតិវិធី និង ធ្វើឱ្យរដ្ឋជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តខុសសីលធម៌")។ លក្ខន្តិកៈក្រុងរ៉ូម, មាត្រា ៦៩(៧) (ការហាមឃាត់ការប្រើភស្តុតាងដែលបានមកដោយការរំលោភសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដែលវិមតិសង្ស័យគ្រប់គ្រាន់នៃករណីរំលោភបំពាននោះទៅលើភាពគួរឱ្យជឿជាក់នៃភស្តុតាង ឬ ភាពអាចទទួលយកបាននៃភស្តុតាង បណ្តាលឱ្យផ្ទុយទៅនឹងសីលធម៌ និង ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី)។

148 សូមមើល ឧទាហរណ៍ UNCAT, មាត្រា ៥, ១២។

នៃកិច្ចដំណើរការនីតិវិធី មិនប្រឆាំងដល់ការហាមឃាត់ទាំងស្រុងលើការប្រើភ័ស្តុតាងដែលបាន ដោយការធ្វើទារុណកម្ម នៅពេលដែលអង្គជំនុំជម្រះត្រូវធ្វើការកំណត់អំពីការទទួលខុសត្រូវចំពោះ អំពើទារុណកម្មនោះទេ។

៧៧. ទីបួន យុត្តិសាស្ត្រអន្តរជាតិស្ទើរតែទាំងអស់ ដែលត្រូវបានដកស្រង់ដោយភាគី ហើយដែលអង្គជំនុំជម្រះបានពិចារណានៅក្នុងសេចក្តីសម្រេចនេះ សុទ្ធតែកើតឡើង នៅពេលដែលជនជាប់ចោទការពារខ្លួនប្រឆាំងនឹងការចោទប្រកាន់ ដែលមាននៅក្នុងចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម។ នៅពេលដែលជនជាប់ចោទខ្លួនឯង ត្រូវគេបង្ខិតបង្ខំឱ្យឆ្លើយសារភាព ពេលនោះមានបញ្ហាជាច្រើនពាក់ព័ន្ធនឹងការជំនុំជម្រះដោយយុត្តិធម៌ និង ដំណើរត្រឹមត្រូវតាមផ្លូវតុលាការ។ ដូចគ្នានេះដែរ នៅពេលណាចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្មរបស់តតិយជនដែលបានឆ្លើយដាក់ជនជាប់ចោទត្រូវបានបង្ហាញធ្វើជាភ័ស្តុតាងបញ្ជាក់អំពីពិរុទ្ធភាព ជនជាប់ចោទមានមធ្យោបាយតិចតួចក្នុងការតតាំងទៅនឹងភ័ស្តុតាងនោះ។ ដោយសារតែភាពមិនគួរឱ្យជឿជាក់បានទៅលើចម្លើយសារភាពប្រភេទនេះ ទើបធ្វើឱ្យតុលាការមិនពិចារណាទៅលើសច្ចភាពនៃចម្លើយសារភាពនោះទេ។ ប៉ុន្តែ ដូចបានគូសបញ្ជាក់ខាងលើ អង្គជំនុំជម្រះយល់ឃើញថា ដោយសារតែកាលៈទេសៈដូចបានបង្ហាញនេះ ការប្រើភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មក្នុងគោលបំណងមានកម្រិតមួយ ដើម្បីកំណត់អំពីអំពើអ្វីខ្លះដែលជាបច្ច័យនៃការដែលផ្អែកលើអង្គហេតុដែលចេញពីចម្លើយសារភាពនោះត្រូវបានធ្វើឡើង មិនបំពានលើដំណើរការត្រឹមត្រូវតាមផ្លូវតុលាការ ឬសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទនោះឡើយ[149]។

៧៨. អង្គជំនុំជម្រះយល់ឃើញថា ពាក្យពេចន៍ខាងលើនៃមាត្រា ១៥ ការពារបានពេញលេញនូវកម្មវត្ថុ និងគោលបំណងនៃវិធានបដិសេធភ័ស្តុតាង ហើយនៅពេលជាមួយគ្នានេះ អនុញ្ញាតឱ្យចោទប្រកាន់

---

[149] អង្គជំនុំជម្រះតុលាការកំពូលលើកឡើងថា អង្គជំនុំជម្រះឯកភាពជាមួយនឹងអាជ្ញាធរតុលាការដែលសម្រេចថា ភាពចាំបាច់នៃការកាត់ទោសមិនអាចផ្តល់យុត្តិកម្មចំពោះការប្រើប្រាស់ចម្លើយដែលបានមកដោយការធ្វើទារុណកម្មឡើយ។ *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៦៧។ វាហាក់ដូចជាថា ការវិភាគរបស់ខ្លួនសម្រាប់តែវិធានបដិសេធទូទៅនៅក្នុងមាត្រា ១៥ ហើយមិនបានបកស្រាយអញ្ញត្រកម្មដែលមាននៅក្នុងមាត្រានេះទេ។ លើសពីនេះទៀត ក្នុងចំណោមអាជ្ញាធរតុលាការដែលបានដកស្រង់ទាំងអស់ មិនមានអាជ្ញាធរមួយណាពាក់ព័ន្ធនឹងការជំនុំជម្រះជនជាប់ចោទពីបទទារុណកម្មឡើយ ដែលមាត្រា ១៥ អនុវត្តចំពោះបទចោទនេះ។

ជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ចំពោះអំពើទារុណកម្ម។ ឥឡូវនេះ អង្គជំនុំជម្រះពិចារណាទៅលើការអនុវត្តជាក់ស្តែងនៃគោលការណ៍ទាំងនេះចំពោះភ័ស្តុតាងនៅក្នុងករណីនេះ។

### ៥.៥.១ ភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ ដែលមានហានិភ័យពិតប្រាកដដែលថាភ័ស្តុតាងនេះបានមកដោយការធ្វើទារុណកម្ម

៧៩. អង្គជំនុំជម្រះរម្លឹកនូវការយល់ឃើញរបស់ខ្លួននៅក្នុងសាលក្រមសំណុំរឿង ០០១ ដែលត្រូវបានទទួលស្គាល់នៅដំណាក់កាលនៃការប្តឹងសាទុក្ខថា អំពើទារុណកម្មត្រូវបានប្រើប្រាស់ដើម្បីបានចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ ។ នៅពេលអ្នកជាប់ឃុំមិនបានឆ្លើយឱ្យពេញចិត្តអ្នកសួរចម្លើយទេនោះ អំពើទារុណកម្មបន្ថែមត្រូវបានអនុវត្ត ហើយភាគច្រើននៃព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពទាំងនោះត្រូវបានប្រឌិតឡើង[150]។ បើទោះជាអាជ្ញាអស់ជំនុំ (*res judicata*) មិនអាចអនុវត្តចំពោះសំអាងហេតុក្នុងសាលក្រមសំណុំរឿង ០០១ ពាក់ព័ន្ធនឹងជនជាប់ចោទក្នុងករណីសំណុំរឿងនេះ ដោយសារពួកគាត់មិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០១ ក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា សំអាងហេតុទាំងនេះបង្ហាញអំពីហានិភ័យពិតប្រាកដដែលថាចម្លើយសារភាពណាដែលធ្វើនៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែបានមកដោយអំពើទារុណកម្ម។ លើសពីនេះទៅទៀត ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ សហចៅក្រមស៊ើបអង្កេត នៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីអត្ថិភាពនៃភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជូនសំណុំរឿង ០០២ មកកាន់អង្គជំនុំជម្រះសាលាដំបូង សហចៅក្រមស៊ើបអង្កេត បានយល់ឃើញថា អំពើទារុណកម្មត្រូវបានអនុវត្តនៅតាមមន្ទីរសន្តិសុខដទៃទៀត ដើម្បីបានចម្លើយសារភាព និង "ដើម្បីកំណត់អត្តសញ្ញាណសមាជិករបស់ "បណ្តាញ"ពួកគេ សម្រាប់ធ្វើការចាប់ខ្លួន[151]។ ហេតុដូច្នេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ហានិភ័យពិតជាមានមែន ដែលថា អំពើទារុណកម្មត្រូវបានអនុវត្តនៅមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខដទៃទៀត ដើម្បីបានចម្លើយសារភាព។ អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឱ្យប្រើភ័ស្តុតាងប្រភេទនេះទេ លើកលែងតែភាគីដែលស្នើសុំឱ្យប្រើភ័ស្តុតាងបង្ហាញឱ្យឃើញថា មិនមានហានិភ័យ

[150] សាលក្រមសំណុំរឿង ០០១ កថាខណ្ឌ ១៧៦, ១៧៧, ១៧៩។

[151] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៨, ១៤១១។

ពិតប្រាកដដែលថា ភ័ស្តុតាងនោះបានមកតាមរយៈការធ្វើទារុណកម្ម ឬក៏ថាវាស្ថិតនៅក្នុងអញ្ញត្រកម្មនៃមាត្រា ១៥[152]។

### ៥.៥.២ ការប្រើភ័ស្តុតាងដែលបានមកដោយអំពើទារុណកម្មក្នុងសំណុំរឿង ០០២/០២

៨០. ដើម្បីផ្តល់ជាការណែនាំដល់ភាគីអំពីការអនុវត្តគោលការណ៍ទាំងនេះ ឥឡូវនេះ អង្គជំនុំជម្រះពិចារណាទៅលើកាលៈទេសៈផ្សេងៗនៅក្នុងករណីនេះ ដែលភាគីបានប្រើ ឬ ស្នើសុំអនុញ្ញាតប្រើភ័ស្តុតាងដែលអាចបានមកដោយការធ្វើទារុណកម្ម។

៨១. មេធាវីការពារក្តីរបស់ នួន ជា និង សហព្រះរាជអាជ្ញា មានបំណងប្រើចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ដើម្បីតាំងសំណួរទៅសាក្សីនៅក្នុងករណីនេះ ឬ ក្នុងសវនាការពិនិត្យលើឯកសារភ័ស្តុតាងគន្លឹះ[153]។ នៅពេលដែលសំណួរទាំងនេះយោងទៅលើចំណារ ឬ សួរអំពីព័ត៌មានអត្តសញ្ញាណជាមូលដ្ឋាន សំណួរបែបនេះអាចអនុញ្ញាតឱ្យសួរបាន។ សំណួរក្រៅពីនេះ មិនត្រូវបានអនុញ្ញាតឱ្យសួរបានទេ។

៨២. មេធាវីការពារក្តីរបស់ នួន ជា ក៏បានយោងទៅឯកសារដែលមាននៅក្នុងចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ផងដែរ ដោយមិនបានកំណត់ឱ្យជាក់លាក់អំពីចម្លើយសារភាពមួយណា ឬ បញ្ជាក់ថាតើចម្លើយសារភាពទាំងនេះ ជាមូលដ្ឋានក្នុងការតាំងសំណួរទាំងនោះនោះទេ[154]។ កាល

---

[152] ចៅក្រម FENZ យល់ស្របជាទូទៅចំពោះការសម្រេចរបស់ចៅក្រមមតិភាគច្រើន នៅក្នុងផ្នែក ៥.៥.១ ប៉ុន្តែគាត់នៅរក្សាជំហជំទាស់ចំពោះការបកស្រាយករណីអញ្ញត្រកម្មនៅក្នុងមាត្រា ១៥។

[153] ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៥ ទំព័រទី ៣៩-៤២ (មេធាវីការពារក្តី នួន ជា បានយោងទៅចម្លើយសារភាពពីមន្ទីរស-២១ របស់ ជូ ចេត ឯកសារ E3/746 នៅក្នុងសវនាការពិនិត្យលើភ័ស្តុតាងគន្លឹះ)។ ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៣២-៣៣, ៥៥-៥៧។

[154] ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ទំព័រទី ៣០-៣៥ (ក្នុងពេលតាំងសំណួរទៅ ពេជ្រ ជឹម មេធាវីការពារក្តីរបស់ នួន ជា សួរថាតើសាក្សីបានដឹង "ថា សែ ឆ្លើយដាក់អ្នក និង បងប្អូនរបស់អ្នកថាជាប់ខ្សែរបស់គាត់"។ សហព្រះរាជអាជ្ញាជំនួយបានលើកឡើងថា ព័ត៌មាននេះមាននៅក្នុងចម្លើយសារភាពពីមន្ទីរស-២១ របស់ កង ចាប (E3/2792)។ ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ៤ (មេធាវីការពារក្តីរបស់ នួន ជា សួរថាតើសាក្សី"ធ្លាប់បានឮការស្តុកទុកស្បៀងអាហារចំនួន ១០០០ តោន នៅអន្លង់ក្ងាន ទុកប្រើសម្រាប់ទ័ពដែលចូលរួមក្នុងការបះបោរដែរឬយ៉ាងណា")។

ណាមូលដ្ឋាននៃការតាំងសំណួរមិនត្រូវបានបង្ហាញឱ្យបានត្រឹមត្រូវទេ សំណួរបែបនេះនឹងមិនត្រូវបានអនុញ្ញាតឱ្យសួរឡើយ[155]។

៨៣. ពាក់ព័ន្ធនឹងមេធាវីការពារក្ដីរបស់ នួន ជា ដែលស្នើសុំការបំភ្លឺអំពីសំណួររបស់ខ្លួន ដែលសួរទៅសាក្សី ពេជ្រ ជឹម (“តើអ្នកមានធ្លាប់ដែលដឹងថា សែ បានឆ្លើយដាក់អ្នក និង បងប្អូនអ្នកថាជាប់ខ្សែរបស់គាត់ដែរ ឬ ទេ?”) អង្គជំនុំជម្រះកត់សម្គាល់ថា ការសួរនេះមិនយកជាការទេ ដោយសាក្សីបានឆ្លើយសំណួរនោះរួចទៅហើយ។ ទោះជាយ៉ាងនេះក្ដី ដោយសារភាគីនៅបន្តតាំងសំណួរស្រដៀងគ្នានេះជាបន្តទៀត[156] ហើយអង្គជំនុំជម្រះត្រូវសម្រេចថាតើខ្លួនអាចផ្អែកលើចម្លើយដែលបានឆ្លើយនោះយកធ្វើជាភស្តុតាងដែរ ឬ យ៉ាងណា អង្គជំនុំជម្រះផ្ដល់ការណែនាំដូចខាងក្រោម។

៨៤. សំណួរដែលសួរទៅសាក្សី ពេជ្រ ជឹម សួរអំពីការដឹងរបស់សាក្សី។ សំណួរនេះចង់ដឹងព័ត៌មានពីសាក្សី អំពីការដឹងរបស់គាត់ពាក់ព័ន្ធនឹងការដែលគាត់ត្រូវបានចោទថាបានប្រព្រឹត្តអំពើដែលអាចត្រូវបានចាត់ទុកថាក្បត់ ប.ក.ក។ វិធីដែលគាត់ដឹងអំពីចំណុចនេះ ជាចំណុចសំខាន់ ដោយសារវាអាចពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធទំនាក់ទំនងការងារនៅក្នុងរបបនោះ។ ចំណុចនេះត្រូវបានគាំទ្រដោយសហព្រះរាជអាជ្ញា[157]។ កន្លងមក ឱ្យតែចម្លើយសារភាពដែលបានមកដោយអំពើទារុណកម្មមិនត្រូវបានសួរទៅសាក្សី ដើម្បីបញ្ជាក់អង្គហេតុ ហើយសំណួរផ្ដោតទៅលើការដឹងរបស់សាក្សីអង្គជំនុំជម្រះយល់ឃើញថា ទម្រង់សំណួរបែបនេះត្រូវបានអនុញ្ញាតឱ្យសួរបាន[158]។

---

[155] ប្រតិចារឹក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ៥-៦។

[156] ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ ឧសភា ទំព័រទី ៣២-៣៣, ៥៥-៥៧។

[157] ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ទំព័រទី ៣២ ( “[...] ខ្ញុំគិតថា មានសំណួរស្របច្បាប់មួយដែលអាចសួរបាន -- ពិតណាស់ គឺមិនមែនសួរអំពីសច្ចភាពនៃបញ្ហានេះទេ។ [...] អ្វីដែលពាក់ព័ន្ធ គឺការសួរចង់ដឹង ថាតើការពិតដែលគាត់ត្រូវគេឆ្លើយដាក់នោះ ត្រូវបានប្រាប់គាត់ឱ្យដឹងដោយ កែ ពក ឬ អ្នកផ្សេង ឬយ៉ាងណា។ ដូច្នេះ ពាក់ព័ន្ធនឹងបញ្ហានេះ គឺថាសំណួរដែលសួរថាតើចម្លើយសារភាពនេះ ត្រូវបានប្រើកាលនៅក្នុងរបបនោះ និង ត្រូវបានផ្ដល់ព័ត៌មានទៅមនុស្សដទៃ ខ្ញុំគិតថាជាសំណួរសមស្រប។ ការប្រើវាសម្រាប់សច្ចភាពនៃចម្លើយសារភាពនោះ ត្រូវបានហាមឃាត់ទាំងស្រុង”)។

[158] ប្រសិនរបៀបនៃការតាំងសំណួរ ឈានទៅរកការបញ្ជាក់ថា សាក្សីរូបនោះពិតជាផ្នែកមួយបណ្ដាញមួយដែលមានផែនការបះបោរប្រឆាំងថ្នាក់ដឹកនាំ បកក សំណួរបែបនេះច្បាស់ជាពឹងផ្អែកលើសច្ចភាពនៃចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម។ ការប្រើភស្តុតាងក្នុងករណីបែបនេះ មិនត្រូវបានអនុញ្ញាតឡើយ។

៨៥. ចំណុចនេះផ្ទុយទៅនឹងសំណួរដែលអង្គជំនុំជម្រះមិនអនុញ្ញាតឱ្យមេធាវីការពារក្តីរបស់ នួន ជា សួរសាក្សី ខឹម បឿន។ មេធាវីការពារក្តីព្យាយាមជជីកសួរសាក្សី ដោយប្រើចម្លើយសារភាពរបស់ ជូ ជេត ដើម្បីឱ្យសាក្សីឆ្លើយបញ្ជាក់ ឬ បដិសេធការពិតដែលមាននៅក្នុងចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ (ឧទាហរណ៍ថាតើ សោម ជាមនុស្សជិះជាន់គេ និង ជាមនុស្សជ្រុលនិយម ឬយ៉ាងណានោះ)[159]។ សំណួរនេះមិនផ្តោតលើការដឹងរបស់សាក្សីនោះទេ។ សំណួរនេះមានបំណងជំទាស់ទៅនឹងសាក្សី ដោយសារកាលពីមុនសាក្សីបានឆ្លើយថា គាត់មិនចាំអ្វីពិតប្រាកដចំពោះ សោម នោះទេ[160]។ហេតុដូច្នេះ សំណួរនេះមិនត្រូវបានអនុញ្ញាតឱ្យសួរទេ ដោយសារវាប្រើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ដើម្បីបញ្ជាក់ពីសច្ចភាពនៃបញ្ហាដែលបានលើកអះអាង[161]។

៨៦. សហព្រះរាជអាជ្ញា និង មេធាវីការពារក្តីរបស់ នួន ជា សុទ្ធតែមានបំណងសួរសំណួរដែលផ្អែកលើចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ របស់ ស្នួង (E3/1892)។ មេធាវីការពារក្តីរបស់ នួន ជា លើកឡើងថា កំណត់សម្គាល់នៅខាងលើចម្លើយសារភាពក្នុងសំណៅជាភាសាអង់គ្លេស បញ្ជាក់ថាចម្លើយសារភាពនោះត្រូវបានសរសេរនៅមុនគាត់ត្រូវបានធ្វើទារុណកម្ម។ អង្គជំនុំជម្រះបានសម្រេចថា ខ្លឹមសារនៃចម្លើយសារភាព នឹងមិនត្រូវបានអនុញ្ញាតឱ្យអានទេ ដោយសារតែមានភាពមិនច្បាស់លាស់អំពីថា តើចម្លើយសារភាពបានមកក្នុងលក្ខខណ្ឌបែបណា[162]។ អង្គជំនុំជម្រះយល់ឃើញថា កំណត់សម្គាល់នៅផ្នែកខាងលើនៃប្រភពឯកសារដែលចោទជាបញ្ហា ដែលមានតែជាភាសាអង់គ្លេស និង គ្មានឯកសារដើមជាភាសាខ្មែរនោះ មិនអាចតតាំងទៅនឹងការសន្មតអំពីហានិភ័យពិតប្រាកដដែលថា ចម្លើយសារភាពនោះបានមកដោយការធ្វើទារុណកម្មនោះបានទេ។

[159] ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៣២ ("ខ្ញុំចង់សួរគាត់អំពីចម្លើយរបស់ ជូ ចេត ដែលថា សោម ជាមនុស្សជិះជាន់គេ និង ជាមនុស្សដាច់ខាត ហើយសំណួររបស់ខ្ញុំ គឺចង់សួរថាតើគាត់យល់ស្របនឹងចំណុចនេះដែរឬយ៉ាងណា ចាស ឬ ទេ?")។

[160] ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ២៩-៣០។

[161] *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កាថខណ្ឌ ៤៧ ("អានុភាពនៃវិធានបដិសេធភស្តុតាងចែងថា ចម្លើយដែលស្ថិតក្រោមវិធាននេះ ពុំអាចត្រូវបានប្រើប្រាស់ក្នុងការបញ្ជាក់ពីការពិតនៃខ្លឹមសារ ឬក៏សូម្បីតែធ្វើសេចក្តីស្និដ្ឋានដោយប្រយោលថាខ្លឹមសារនោះអាចជាការពិត ដើម្បីដេញដោលសាក្សីឡើយ")

[162] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រទី ៨០-៨១។

ដោយសារតែវាជាភ័ស្តុតាងដែលបានមកដោយសារធ្វើទារុណកម្ម ការប្រើភ័ស្តុតាងបែបនេះ ត្រូវតែស្ថិតក្រោមការកំហិតផ្អែកតាមលក្ខខណ្ឌដែលបានរៀបរាប់ខាងលើ[163]។

៨៧. លើសពីនេះទៀត សហព្រះរាជអាជ្ញា ជាច្រើនលើកច្រើនសា បានតាំងសំណួរទៅសាក្សីដោយផ្អែកលើសៀវភៅកំណត់ហេតុ ឬ សៀវភៅបញ្ជីឈ្មោះអ្នកជាប់ឃុំពីមន្ទីរសន្តិសុខនានា[164]។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះ ដែលមានគំនិត និង ការយល់ឃើញរបស់អ្នកធ្វើទារុណកម្ម អាចអនុញ្ញាតឱ្យប្រើបាន ដរាបណាឯកសារទាំងនេះមិនត្រូវបានប្រើដើម្បីបញ្ជាក់ការពិតនៃខ្លឹមសារចម្លើយសារភាពរបស់អ្នកដែលត្រូវទទួលរងអំពើទារុណកម្មទាំងនោះ។ ឧទាហរណ៍ ប្រសិនបើភាគីអាចបញ្ជាក់បានថា មនុស្សដែលមាននៅក្នុងបញ្ជី ត្រូវបានចាប់ខ្លួននៅពេលបន្ទាប់ ឬ ត្រូវបានសម្លាប់ ឯកសារនោះអាចធ្វើជាភ័ស្តុតាងថា ជនជាប់ចោទ ឬ អ្នកផ្សេងទៀតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាបានពឹងផ្អែកទៅលើព័ត៌មាននេះ[165]។

**៥.៥.៣ ការអនុវត្តគោលការណ៍ទាំងនេះនៅពេលអនាគត**

៨៨. អង្គជំនុំជម្រះទទួលស្គាល់ថា ដើម្បីធ្វើឱ្យមានតុល្យភាពនៃប្រយោជន៍ ដែលមាត្រា ១៥ មានបំណងការពារ រាល់ភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្មដែលបានស្នើឡើង ត្រូវឆ្លងកាត់ការវាយតម្លៃទៅតាមករណីជាក់ស្តែងនីមួយៗ។ យ៉ាងណាក៏ដោយ គោលការណ៍ណែនាំជាក់លាក់មួយចំនួន អាចធ្វើឱ្យមានភាពច្បាស់លាស់បន្ថែមទៀតអំពីការអនុវត្តគោលការណ៍ទាំងនេះ។ ទីមួយ ការអានចម្លើយសារភាពដែលបានមកដោយអំពើទារុណកម្ម ដោយផ្ទាល់ក្នុងសវនាការ ទោះបីជាមានចេតនាបែបណាក៏ដោយ វានឹងធ្វើឱ្យមានការយល់ឃើញថា ឯកសារនោះកំពុងត្រូវបានប្រើដើម្បីបង្ហាញការពិតនៃចម្លើយសារភាពនោះ។ ការប្រើប្រាស់បែបនេះ ទំនងជាមិននាំឱ្យអង្គជំនុំ-

---

[163] ចៅក្រម FENZ រក្សាជំហរជំទាស់ចំពោះការបកស្រាយករណីអញ្ញត្រកម្មនៅក្នុងមាត្រា ១៥។

[164] ប្រតិចារឹកចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥ ទំព័រទី ៩-១០, ២៥-២៦ (សហព្រះរាជអាជ្ញាជំនួយយោងឯកសារ D157.7)។ ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ៤៧-៤៨ (ពេលសួរសាក្សី ខឹម ហឿន សហព្រះរាជអាជ្ញាជំនួយយោងឯកសារ E3/2048)។ ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រទី ១៩-២១ (សហព្រះរាជអាជ្ញាយោងសៀវភៅកំណត់ហេតុ ក្រាំងតាចាន់ (D157.13, E3/5860), ដោយកត់សម្គាល់ព័ត៌មានអំពីប្រវត្តិរូបរបស់មនុស្សម្នាក់ និង ឈ្មោះរបស់បុគ្គលមួយចំនួន ដែលត្រូវបានកំណត់ថាជាជនក្បត់ ទោះបីមិនបានសួរថាតើអ្នកទាំងនោះជាជនក្បត់ពិតប្រាកដមែន ឬ មិនមែន)។

[165] ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ២៧។

ជម្រះទទួលយកឡើយ។ ទីពីរ ការតតាំងជាមួយសាក្សីដោយផ្អែកទៅលើការចោទប្រកាន់ដែលមាននៅក្នុងចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម មិនយុត្តិធម៌ចំពោះសាក្សីនោះទេ ហើយការធ្វើដូច្នេះបង្ហាញថា ការយោងនេះធ្វើឡើងដើម្បីបញ្ជាក់ការពិតនៃចម្លើយសារភាពនោះ[166]។ ការប្រើប្រាស់បែបនេះអង្គជំនុំជម្រះនឹងមិនអនុញ្ញាតឡើយ។

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**សម្រេចថា** វិធានបដិសេធភ័ស្តុតាង ដែលមានក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មតម្រូវឱ្យភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធីអនុវត្តតាម ។

**សម្រេចថា** ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហាមឃាត់ការផ្តល់ទម្ងន់ណាក៏ដោយទៅលើចម្លើយដែលបានមកដោយការបង្ខិតបង្ខំ នៅក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងដំណាក់កាលរៀបចំ និងចេញសាលក្រម។

**សម្រេចថា** មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម មិនមានវិសាលភាពអនុវត្តចំពោះភ័ស្តុតាងដែលបានមកដោយអំពើឃោរឃៅ អមនុស្សធម៌ និង ការបន្ទាបបន្ថោក ឬ ភ័ស្តុតាងដែលកើតចេញពីភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម។

**សម្រេចថា** ចម្លើយសារភាពពីមន្ទីរសន្តិសុខនានា ដែលសហចៅក្រមស៊ើបអង្កេតបានកំណត់ថាមានការប្រើអំពើទារុណកម្ម ស្ថិតក្នុងវិសាលភាពនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ដូច្នេះហើយ អាចមិនត្រូវបានអនុញ្ញាតឱ្យប្រើក្នុងកិច្ចដំណើរការនីតិវិធីនេះទេ លើកលែងតែមានករណីជាក់ស្តែងណាមួយដែលមានការបង្ហាញថា ចម្លើយសារភាពនោះ មិនមែនទទួលបានដោយការធ្វើទារុណកម្ម ឬថា ភ័ស្តុតាងនោះត្រូវបានប្រើប្រាស់អនុលោមតាមអញ្ញត្រកម្មដែលមានក្នុងមាត្រា ១៥ និង

**បញ្ជាក់ជាថ្មីថា** អញ្ញត្រកម្មលើវិធានបដិសេធភ័ស្តុតាងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម អនុញ្ញាតឱ្យប្រើភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់

---

[166] ចៅក្រម FENZ យល់ស្របចំពោះលទ្ធផលនេះ ប៉ុន្តែរក្សាជំហរជំទាស់ចំពោះការបកស្រាយករណីអញ្ញត្រកម្មនៅក្នុងមាត្រា ១៥។

អំពីការធ្វើទារុណកម្ម ក្នុងគោលបំណងផ្សេងៗក្រៅពីការបញ្ជាក់ការពិតទៅលើការលើកឡើងនៅក្នុងចម្លើយសារភាព (ដោយចៅក្រម Fenz មានមតិជំទាស់ ដែលសម្អាងហេតុនឹងចេញនៅពេលក្រោយ)។

ភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

និល ណុន